**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

## សារណាបញ្ចប់ការសិក្សា

# តួនាទីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **រុន សុវណ្ណាត្រី**
**លៀប ឈីអ័រ**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ឌុយ ចាន់ឌីណា**

ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍
ជំនាន់ទី ០៣

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ រុន សុវណ្ណាត្រី និងលៀប ឈីអ័រ ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ក្រុម $D_4B_1$ ឆ្នាំសិក្សា២០១៨-២០១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ

១. លោកអ្នកមានគុណទាំងទ្វេ គឺលោកឪពុក និងអ្នកម្តាយ ដែលលោកទាំងពីរបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ព្រមទាំងបានឧបត្ថម្ភគាំទ្រទាំងផ្នែកថវិកានិងកម្លាំងចិត្តដល់រូបយើងខ្ញុំតាំងពីចាប់កំណើត រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។

២. លោកសាស្ត្រាចារ្យបណ្ឌិត ឌុយ ចាន់ឌីណា ដែលបានចំណាយទាំងកម្លាំងកាយចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំតម្រង់ទិស កែរតម្រូវ និងផ្តល់អនុសាសន៍ ដល់យើងខ្ញុំទាំងពីរក្នុងការសរសេរនូវសារណាបញ្ចប់ការសិក្សានេះ។

៣. ថ្នាក់ដឹកនាំ គណៈគ្រប់គ្រង និងមន្ត្រីនៃក្រសួងបរិស្ថានទាំងអស់ ជាពិសេសនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលបានផ្តល់នូវឯកសារសំខាន់ៗមួយចំនួន ព្រមទាំងផ្តល់ឱកាសដល់យើងខ្ញុំក្នុងការជួបសម្ភាសន៍ផ្ទាល់ជាមួយលោកអនុប្រធាននាយកដ្ឋានវាយម្លៃហេតុប៉ះពាល់បរិស្ថាន និងលោកប្រធានការិយាល័យស្រាវជ្រាវនិងបណ្តុះបណ្តាល។

៤. ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស លោក-លោកស្រីសាស្ត្រាចារ្យ មន្ត្រីការិយាល័យស្រាវជ្រាវ និងការិយាល័យសិក្សា ព្រមទាំងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយបង្ហាត់បង្រៀនអស់ពីកម្លាំងកាយចិត្ត និងជួយសម្រួលដល់ដំណើរការរៀនសូត្ររបស់យើងខ្ញុំទាំងពីរតាំងពីឆ្នាំទីមួយរហូតដល់ឆ្នាំបញ្ចប់នេះ។

ជាចុងបញ្ចប់ យើងខ្ញុំសូមជូនពរដល់អ្នកទាំងអស់គ្នាអោយជួបប្រទះនូវពុទ្ធពរទាំងឡាយបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ ព្រមទាំងសម្រេចជោគជ័យលើគ្រប់បំណងប្រាថ្នាទាំងឡាយ។

# អារម្ភកថា

ប្រទេសកម្ពុជា ដែលធ្លាប់ជាប្រទេសពឹងផ្អែកលើវិស័យកសិកម្ម កំពុងប្រែក្លាយជាប្រទេសដែលពឹងផ្អែកលើវិស័យឧស្សាហកម្មវិញ។ ការណ៍នេះ បានជម្រុញអោយសំណង់ រោងចក្រសហគ្រាស និងគំរោងអភិវឌ្ឍន៍នានាមានការរីកដុះដាល និងការកើនឡើងជាលំដាប់។ ការកើនឡើងនេះនឹងមានផលប៉ះពាល់ដល់បរិស្ថានរបស់កម្ពុជាជាក់ជាមិនខាន ប្រសិនបើកម្ពុជាមិនមានការទប់ស្កាត់និងពិនិត្យអោយបានម៉ត់ចត់លើគម្រោងទាំងនោះទេ។ តបតាមបញ្ហានេះ ទើបក្រសួងបរិស្ថានរបស់កម្ពុជាបាននិងកំពុងធ្វើការងារយ៉ាងសកម្មទៅលើបញ្ហានេះ តាមរយៈ **នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន(EIA)។**

ដើម្បីអោយដឹងកាន់តែច្បាស់ថានាយកដ្ឋាននេះមានការរួមចំណែកយ៉ាងណាខ្លះក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា យើងខ្ញុំដែលទទួលបានការណែនាំពីសាស្ត្រាចារ្យ **បណ្ឌិត ឌុយ ចាន់ឌីណា** បានសម្រេចលើកយកប្រធានបទ **"តួនាទីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន(EIA)ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា"** ដើម្បីសិក្សាស្រាវជ្រាវ និងសរសេរជាសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ។

មិនតែប៉ុណ្ណោះ អំពីប្រធានបទនេះ យើងខ្ញុំក៏សង្ឃឹមយ៉ាងមុតមាំដែរថា វានឹងក្លាយជាឯកសារដ៏មានសារៈសំខាន់ សម្រាប់សិស្ស និស្សិត និងសាធារណជនទាំងឡាយបានសិក្សាស្រាវជ្រាវ។ មួយវិញទៀត វាក៏សំខាន់ណាស់ដែរក្នុងការដោះស្រាយចម្ងល់សម្រាប់សិស្ស និស្សិត និងសាធារណជនទាំងឡាយ ដែលមានការព្រួយបារម្ភទាក់ទងនឹងបញ្ហាបរិស្ថាន ដែលកើតចេញពីគម្រោងអភិវឌ្ឍន៍នានា។

ជាចុងក្រោយ យើងខ្ញុំសូមអភ័យទោសជាមុនផងដែរ នូវរាល់កំហុសខុសឆ្គងដោយអចេតនាតាមរយៈខ្លឹមសារ ឬកំហុសអក្ខរាវិរុទ្ធជាដើម ពីព្រោះថាថ្វិត្បិតតែយើងខ្ញុំបានធ្វើការស្រាវជ្រាវលើប្រធានបទនេះ ប៉ុន្តែក៏គង់នឹងមានការខ្វះចន្លោះណាមួយមិនខាន។ ម្យ៉ាងវិញទៀត យើងខ្ញុំរងចាំជានិច្ចនូវការរិះគន់ដើម្បីស្ថាបនាពីសំណាក់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងមិត្តអ្នកអានទាំងឡាយដោយសេចក្តីរីករាយបំផុត។

សូមអរគុណ!

# មាតិកា


បញ្ជីអក្សរកាត់ ........ v

បញ្ជីតារាង ........ vi

## សេចក្តីផ្តើម

១. លំនាំបញ្ហា ........ ១

២. ចំណោទបញ្ហា ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣

៥. វិធីសាស្រ្តនៃការស្រាវជ្រាវ ........ ៣

៦. សារសំខាន់នៃការស្រាវជ្រាវ ........ ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤

## ជំពូកទី១
## រំលឹកទ្រឹស្តី

១.១. ទស្សនៈទាននៃសេដ្ឋកិច្ច ........ ៥

១.១.១. និយមន័យ ........ ៥

១.១.២. ការយល់ឃើញអំពីសេដ្ឋកិច្ច ........ ៥

១.១.៣. ប្រភេទសេដ្ឋកិច្ច ........ ៦

១.២. ការអភិវឌ្ឍសេដ្ឋកិច្ច ........ ៧

១.២.១. និយមន័យ ........ ៧

១.២.២. លំនាំដើមនៃការអភិវឌ្ឍសេដ្ឋកិច្ច ........ ៧

១.២.៣. ការវាស់វែងការអភិវឌ្ឍសេដ្ឋកិច្ច ........ ៧

១.៣. អ្វីទៅជាបរិស្ថាន ........ ៨

១.៣.១. និយមន័យ ........ ៨

១.៣.២. ចំណាត់ថ្នាក់បរិស្ថាន ........ ៨

១.៣.៣. បញ្ហាបរិស្ថាននៅលើពិភពលោក ........ ៩

១.៤. ទំនាក់ទំនងបរិស្ថាន និងការអភិវឌ្ឍសេដ្ឋកិច្ច ........ ១៣

១.៤.១. បរិស្ថានធម្មជាតិ និងកំណើនសេដ្ឋកិច្ច ........ ១៣

១.៤.២. បរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាព ..... ១៥
១.៥. ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (Environment Impact Assessment) ..... ១៦
១.៥.១. និយមន័យ ..... ១៦
១.៥.២. ដើមកំណើតនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ..... ១៦

## ជំពូកទី២

## បរិស្ថាន និងការអភិវឌ្ឍនៅកម្ពុជា

២.១. ស្ថានភាពបរិស្ថាននៅកម្ពុជា ..... ១៨
២.២. គុណតម្លៃនៃបរិស្ថានមកលើការអភិវឌ្ឍនៅកម្ពុជា ..... ២០
២.៣. ផលប៉ះពាល់នៃការអភិវឌ្ឍមកលើបរិស្ថាននៅកម្ពុជា ..... ២២
២.៣.១. ការបំពុលខ្យល់ ..... ២២
២.៣.២. ការបំពុលទឹក ..... ២៣
២.៣.៣. កាកសំណល់រឹង ..... ២៦
២.៣.៤. បម្រែបម្រួលអាកាសធាតុ ..... ២៦

## ជំពូកទី៣

## នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

៣.១. ប្រវត្តិនៃការបង្កើតក្រសួង ..... ៣០
៣.២. ចក្ខុវិស័យ និងបេសកកម្ម ..... ៣០
៣.៣. រចនាសម្ព័ន្ធក្រសួង ..... ៣២
៣.៤. បុព្វហេតុនៃការបង្កើតនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ..... ៣៤
៣.៥. រចនាសម្ព័ន្ធនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ..... ៣៥
៣.៦. តួនាទីរបស់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ..... ៣៥

## ជំពូកទី៤

## នីតិវិធីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

៤.១. បទប្បញ្ញត្តិផ្សេងៗទាក់ទងនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ..... ៣៨
៤.២. ការជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា ..... ៣៩
៤.២.១. លក្ខណៈវិនិច្ឆ័យ ..... ៤០
៤.២.២. លក្ខខណ្ឌដែលក្រុមហ៊ុនទីប្រឹក្សាត្រូវបំពេញ ..... ៤២

៤.៣. ប្រភេទនៃគម្រោងដែលត្រូវវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ........ ៤៥
៤.៤. កិច្ចដំណើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ........ ៤៨
៤.៤.១. គម្រោងស្នើសុំ ........ ៤៨
៤.៤.២. ការជ្រើសរើសគម្រោង ........ ៤៨
៤.៤.៣. ការកំណត់វិសាលភាព ........ ៤៩
៤.៤.៤. ការវិភាគហេតុប៉ះពាល់បរិស្ថាន ........ ៤៩
៤.៤.៥. វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន ........ ៥០
៤.៤.៦. ការរៀបចំរបាយការណ៍ហេតុប៉ះពាល់បរិស្ថាន ........ ៥១
៤.៤.៧. ការពិនិត្យ និងធ្វើសេចក្តីសម្រេចលើរបាយការណ៍ ........ ៥១
៤.៤.៨. ការអង្កេតតាមដានគម្រោង ........ ៥២

**ជំពូកទី៥**

**តួនាទីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមកលើការអភិវឌ្ឍ សេដ្ឋកិច្ចកម្ពុជា**

៥.១. ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់រោងចក្រ និងសិប្បកម្ម ........ ៥៣
៥.១.១. សេចក្តីផ្តើម ........ ៥៣
៥.១.២. គោលបំណងនៃលក្ខខណ្ឌការងារ ........ ៥៣
៥.១.៣. ការពិពណ៌នាគម្រោង ........ ៥៤
៥.១.៤. ទំហំ និងវិធីសាស្រ្តនៃការសិក្សា ........ ៥៦
៥.១.៥. ការកំណត់ទម្រង់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមសង្គមដំបូង ........ ៦៥
៥.១.៦. សមាសភាពក្រុមហ៊ុនទីប្រឹក្សាចុះសិក្សា ........ ៦៥
៥.១.៧. តារាងការងារ/សកម្មភាពការងាររបស់ក្រុមហ៊ុនទីប្រឹក្សាសិក្សាលើម្ចាស់គម្រោង ........ ៦៥
៥.១.៨. ឧបសម្ព័ន្ធ ........ ៦៥
៥.២. ការវិភាគអត្ថប្រយោជន៍ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើវិស័យឧស្សាហកម្ម ........ ៦៥
៥.២.១. អត្ថប្រយោជន៍នៃការធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើគម្រោងឧស្សាហកម្មសម្រាប់ម្ចាស់គម្រោង ........ ៦៧
៥.២.២. អត្ថប្រយោជន៍នៃការធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើគម្រោងឧស្សាហកម្មសម្រាប់សង្គមជាតិទាំងមូល ........ ៧០

## ជំពូកទី៦

## បញ្ហាប្រឈម និងដំណោះស្រាយ

៦.១. បញ្ហាប្រឈម ..... ៧៤

៦.២. ដំណោះស្រាយ ..... ៧៤

## សេចក្តីសន្និដ្ឋាន និង អនុសាសន៍

១. សន្និដ្ឋាន ..... ៧៦

២. អនុសាសន៍ ..... ៧៧

**គន្ថនិទ្ទេស**

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

**EIA** Environment Impact Assessment
ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**EPI** Environment Performance Index
សន្ទស្សន៍នៃការអនុវត្តខាងបរិស្ថាន

**OECD** Organization for Economic Co-operation Development
អង្គការសហប្រតិបត្តិការអភិវឌ្ឍសេដ្ឋកិច្ច

**ODC** Open Development Cambodia
អង្គការទិន្នន័យអំពីការអភិវឌ្ឍ

**UNICEF** United Nations International Children’s Emergency Fund
មូលនិធិអង្គការសហប្រជាជាតិសម្រាប់កុមារនៅកម្ពុជា

**USAID** United States Agency for International Development
ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ

# បញ្ជីតារាង

តារាងទី១ បញ្ជីឈ្មោះក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សាវាយតម្លៃ
តារាងទី២ ចំណាត់ថ្នាក់គម្រោងដែលតម្រូវឱ្យវាយហេតុវាយតម្លៃប៉ះពាល់បរិស្ថាន

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហា

មនុស្សយើងកើតមកមិនអាចរស់នៅដោយគ្មានធម្មជាតិនោះទេ យ៉ាងហោចណាស់យើងក៏ត្រូវការទឹក អុកស៊ីសែនសម្រាប់ដកដង្ហើម និងអាកាសធាតុសមស្របសម្រាប់រស់នៅ។ មិនតែប៉ុណ្ណោះ ការអភិវឌ្ឍក៏ត្រូវការនូវធនធានធម្មជាតិមួយចំនួនដែលជាវត្ថុធាតុដើមផងដែរ។

ជាក់ស្ដែង ប្រទេសកម្ពុជាត្រូវបានគេចាត់ទុកជាប្រទេសមួយ ដែលមានធនធានធម្មជាតិដ៏សំបូរបែប និងជាប្រទេសដែលមានអាកាសធាតុអំណោយផលផងដែរ។ ធនធានធម្មជាតិទាំងនោះរួមមាន ព្រៃឈើ ផ្លូវទឹក រុក្ខជាតិ សត្វព្រៃ រ៉ែ ថាមពល ព្រមទាំងឧស្សាហកម្មនិស្សារណកម្ម។ ប្រមាណជាបីភាគបួននៃប្រជាជនកម្ពុជាសុទ្ធសឹងតែជាកសិករ និងរស់នៅតាមតំបន់ជនបទដែលពួកគេបានពឹងអាស្រ័យយ៉ាងខ្លាំងលើធនធានធម្មជាតិដ៏សំបូរបែបទាំងនោះ។ ដូច្នេះហើយ ការគ្រប់គ្រងនិងប្រើប្រាស់ធនធានធម្មជាតិអោយបានសមស្រប គឺជាកត្តាសំខាន់ណាស់សម្រាប់រដ្ឋាភិបាលកម្ពុជាក្នុងការជួយសម្រួលដល់ការរស់នៅរបស់ប្រជាជន។

មិនតែប៉ុណ្ណោះ ចាប់តាំងពីទសវត្សឆ្នាំ១៩៩០មក ប្រទេសកម្ពុជាបានចាប់ផ្ដើមការអភិវឌ្ឍប្រទសជាតិ និងព្យាយាមទាក់ទាញវិនិយោគទុនបរទេសយ៉ាងខ្លាំង។ លើសពីនេះ កម្ពុជាក៏បានប្រើប្រាស់នូវធនធានធម្មជាតិមួយចំនួនដើម្បីបម្រើឱ្យការអភិវឌ្ឍផងដែរ ដូចជា ការធ្វើអាជីវកម្មរ៉ែ ការសាងសង់វារីអគ្គិសនីជាដើម -ល-។

ពិសេសជាងនេះទៅទៀត កំណើនសេដ្ឋកិច្ចរបស់កម្ពុជាមានប្រមាណជាង៧%ក្នុងមួយឆ្នាំជិតពីរទសវត្សមកហើយ។ សព្វថ្ងៃនេះយើងឃើញថាសំណង់អគារ រោងចក្រ សហគ្រាស គម្រោងអភិវឌ្ឍន៍និងគម្រោងសាងសង់ដ៏ទៃទៀត កំពុងតែរីករាលដាលស្ទើរគ្រប់ទីកន្លែងនៃប្រទេសកម្ពុជា។ ថ្វីត្បិតតែការកើនឡើងនេះមានផលល្អដល់កំណើនសេដ្ឋកិច្ចនៃប្រទេសកម្ពុជា ប៉ុន្តែទោះជាយ៉ាងនេះក្ដីទាំងការសាងសង់ និងដំណើរការនៃរោងចក្រសហគ្រាសគ្រប់ទីកន្លែងសុទ្ធតែមានផលប៉ះពាល់ដល់បរិស្ថាន សុខុមាលភាពនៃបុគ្គលិក និងប្រជាជននៅជុំវិញនោះ ប្រសិនបើមិនមានការសាងសង់ឱ្យត្រូវតាមស្តង់ដារ រឺមិនបានពិនិត្យពិច័យពីការប៉ះពាល់អោយបានច្បាស់លាស់។

ទាំងនេះហើយសុទ្ធសឹងតែជាបញ្ហាដែលធ្វើអោយសាធារណជនមានការព្រួយបារម្ភជាខ្លាំង។ ម្យ៉ាងទៀត ប្រសិនបើមានការបំពុលខ្លាំងលើសកម្រិតទៀតសោត ដែលចេញពីសំណង់ ឬអាជីវកម្មទាំងនោះ វាពិតជាមានផលអាក្រក់យ៉ាងខ្លាំងដល់បរិស្ថាន ព្រមទាំងការអភិវឌ្ឍរបស់

ប្រទេសកម្ពុជាទៅថ្ងៃអនាគត។ ជាក់ស្តែងណាស់ អ្នកសេដ្ឋកិច្ច ក៏ដូចជាថ្នាក់ដឹកនាំប្រទេសមួយតែងតែចង់បាននូវការអភិវឌ្ឍដែលមានភាពយូរអង្វែង និងផ្តល់ភាពងាយស្រួលដល់ការរស់នៅរបស់ប្រជាជន។ ហើយក្នុងនាមយើងខ្ញុំជាអ្នកសិក្សាសេដ្ឋកិច្ច យើងខ្ញុំពិតជាចង់បាននូវចីរភាពក្នុងការអភិវឌ្ឍ ដែលជាការអភិវឌ្ឍនៅពេលនេះ មិនផ្តល់ផលវិបាកដល់ការអភិវឌ្ឍនិងការរស់នៅនាពេលអនាគត។ ហេតុនេះហើយទើបយើងខ្ញុំបានសម្រេចជ្រើសរើសប្រធានបទ **តួនាទីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា** មកធ្វើការសិក្សា។

## ២. ចំណោទបញ្ហា

ដោយសារតែឃើញមាននូវការកកើតឡើងនៃការអភិវឌ្ឍនៅកម្ពុជាដូចខាងលើ ហេតុនេះហើយដែលនាំអោយសាធារណៈជន ព្រមទាំងរូបយើងខ្ញុំផងដែរចេះតែមានក្តីព្រួយបារម្ភ និងសំណួរចោទសួរដូចជា៖

- តើរដ្ឋាភិបាលកម្ពុជាមានបានគិតគូរពីបញ្ហាបរិស្ថាននេះទេ?
- តើរដ្ឋាភិបាលកម្ពុជាកំពុងធ្វើអ្វីខ្លះពាក់ព័ន្ធនឹងបញ្ហានេះ?
- តើគម្រោងសាងសង់ទាំងអស់ត្រូវបានត្រួតពិនិត្យទាក់ទងនឹងការបំពុលបរិស្ថានទេ?
- តើរដ្ឋាភិបាលកម្ពុជានឹងធ្វើយ៉ាងណា ដើម្បីទទួលបានទាំងការអភិវឌ្ឍ និងបរិស្ថានល្អ?
- តើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបានរួមចំណែកអ្វីខ្លះក្នុងការអភិវឌ្ឍប្រទេសកម្ពុជា?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ដើម្បីដោះស្រាយចម្ងល់នៃបញ្ហាខាងលើនេះ ក្រុមយើងខ្ញុំបានរកឃើញថានាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន កំពុងធ្វើការពាក់ព័ន្ធនឹងបញ្ហាទាំងនេះ។ មិនតែប៉ុណ្ណោះ ដើម្បីផ្សារភ្ជាប់នឹងជំនាញរបស់យើង ដែលនាំអោយយើងខ្ញុំលើកយកប្រធានបទ **តួនាទីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជា** មកធ្វើការស្រាវជ្រាវ និងលម្អិត។

ជារួម ការស្រាវជ្រាវនេះមានគោលបំណងដូចជា៖

- ស្រាយចម្ងល់របស់សាធារណៈជនទាក់ទងនឹងបញ្ហាបរិស្ថាន
- បង្ហាញពីនីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- រំលេចពីសារៈសំខាន់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលមានផលល្អដល់ការអភិវឌ្ឍសេដ្ឋកិច្ច។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានវិសាលភាពធំទូលាយគ្រប់ដណ្តប់រាល់គម្រោងទាំងអស់ ដែលត្រូវបានបែងចែកជាបួនវិស័យគឺ វិស័យឧស្សាហកម្មនិងសុខាភិបាល វិស័យរ៉ែនិងថាមពល វិស័យកសិកម្មនិងធនធានទឹក និងវិស័យហេដ្ឋារចនាសម្ព័ន្ធនិងទេសចរណ៍។ ដោយហេតុនេះហើយ ដើម្បីឱ្យមានភាពច្បាស់លាស់ ក្រុមនាងខ្ញុំបានសម្រេចចិត្តយកតែមួយផ្នែកគឺវិស័យឧស្សាហកម្មមកធ្វើការវិភាគ និងរកនូវសារៈសំខាន់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះដែលនាំអោយមានផលប្រយោជន៍ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។ មូលហេតុដែលយើងខ្ញុំជ្រើសយកវិស័យនេះ គឺដោយសារតែប្រភេទឧស្សាហកម្មសំបូរទៅដោយកាកសំណល់មានទាំងរឹង រាវ និងឧស្ម័ន ដែលបង្កជាផលប៉ះពាល់ដល់បរិស្ថានច្រើន។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីសម្រេចលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ យើងខ្ញុំបានប្រើវិធីសាស្ត្រស្រាវជ្រាវពីរគឺ៖

- ការស្រាវជ្រាវគោល (Primary Research): គឺជាការស្រាវជ្រាវដោយផ្ទាល់ ដោយចុះយកឯកសារពាក់ព័ន្ធផ្ទាល់ពីក្រសួងបរិស្ថាន ពោលគឺនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន(EIA)នេះតែម្តង។ មួយវិញទៀត បូករួមទាំងការធ្វើបទសម្ភាសន៍ជាមួយលោកអនុប្រធាននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងលោកប្រធានការិយាល័យស្រាវជ្រាវ និងបណ្តុះបណ្តាល។
- ការស្រាវជ្រាវបន្ថែម (Secondary Research): គឺជាការសិក្សាស្រាវជ្រាវដោយប្រយោលតាមរយៈការរកឯកសារតាមប្រព័ន្ធអ៊ិនធឺណិតរឺគេហទំព័រផ្សេងៗ ការពិនិត្យមើលសៀវភៅនិក្ខេបបទរៀមច្បងនៅក្នុងបណ្ណាល័យ និងឯកសារដែលធ្លាប់រៀនកន្លងមកផងដែរ។

## ៦. សារសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃការស្រាវជ្រាវលើប្រធានបទនេះគឺ៖

- យល់ដឹងពីទ្រឹស្តីនៃការអភិវឌ្ឍ ដែលផ្សារភ្ជាប់ទៅនឹងបរិស្ថាន
- យល់ដឹងពីការបំពុលបរិស្ថាននៅកម្ពុជា
- ដឹងពីតួនាទីរបស់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- ដឹងពីគម្រោងដែលត្រូវវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- ដឹងពីសារៈសំខាន់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមកលើនិរន្តរភាពសេដ្ឋកិច្ច និងបរិស្ថាន

- កំណត់រកចំណុចខ្សោយ និងរកវិធានការដោះស្រាយ
- ផ្តល់ជាឯកសារសម្រាប់អ្នកសិក្សាស្រាវជ្រាវ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងកិច្ចការស្រាវជ្រាវបែបសារណាមួយនេះ ក្រុមយើងខ្ញុំបានបែងចែកជាប្រាំមួយជំពូកដែលមិនរាប់បញ្ចូលសេចក្តីផ្តើម និងសេចក្តីសន្និដ្ឋានឡើយ។

ចំណងជើងជំពូកទាំងប្រាំមួយនោះរួមមាន៖

- ជំពូកទី១ : រំលឹកទ្រឹស្តី
- ជំពូកទី២ : បរិស្ថាន និងការអភិវឌ្ឍនៅកម្ពុជា
- ជំពូកទី៣ : នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន(EIA)
- ជំពូកទី៤ : នីតិវិធីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- ជំពូកទី៥ : តួនាទីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមកលើការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា
- ជំពូកទី៦ : បញ្ហាប្រឈម និងដំណោះស្រាយ។

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១. ទស្សនៈទាននៃសេដ្ឋកិច្ច

### ១.១.១. និយមន័យ

សេដ្ឋកិច្ច គឺជាវិទ្យាសាស្ត្រសង្គមដែលជាប់ទាក់ទងជាមួយការផលិត ការបែងចែក និងការប្រើប្រាស់ទំនិញនិងសេវាកម្ម។ វាសិក្សាពីបុគ្គល អាជីវកម្ម រដ្ឋាភិបាល និងជាតិថាតើត្រូវការសម្រេចចិត្តបែបណាទៅលើការបែងចែកធនធានដើម្បីបំពេញនូវសេចក្តីត្រូវការ និងសេចក្តីចង់បានរបស់ពួកគេ ហើយព្យាយាមកំណត់ថាតើក្រុមទាំងនេះគួរតែរៀបចំ និងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងបែបណាដើម្បីទទួលបាននូវទិន្នផលអតិបរមា។

ជាទូទៅសេដ្ឋកិច្ចអាចបំបែកចេញជាពីរគឺ ម៉ាក្រូសេដ្ឋកិច្ច និងមីក្រូសេដ្ឋកិច្ច។ ម៉ាក្រូសេដ្ឋកិច្ចគឺជាការយកចិត្តទុកដាក់ទៅលើឥរិយាបថនៃសេដ្ឋកិច្ចសរុប រីឯមីក្រូសេដ្ឋកិច្ច គឺផ្តោតទៅលើអ្នកប្រើប្រាស់បុគ្គល។

សេដ្ឋកិច្ចគឺជាការសិក្សាអំពីរបៀបប្រើប្រាស់ធនធានកម្រសម្រាប់ការផលិត ការចែកចាយ និងការប្រើប្រាស់ទាំងជាលក្ខណៈបុគ្គលនិងជារួម។

សេដ្ឋកិច្ចបានយកចិត្តទុកដាក់លើប្រសិទ្ធក្នុងការផលិតនិងការផ្លាស់ប្តូរ និងប្រើប្រាស់គំរូ និងការសន្មត់ផ្សេងៗដើម្បីបង្កើតការលើកទឹកចិត្ត និងគោលនយោបាយដែលអាចធ្វើឲ្យមានប្រសិទ្ធភាពអតិបរមា។

សេដ្ឋវិទូបានបង្កើត និងផ្សព្វផ្សាយសូចនាករសេដ្ឋកិច្ចជាច្រើន ដើម្បីជួយក្នុងការសិក្សាសេដ្ឋកិច្ច។ ទាំងនេះក៏អាចមានប្រយោជន៍ដល់វិនិយោគិនផងដែរក្នុងការវិនិច្ឆ័យថាតើលក្ខខណ្ឌសេដ្ឋកិច្ចនឹងផ្លាស់ប្តូរទីផ្សាររបៀបណា និងដើម្បីណែនាំការសម្រេចចិត្តការវិនិយោគ។

### ១.១.២. ការយល់ឃើញអំពីសេដ្ឋកិច្ច

ការកត់ត្រាសេដ្ឋកិច្ចដំបូងគេគឺនៅក្នុងសតវត្សទី៨មុនគ.ស ដោយលោកហ៊ីស៊ីអ៊ីត (Hesiod) គឺជាកសិករជនជាតិក្រិច ដែលលោកបានសរសេរថា ពលកម្ម វត្ថុធាតុដើម និងពេលវេលាត្រូវធ្វើការបែងចែកយ៉ាងមានប្រសិទ្ធភាពដើម្បីយកឈ្នះភាពខ្វះខាត។ ប៉ុន្តែការកឃើញសេដ្ឋកិច្ចរបស់លោកខាងលិចបែបសម័យទំនើបបានកើតមានជាយូរមកហើយដែរ និងត្រូវបានបោះពុម្ពផ្សាយ

នៅឆ្នាំ១៧៧៦ ដោយលោកអាដាមស្មីធ (Adam Smith) ដែលជាសេដ្ឋវិទូជនជាតិស្កុតលែន (Scottish)។[1]

គោលការណ៍ (និងបញ្ហា) នៃសេដ្ឋកិច្ចគឺថាមនុស្សមានសេចក្តីត្រូវការគ្មានដែនកំណត់ ខណៈពេល ដែលពួកគេរស់នៅក្នុងពិភពលោកដែលមានធនធានមានកំណត់។ សម្រាប់ហេតុផលនេះ ទស្សនៈប្រសិទ្ធភាពនិងផលិតភាពត្រូវបានកាន់កាប់ដោយសេដ្ឋវិទូ។ ពួកគេបានអះអាងថាការបង្កើនផលិតភាព និងការប្រើធនធានឲ្យមានប្រសិទ្ធភាពអាចនាំទៅរកកម្រិតការរស់នៅខ្ពស់។

### ១.១.៣. ប្រភេទសេដ្ឋកិច្ច

ការសិក្សាសេដ្ឋកិច្ចត្រូវបានចែកជាពីរផ្នែកគឺៈ

- មីក្រូសេដ្ឋកិច្ច : ផ្តោតលើអ្នកប្រើប្រាស់បុគ្គលនិងអ្នកផលិតធ្វើការសំរេចចិត្តរបស់ពួកគេដោយរបៀបណា។ វារាប់បញ្ចូលទាំងមនុស្សម្នាក់ គ្រួសារមួយ អាជីវកម្មមួយ អង្គការរដ្ឋាភិបាលមួយ។ មីក្រូសេដ្ឋកិច្ចរាប់ពីលំនាំ ដែលបុគ្គលទាំងនេះធ្វើពាណិជ្ជកម្មជាមួយបុគ្គលមួយផ្សេងទៀតថាតើថ្លៃត្រូវបានរងឥទ្ធិពលពីការផ្គត់ផ្គង់ និងតម្រូវការរបស់ទំនិញរបៀបណា។ វាក៏បានសិក្សាពីប្រសិទ្ធិភាពនិងការចំណាយដែលបានផ្សារភ្ជាប់ជាមួយនឹងការផលិតទំនិញនិងសេវាកម្ម របៀបនៃការបែងចែកកម្លាំងពលកម្ម និងការបម្រុងទុកភាពមិនប្រាកដប្រជានៃហានិភ័យ។
- ម៉ាក្រូសេដ្ឋកិច្ច : ជាការសិក្សាពីសេដ្ឋកិច្ចទាំងមូល។ វាអាចរាប់បញ្ចូលទាំងតំបន់ភូមិសាស្ត្រខុសគ្នា ប្រទេសមួយ ទ្វីបមួយ ឬសូម្បីតែពិភពលោកទាំងមូល។ ប្រធានបទដែលបានសិក្សារួមមាន គោលនយោបាយសារពើពន្ធនិងរូបិយវត្ថុរបស់រដ្ឋាភិបាល អត្រាគ្មានការងារធ្វើ ដែលកំណើននេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈការផ្លាស់ប្តូរនៅក្នុងផលិតផលក្នុងស្រុកសរុប(GDP) និងវដ្តអាជីវកម្ម ដែលបង្កឲ្យមាននូវការរីកចម្រើន ការកើនឡើងយ៉ាងលឿន ការធ្លាក់ចុះ និងវិបត្តិសេដ្ឋកិច្ច។

[1] JIM CHAPPELOW, Economics: overview, types, and economic indicators, (2019), https://www.investopedia.com/terms/e/economics.asp, (ចូលទស្សនាថ្ងៃទី៩ ឧសភា ២០១៩)។

## ១.២. ការអភិវឌ្ឍសេដ្ឋកិច្ច

### ១.២.១. និយមន័យ

ការអភិវឌ្ឍសេដ្ឋកិច្ចគឺជាលំនាំនៃប្រទេសមានចំណូលទាប ខិតខំវិវត្តន៍ខ្លួនទៅជាប្រទេសដែលមានចំណូលខ្ពស់ និងមានឧស្សាហកម្មទំនើប។ ពេលខ្លះគេនិយាយថាការអភិវឌ្ឍសេដ្ឋកិច្ចស្រដៀងទៅនឹងកំណើនសេដ្ឋកិច្ច ប៉ុន្តែតាមពិតវាមិនមែនបែបនោះទេ។ កំណើនសេដ្ឋកិច្ចគ្រាន់តែជាផ្នែកមួយនៃការអភិវឌ្ឍសេដ្ឋកិច្ចតែប៉ុណ្ណោះ។ ជាក់ស្តែងកំណើនសេដ្ឋកិច្ច គឺនិយាយតែលើការកើនឡើងនៃផលិតផលសរុបក្នុងស្រុក(GDP) ប៉ុន្តែទ្រឹស្តីនៃការអភិវឌ្ឍសេដ្ឋកិច្ចវិញ គឺសំដៅដល់កំណើននៃការផលិត(កំណើនGDP) ព្រមទាំងការបង្កើននូវវិបុលភាព និងសុខុមាលភាពប្រជាជនផងដែរ។ វិបុលភាព និងសុខុមាលភាពប្រជាជនសំដៅដល់ភាពពេញចិត្ត ដែលរួមមានជីវភាព ភាពមានការងារធ្វើ សន្តិសុខសង្គម សិទ្ធសេរីភាព សុខភាព និងបរិស្ថានជុំវិញផងដែរ។

### ១.២.២. លំនាំដើមនៃការអភិវឌ្ឍសេដ្ឋកិច្ច

នៅក្នុងកំឡុងពេលក្រោយសង្គ្រាមលោកលើកទី២ ការអភិវឌ្ឍន៍សេដ្ឋកិច្ចបានក្លាយជារឿងដំបូងដែលពេញនិយមជាងគេ។ ក្រោយពីបញ្ចប់សង្គ្រាម មានប្រទេសជាច្រើនបានខូចខាតនូវហេដ្ឋារចនាសម្ព័ន្ធក្នុងស្រុក បាត់បង់ធនធានមនុស្ស ខាតបង់ចំណូលជាតិ ហើយទីផ្សារមិនមានដំណើរការផងដែរ។ ក្នុងពេលនោះសេដ្ឋកិច្ចរបស់ប្រទេសមួយចំនួនក៏បានធ្លាក់ចុះ និងជំពាក់បំណុលគេទៀតផង។ ហេតុនេះហើយ បណ្តាប្រទេសទាំងអស់បានខិតខំស្តារប្រទេសទាំងផ្នែកសេដ្ឋកិច្ច និងការកសាងហេដ្ឋារចនាសម្ព័ន្ធឡើងវិញ។ ម្យ៉ាងវិញទៀត ពេលនោះមិនគ្រាន់តែជាពេលដែលបញ្ចប់សង្គ្រាមលោកលើកទី២ តែវាក៏ជាពេលដែលពួកអ៊ឺរ៉ុបបានចាប់ផ្តើមបញ្ចប់នូវអាណានិគមរបស់ខ្លួនទៅលើប្រទេសក្រោមអាណានិគម។ ក្រោយពីប្រទេសក្រោមអាណានិគមទាំងឡាយទទួលបានឯករាជ្យ ប្រទេសទាំងអស់នោះក៏បានខិតខំប្រឹងប្រែងអភិវឌ្ឍន៍ប្រទេសរបស់ខ្លួន ដោយប្រើប្រាស់ធនធានដែលខ្លួនមាន និងហេដ្ឋារចនាសម្ព័ន្ធដែលបានពីការកសាងរបស់ពួកអាណានិគម។[2]

### ១.២.៣. ការវាស់វែងការអភិវឌ្ឍសេដ្ឋកិច្ច

ដូចដែលបានរៀបរាប់អំពីនិយមន័យខាងលើ ការអភិវឌ្ឍសេដ្ឋកិច្ចគេមិនត្រឹមតែនិយាយពីកំណើនផលិតផលសរុបក្នុងស្រុក(GDP)ប៉ុណ្ណោះទេ។ ជាក់ស្តែងណាស់គេមើលទៅលើថាតើ

---

[2] Economics Principles, (n/d), https://www.soas.ac.uk/cedep-demos/000_P542_EP_K3736-Demo/module/ topindex.htm, (ចូលទស្សនាថ្ងៃទី៤ ឧសភា ២០១៩)។

ជាពលរដ្ឋទទួលបានអ្វីខ្លះក្នុងការរស់នៅរបស់ពួកគេ។ ការអភិវឌ្ឍន៍សេដ្ឋកិច្ច តែងតែមានបំណង ធ្វើអោយប្រសើរឡើងនៃស្តង់ដារនៃការរស់នៅ និងបំពេញចិត្តរបស់ប្រជាពលរដ្ឋ។[3]

៥ចំណុចខាងក្រោមនេះ ជាចំណុចសំខាន់សរាប់ការវាស់វែងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសមួយ៖

- ចំណូលក្នុងពលរដ្ឋម្នាក់ (GDP per Capita)
- កាត់បន្ថយភាពក្រីក្រ
- កាត់បន្ថយគម្លាតរវាងអ្នកមាន និងអ្នកក្រ
- សិទ្ធស្មើគ្នារវាងអ្នកមាន និងអ្នកក្រ
- ស្តង់ដារនៃការរស់នៅរបស់ប្រជាជន។

## ១.៣. អ្វីទៅជាបរិស្ថាន

### ១.៣.១. និយមន័យ

វិទ្យាសាស្ត្របរិស្ថាន ឬការសិក្សាបរិស្ថាន គឺជាមុខវិជ្ជាមួយសំរាប់សិក្សាអំពីអ្វីៗដែលនៅជុំវិញខ្លួនយើង និងជាការសិក្សាពីទំនាក់ទំនងនៃសកម្មភាពមនុស្សដែលមានឥទ្ធិពលលើបរិស្ថានទាំងបរិស្ថានមានជីវិត និងគ្មានជីវិត (Raven,១៩៩៣)។

បរិស្ថានថាជាអ្វីៗទាំងអស់ដែលមានជីវិត ឬគ្មានជីវិតដែលនៅជុំវិញខ្លួនយើង ដោយរាប់បញ្ចូលទាំងសកម្មភាពរបស់មនុស្សផងដែរ។

### ១.៣.២. ចំណាត់ថ្នាក់បរិស្ថាន

ពាក្យថាបរិស្ថានដើម្បីអោយវាស្របតាមការសិក្សាបរិស្ថានយើងអាចបែងចែកនិយមន័យបរិស្ថានជាពីរផ្នែកធំៗគឺ៖ ១.បរិស្ថានធម្មជាតិ, ២.បរិស្ថានសង្គមវប្បធម៌ (CEAT, UNDP, OPS, ១៩៩៤)។

- បរិស្ថានធម្មជាតិ: ធម្មជាតិកើតឡើងដោយឯកឯង ដែលមិនបានបង្កើតឡើងដោយមនុស្ស។ បរិស្ថានគ្មានជីវិតមានដូចជា ស្ទឹង ទន្លេ បឹងសមុទ្រ មហាសមុទ្រ ភ្នំ និងកត្តាអាកាសធាតុរួមបញ្ចូលទាំង សីតុណ្ហភាព សំណើម ភ្លៀង ការធ្លាក់ព្រិល ខ្យល់.....។ល។ ចំណែកឯពពួកសត្វ សត្វស្លាប រុក្ខជាតិ ដើមឈើជាផ្នែកនៃបរិស្ថានមានជីវិត។

[3] Economishelp, Difference between economic growth and development, (2015), https://www.economicshelp.org/blog/1187 /development/economic-growth-and-development/ ចូលទស្សនាថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៩។

- បរិស្ថានសង្គម-វប្បធម៌: គឺអ្វីៗដែលមាននៅជុំវិញយើង ហើយត្រូវបានបង្កើតឡើងដោយមនុស្ស។ វាត្រូវបានចែកជាពីរផ្នែក: ផ្នែកគ្មានមានជីវិត និងមានជីវិត។ ផ្នែកមានជីវិតនៃបរិស្ថានសង្គម-វប្បធម៌រួមមានទាំងសំណង់ ផ្លូវថ្នល់ ស្ពាន ទីក្រុង ភូមិស្ថាន ធារាសាស្ត្រ ប្រឡាយទឹក រោងចក្រ សង្គមសាំញ៉ាំ និងសកម្មភាពសង្គមរស់នៅដែលកើតឡើងពីវប្បធម៌។

### ១.៣.៣. បញ្ហាបរិស្ថាននៅលើពិភពលោក

នៅលើពិភពលោកទាំងក្នុងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ បញ្ហាបរិស្ថាន គឺជាការព្រួយបារម្ភចម្បងមួយដែលប្រជាជន និងរាជរដ្ឋាភិបាលនានាកំពុងតែប្រឈមមុខ។ បញ្ហាទាំងនេះរួមមាន: កំណើនប្រជាជន ការដុតឥន្ធនៈ ផូស៊ីល ការបំផ្លាញព្រៃឈើ ការបំពុលទឹក ការបំពុលខ្យល់ ការបំពុលដី ការចាក់សំណល់ចោល ភាពក្រីក្រ និងការបាត់បង់ប្រភេទសត្វ និងរុក្ខជាតិនានា។ ពិតមែនតែមានលក្ខណៈពិសេសសំរាប់តំបន់នីមួយៗក្តីក៏បញ្ហាបរិស្ថានដែលទ្វីបអាស៊ី កំពុងតែជួបប្រទះមានភាពស្រដៀងគ្នាទៅនឹងបញ្ហាបរិស្ថានដែលពិភពលោកទាំងមូលកំពុងតែប្រឈមមុខដែរ។[4]

ក. បញ្ហាកំណើនប្រជាជនលើបរិស្ថាន

- ប្រជាជននៅលើពិភពលោកបានកើនយ៉ាងឆាប់រហ័សពី២,២ពាន់លាននៅឆ្នាំ១៩៥០ ទៅ ៥.៨៤ពាន់លាននៅពាក់កណ្តាលឆ្នាំ១៩៩៧។ ចំនួននេះត្រូវបានកើនឡើងដល់ប្រមាណ ៧.៦៣២ពាន់លាននៅឆ្នាំ២០១៨ ហើយគេប៉ាន់ស្មានថានឹងកើនដល់៨.០៣៦ពាន់លាននៅឆ្នាំ២០២៥។ ដោយសារតែចំនួនមនុស្សកើនឡើងទ្វេគុណគឺ៤៧ឆ្នាំ សម្រាប់អត្រាកំណើនបច្ចុប្បន្ន នោះចំនួនប្រជាជននៅលើពិភពលោកនឹងឡើងដល់១៥ពាន់លាននាក់នៅចុង សតវត្សទី២១។
- នៅទ្វីបអាស៊ីកំណើនប្រជាជន គឺការព្រួយបារម្ភធំមួយ នៅឆ្នាំ១៩៩៧ ចំនួនប្រជានជននៅអាស៊ីមាន៣,៥៥២លាននាក់ ហើយមានចំនួន៤,៥៤៥លាននាក់ ក្នុងឆ្នាំ២០១៨ ហើយ

---

[4] Army Institute Professor Ministry, មេរៀនបរិស្ថាន, (2016), http://www.armyinstitute.epizy.com/2016/12/02/%E1%9E%98%E1%9F%81%E1%9E%9A%E1%9F%80%E1%9E%93%E1%9E%94%E1%9E%9A%E1%9E%B7%E1%9E%9F%E1%9F%92%E1%9E%90%E1%9E%B6%E1%9E%93/?i=1, ចូលដកស្រង់ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩។

ជាមួយនឹងអត្រាកំណើនបច្ចុប្បន្ន រយៈពេលដែលចំនួនមនុស្សកើនទ្វេគុណ គឺតែ៥៥ឆ្នាំប៉ុណ្ណោះ។

កំណើនប្រជាជននៅទ្វីអាស៊ីមានន័យថា តំរូវការធនធាននានាក៏កើនឡើងដែរ ដូចជា ត្រីសាច់ ធញ្ញជាតិ ផ្លែឈើ បន្លែ ។ល។ ដើម្បីរកចំណីអាហារនេះ គេត្រូវការចាំបាច់នូវដីដាំដំណាំមានជីជាតិ វាលស្មៅចិញ្ចឹម សត្វ និង នេសាទ។ មនុស្សជាច្រើនត្រូវការអុសដើម្បីចំអិនអាហារ និងរានព្រៃដើម្បីធ្វើជម្រកផងដែរ។ ពួកគេក៏ត្រូវការទឹកសម្រាប់ផឹក លាងសំអាត នចំអិនអាហារ ស្រោចដំណាំ និងចិញ្ចឹមសត្វ។ មិនតែប៉ុណ្ណោះគេក៏ត្រូវការកន្លែងសំរាប់រស់នៅ សំភារៈសាងសង់ និងធនធានធម្មជាតិសំរាប់បំរើសេចក្តីត្រូវការក្នុងកសិកម្ម ពាណិជ្ជកម្ម និងឧស្សាហកម្មរបស់គេទៀតផង។ នៅពេលដែលប្រជាជនកាន់តែច្រើន គេក៏ជួបការលំបាកក្នុងការប្រយុទ្ធនឹងជំងឺកង្វះចំណីអាហារ និងភាពក្រីក្រ ព្រមទាំងការលំបាកជាទូទៅក្នុងការលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជន។

ហេតុផលប៉ះពាល់បរិស្ថានជាអនុគមន៍ទៅនឹងចំនួនប្រជាជន ភាពសំបូរហូរហៀរ និងបច្ចេកវិទ្យា។ នៅប្រទេសកំពុងអភិវឌ្ឍន៍ កំណើនប្រជាជនគឺជាមូលហេតុនាំមកនូវការប្រែប្រួលក្នុងការប្រើប្រាស់ដី។ នៅក្នុងប្រទេសអ្នកមានវិញ កំរិតនៃការប្រើប្រាស់សំរាប់មនុស្សម្នាក់បានក្លាយជាការគំរាមកំហែងយ៉ាងធំដល់បរិស្ថានពិភពលោកពោល គឺដូចគ្នានឹងកំណើនប្រជាជនដែរ។

ខ. ការបាត់បង់ស្ថានប្រព័ន្ធ(Ecosystem) និងការផុតពូជប្រភេទនានា

- ជារៀងរាល់ថ្ងៃ ការបំផ្លាញព្រៃឈើ និងជំរកនានាបណ្តាលឱ្យផុតពូជប្រភេទសត្វ និងរុក្ខជាតិនានាចំនួនរាប់រយប្រភេទ។ ព្រៃត្រូពិចកំពុងរងគ្រោះថ្នាក់ខ្លាំងជាងគេ។ ព្រៃប្រភេទនេះគ្របដណ្តប់លើផ្ទៃដីពិភពលោកតែប្រមាណ៧%ប៉ុណ្ណោះ តែវាផ្តល់ជំរកដល់សត្វនិងរុក្ខជាតិប្រមាណ៥០% ទៅ៧០% នៃប្រភេទសត្វទាំងអស់នៅលើពិភពលោក។
- ព្រៃឈើគ្របដណ្តប់លើផ្ទៃដីពិភពលោកប្រមាណមួយភាគបី។ នៅតំបន់អាស៊ី និងតំបន់ប៉ាស៊ីភិច ព្រៃត្រូពិចគ្រប់ ដណ្តប់លើផ្ទៃដីប្រមាណ៣០០លានហិចតា ហើយផ្តល់នូវផលិតផល ឈើត្រូពិចសំរាប់នាំចេញប្រមាណ៧០% នៃបរិមាណឈើត្រូពិចនាំចេញទាំងអស់នៅលើពិភពលោក ក៏ប៉ុន្តែបច្ចុប្បន្ននេះព្រៃត្រូពិចកំពុងតែបាត់បង់ក្នុងអត្រាប្រកាសអាសន្នមួយ។
- សំណឹកដី គឺជាបញ្ហាបរិស្ថានធំទីពីរដែលទាក់ទងទៅនឹងដីនៅទ្វីបអាស៊ី។ រហោស្ថានកម្មជាបញ្ហាសំខាន់មួយ នៅអាស៊ីដែលតាមនិយមន័យ គឺជាការថយចុះនូវផលិតភាពរបស់ដី

ដោយសារមូលហេតុមួយឬច្រើន ដែលរួមមានការបំផ្លាញព្រៃឈើ សំណឹកដី ដីជាំទឹក អំបិលកម្ម អំពើគីមី និងការគ្រប់គ្រងដីធ្លីពុំបានត្រឹមត្រូវ។

- នៅតំបន់អាស៊ី និងតំបន់ប៉ាស៊ីភិចមានសត្វសំបូរបែបជាងគេនៅលើពិភពលោក។ មូលហេតុចំបងនៃការផុតពូជនៃប្រភេទសត្វនានា គឺបណ្ដាលមកពីការបំផ្លាញជំរករបស់វាដោយផ្ទាល់ ឬដោយប្រយោល។

គ. នគរូបនីយកម្ម(Urbanization)

អត្រាកំណើនប្រជាជននៅទ្វីអាស៊ី គឺជាបញ្ហាបរិស្ថានដ៏ធំមួយ។ អត្រាកំណើនប្រជាជនទីក្រុងមានពីរដងខ្ពស់ជាងអត្រាកំណើនប្រជាជនទូទៅ។ នៅទ្វីបអាស៊ីមានមនុស្សប្រមាណ៣៣% រស់នៅទីក្រុង។ នៅពេលដែលរីកសាយនៃនគរូបនីយកម្ម គុណភាពនៃការផ្គត់ផ្គង់ទឹកនិងមធ្យោបាយបង្ហូរទឹកល្អសំអុយតែងតែចុះថយជាលំដាប់។ បញ្ហាបរិស្ថានសំខាន់ៗនៅទីក្រុងរួមមាន ភាពគ្មានអនាម័យ បញ្ហាផ្គត់ផ្គង់ទឹក ការបំពុលខ្យល់ ការបំពុលទឹក កង្វះខាត់ទីធ្លាចំហា កង្វះខាតកន្លែងសំរាក ចរាចរណ៍ចង្អៀត បញ្ហាទុកដាក់សំណល់ ។ល។

ភាពក្រីក្រមានឥទ្ធិពលផ្ទាល់ដល់សុខភាពមនុស្ស។ ការផ្គត់ផ្គង់ទឹកសំរាប់ផឹកនិងប្រើប្រាស់ពុំបានសមស្រប និងភាពខ្វះខាតបរិក្ខាការពារអនាម័យ គឺជាទិដ្ឋភាពយ៉ាងសំខាន់ នៃទំនាក់ទំនងរវាងភាពក្រីក្រ និងសុខភាព។ ក្រៅពីទឹក ខ្យល់ពុលក៏អាចបណ្ដាលឱ្យមានបញ្ហាសុខភាពដែរ ជាពិសេសនៅពេលដែលវាមិនស្អាត។ កំណើនការពុលខ្យល់នាំកើតជំងឺផ្លូវដង្ហើម និងជំងឺផ្សេងទៀតជាញឹកញាប់។

ឃ. ការបំពុលខ្យល់

ការបំពុលខ្យល់ គឺជាបញ្ហាបរិស្ថានមួយក្នុងចំណោមដែលត្រូវគេយកមកពិភាក្សាច្រើនបំផុត។ បញ្ហាសុខភាពជាច្រើននៅទីក្រុង កើតឡើងបណ្ដាលមកពីការបំពុលខ្យល់។ ជាការពិតណាស់ដែលថាការបំពុលខ្យល់ គឺជាបញ្ហាដែលមាននៅកំរិតមូលដ្ឋាន ក៏ប៉ុន្តែវាបណ្ដាលមានបាតុភូតបីទៀត ដែលជាការព្រួយបារម្ភក្នុងកំរិតពិភព លោកគឺៈ

- ភ្លៀងអាស៊ីតៈ ចំហេះឥន្ធនៈផូស៊ីលនៅស្ថានីយអគ្គិសនី រោងចក្រ និងម៉ាស៊ីនយានយន្តបណ្ដាលឱ្យមានភ្លៀងអាស៊ីត។
- ការហិនហោចស្រទាប់អូសូនៈ សារធាតុគីមីមួយចំនួនដែលបញ្ចេញចោលទៅក្នុងបរិយាកាស ធ្វើឱ្យខូច ខាតស្រទាប់អូសូនដែលការពារមនុស្ស សត្វ និងរុក្ខជាតិ ពីកាំរស្មីស្វាយអុលត្រា (UV)។

– ការប្រែប្រួលអាកាសធាតុ (រួមទាំងការកើនឡើងកម្ដៅផែនដីផង) ចំហេះឥន្ទនៈផូស៊ីល និងការបំផ្លាញព្រៃឈើបានបន្ថែមឧស្ម័នកាបូនិច($CO_2$)ចូលក្នុងបរិយាកាស។ អ្នកវិទ្យាសាស្ត្រអាកាសធាតុជឿថា នៅពេលដែលកំហាប់ឧស្ម័នកាបូនិច និងឧស្ម័នមួយចំនួនទៀតកើនឡើងអាកាសធាតុពិភពលោកក៏ក្ដៅជាងមុន។

ង. ការទុកដាក់សំណល់រឹង

ការទុកដាក់សំណល់រឹង គឺជាបញ្ហាដែលចោទនៅគ្រប់ប្រទេស។ ប្រទេសជាច្រើនបានបន្សល់សំណល់ចេញពីលំនៅដ្ឋាន និងសំណល់ចេញពីរោងចក្រឧស្សាហកម្មនិងមន្ទីរពេទ្យ។ សំណល់ទាំងនេះបំពុលខ្យល់ ដី និងទឹកព្រោះប្រទេស និងសហគមន៍ភាគច្រើនពុំមានមធ្យោបាយទុកដាក់សំណល់ឱ្យមានសុវត្ថិភាពទេ។ នៅពេលគេដុតកាកសំណល់ឧស្ម័នពុល ក៏សាយភាយចូលទៅក្នុងខ្យល់។

ការចាក់ចោលសំណល់ប្រភេទខ្លះ អាចបណ្ដាលឱ្យមានគ្រោះថ្នាក់ខ្លាំងដល់សុខភាពសារធារណៈ ពីព្រោះសារធាតុអាស៊ីត និងសារធាតុសរីរាង្គដែលមិនអាចបំបែកធាតុបានត្រូវជ្រាបចូលទៅក្នុងដី ហើយបំពុលដីសម្រាប់ធ្វើកសិកម្ម និងកង្វក់ទឹកសំរាប់ប្រើប្រាស់។ ជាលទ្ធផលសំណល់បណ្ដាលឱ្យមានគ្រោះថ្នាក់ដល់សុខភាព។ សំណល់ត្រូវការទីកន្លែងទុកដាក់ត្រឹមត្រូវព្រោះវាបញ្ចេញក្លិនមិនល្អ។ អ្នកប្រើប្រាស់នៅបណ្ដាលប្រទេសឧស្សាហកម្មបានបញ្ចេញចោលនូវបរិមាណសំណល់ដ៏ច្រើន តែនៅប្រទេសកំពុងលូតលាស់គេមាន បញ្ហាផ្ទាល់របស់គេជាពិសេស គឺគេពុំទាន់មានបច្ចេកវិទ្យាដែលគេអាចទទួលយកបានសំរាប់ទុកដាក់សំណល់គីមីពុលប្រកបដោយសុវត្ថិភាពទេ ព្រោះតែខ្វះខាតនេះ វិធីសាស្ត្រដោះស្រាយនឹងការទុកដាក់ និងផ្ដល់នូវការរៀបចំទីលានចាក់សំរាមអនាម័យ និងការដុតដោយមានប្រសិទ្ធភាពខ្ពស់។ ការបំពុលដោយការរំលាយសារធាតុបំពុលក្នុងទឹកដែលបានចេញ ពីសំណល់រឹងនឹងបង្កើតជាសូលុយស្យុងដែលហៅថា ទឹក Leachate ដែលជ្រាបចូលទៅក្នុងទឹកក្រោមដី។ ម្យ៉ាងវិញទៀតវាអាចនឹងជាមូលហេតុផ្ដល់គ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ។ ឧទាហរណ៍: នៅបណ្ដាប្រទេសដែលមានប្រាក់ចំណូលទាបដូចជាកម្ពុជាយើងនេះ ដែលសព្វថ្ងៃកំពុងតែមានការព្រួយបារម្ភ។

ច. ការបំពុលទឹក(Water Pollution)

ការបំពុលទឹកសមុទ្រ និងទឹកសាប គឺជាបញ្ហាបរិស្ថានដ៏សំខាន់មួយ។ ស្ថានប្រព័ន្ធទឹកនៅក្រោមខ្សែទឹកពី តំបន់ទីក្រុង ឬកំពង់ផែឧស្សាហកម្ម តែងរងការបំពុលជាញឹកញាប់ដោយសារតែសំណល់ដែលពុំបានធ្វើប្រត្តិកម្ម ឬក៏ធ្វើប្រត្តិកម្មពុំត្រឹមត្រូវ។ សំណល់ពីលំនៅដ្ឋានជាសារធាតុ

បំពុលចំបងមួយ។ អាជីវកម្មរ៉ែ ការបូមភក់ ការលាង នាវាដឹកប្រេង និងគ្រោះថ្នាក់នាវា ក៏បណ្តាលឱ្យមានការបំពុលដែរ។ គេប៉ាន់ស្មានថា ប្រមាណ៨០% នៃជំងឺនានានៅប្រទេសកំពុងអភិវឌ្ឍន៍ មានមូលហេតុទាក់ទងនឹងការប្រើប្រាស់ទឹកមិនស្អាត និងអនាម័យមិនល្អ។ ប្រជាជននៅទ្វីអាស៊ីបានចាត់វិធានការវិជ្ជមានមួយចំនួន ដើម្បីកាត់បន្ថយឥទ្ធិពលនៃការបំពុលទឹក ដូចជាការកែលំអរអនាម័យ និងគុណភាពទឹកផឹក ការសាងសង់រោងចក្រប្រតិកម្ម ការត្រួតពិនិត្យ កែតំរូវសំណល់រាវបង្ហូរចេញ និងការដាំដើមឈើឡើងវិញដើម្បីបញ្ឈប់កំទេចកំណ។

ឆ. ការបំពុលដោយសូរសំលេង (Noise Pollution)

ជាញឹកញាប់ការបំពុលដោយសូរសំលេង គឺជាបញ្ហាបរិស្ថានចំបងនៅទីក្រុង ដែលប្រមូលផ្តុំទៅដោយរថយន្តផ្ទាល់ខ្លួន រថយន្តដឹកជញ្ជូន យន្តហោះ ស៊ីរ៉ែន ឧបករណ៍បំពងសំលេង ម៉ាស៊ីនភ្លើង ។ល។ សូរសំលេងទាំងនេះរំខានដល់មនុស្ស ហើយអាចធ្វើឱ្យមានការខ្សោយអស់កំលាំងខាងផ្លូវចិត្ត ការមួម៉ៅតប់ប្រមល់ និងការខូចខាតសោតវិញ្ញាណទៀតផង។

## ១.៤. ទំនាក់ទំនងបរិស្ថាន និងការអភិវឌ្ឍសេដ្ឋកិច្ច

### ១.៤.១. បរិស្ថានធម្មជាតិ និងកំណើនសេដ្ឋកិច្ច

យោងតាមអង្គការ OECD ( Organization of Economic Co-operation and Development) បានកំណត់ថាធនធានបរិស្ថានធម្មជាតិ ដែលហៅម្យ៉ាងទៀតថាមូលធនធម្មជាតិគឺជាកត្តាសំខាន់ណាស់ សំរាប់បម្រើអោយផលិតកម្មក្នុងវិស័យសេដ្ឋកិច្ច។ ក្នុងនោះគេគិតតាំងពីខ្យល់ ទឹក និងដីព្រមទាំងរ៉ែគ្រប់ប្រភេទ ដែលយើងទទួលបានពីផែនដី។[5]

បរិស្ថានធម្មជាតិបានចូលរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចតាមរយ:បណ្តាញ២សំខាន់ៗគឺ៖

- ដោយផ្ទាល់: មានន័យថា ធនធានធម្មជាតិចូលរួមដោយផ្ទាល់នៅក្នុងដំណើរការសេដ្ឋកិច្ច។
- ដោយប្រយោល: មានន័យថា ធនធានធម្មជាតិមានឥទ្ធិពលទៅលើផលិតភាពនៃកត្តាផលិតកម្ម។

កំណើនសេដ្ឋកិច្ចក៏កើតឡើងផងដែរតាមរយ:ទីកន្លែងដែលមានការផលិតកត្តាផលិតកម្មដោយមានការគាំទ្រទៅដល់បរិស្ថានស្អាត និងផ្តល់ផាសុខភាពដល់បរិស្ថានជុំវិញ។ ផ្ទុយទៅវិញ ប្រសិនបើឧស្សាហកម្មណាមួយមិនបានគិតគូដល់បញ្ហាបរិស្ថាន ពិតណាស់ឧស្សាហកម្មនោះនៅ

[5] Everett. T & others, Economics Growth and the Environment, (2010), https://assets.publishing.service.gov.uk/government/ uploads/system/uploads/attachmentdata/file/69195/pb13390-economic-growth-100305.pdf, ចូលទស្សនាថ្ងៃទី៣០ មេសា ២០១៩។

តែមានផលចំណេញ ប៉ុន្តែកត្តាផ្សេងទៀតនឹងទទួលរងផលប៉ះពាល់ផ្សេងៗដូចជា បញ្ហាសុខភាព របស់ប្រជាជនថយចុះ បម្រែបម្រួលអាកាសធាតុជាដើម ដែលអាចប៉ះពាល់ដល់ផលិតភាព ផលិតកម្មសំរាប់ឧស្សាហកម្មនោះ ហើយក៏ជាបញ្ហារបស់សាកលលោកដែរ។

### ១.៤.១.១. ធនធានធម្មជាតិចូលរួមដោយផ្ទាល់នៅក្នុងកំណើនសេដ្ឋកិច្ច

បរិស្ថានធម្មជាតិផ្តល់នូវវត្ថុធាតុដើមសម្រាប់ផលិតទំនិញ និងសេវាកម្មផ្សេងៗនៅក្នុង ដំណើរការផលិតកម្ម ដែលប្រើអោយវិស័យសេដ្ឋកិច្ច។

ធនធានធម្មជាតិដែលបម្រើអោយកត្តាផលិតកម្មដោយផ្ទាល់ចែកចេញជា២គឺ៖

- ធនធានមិនកើតឡើងវិញ: គឺជាធនធានធម្មជាតិដែលផ្តល់អោយមានកម្រិត ដែលងាយ នឹងបាត់បង់គ្រប់ពេលវេលា។ ធនធានទាំងនោះមានដូចជា ប្រេងឥន្ធនៈ រ៉ែ លោហធាតុ និង ធនធានធម្មជាតិជាមូលដ្ឋានមួយចំនួនទៀត ដែលប្រើសម្រាប់ផលិតថាមពល គ្រឿងយន្ត និងសម្ភារៈប្រើប្រាស់ផ្សេងៗ។
- ធនធានកើតឡើងវិញ: គឺជាធនធានធម្មជាតិដែលមានសមត្ថភាពកើតឡើងវិញ តាមរយៈ ដំណើរការធម្មជាតិ។ ទោះបីជាយ៉ាងណាក៏ដោយ ធនធានទាំងនេះអាចនឹងបាត់បង់ ផងដែរ ប្រសិនបើកម្រិតនៃការប្រើប្រាស់លឿនជាងកម្រិតនៃការកកើតឡើងវិញ។ ធនធាន កើតឡើងវិញមានដូចជា ព្រៃឈើ ជីវចម្រុះ ដែលចូលរួមដោយផ្ទាល់នៅក្នុងសកម្មភាព សេដ្ឋកិច្ច។

### ១.៤.១.២. ធនធានធម្មជាតិចូលរួមដោយប្រយោលនៅក្នុងកំណើនសេដ្ឋកិច្ច

ការចូលរួមដោយប្រយោលពីធនធានធម្មជាតិ ក៏មានសារៈសំខាន់ផងដែរនៅក្នុងដំណើរ ការសេដ្ឋកិច្ច។ កត្តាផលិតកម្មដោយប្រយោលបានផ្តល់អោយដោយសារប្រព័ន្ធអេកូឡូស៊ីជួយ សម្រួលដល់ដំណើការផលិតកម្ម ហើយវាក៏បាននាំងសម្រាប់ប្រឆាំងនឹងផលប៉ះពាល់បរិស្ថាន ដែលបានមកពីសកម្មភាពសេដ្ឋកិច្ច។

ការចូលរួមដោយប្រយោលនោះមានដូចជា៖

- ការទ្រទ្រង់ជីវិតសាកលលោក: ធនធានធម្មជាតិដែលផ្តល់ការទ្រទ្រង់ជីវិតសាកលលោក រួមមាន អាកាសធាតុ និង កម្រិតសមស្របនៃសារធាតុគីមីក្នុងបរិយាកាសនិងសមុទ្រ។
- ភាពទៀងទាត់នៃទឹក: វដ្តទឹកអាចទប់ទល់នឹងលំហូរជលសា និងកាត់បន្ថយភាពប្រែប្រួល នៃបរិស្ថាន។ ផ្តល់នូវការការពារទឹកជំនន់ ខ្យល់ព្យុះ និងទប់ស្កាត់ការបំផ្លាញផ្សេងៗពី គ្រោះធម្មជាតិ។

- ចម្រោះជាតិពុល: ធនធានធម្មជាតិបានដើរតួយ៉ាងសំខាន់ក្នុងការគ្រប់គ្រងការបំពុល និងការបន្សាបជាតិពុល ដូចជាដើមឈើបានស្រូបយកសារធាតុពុលពីខ្យល់ និងបញ្ចេញមកវិញនូវឧស្ម័នអុកស៊ីសែនជាដើម។
- រំលាយកាកសំណល់: ធម្មជាតិអាចផ្តល់នូវឃ្លាំងផ្ទុកកាកសំណល់ទាំងឡាយណាដែលមិនត្រូវបានកែច្នៃឡើងវិញ ហើយវាបានរំលាយនូវកាកសំណល់ទាំងនោះតាមពេលវេលាលឿនរឺឆាប់ អាស្រ័យនឹងប្រភេទកាកសំណល់។
- វដ្តនៃសារធាតុចិញ្ចឹម: ដំណើរការនៃប្រព័ន្ធអេកូឡូស៊ីផ្តល់នូវអត្ថប្រយោជន៍តាមរយៈការផ្ទុកការកែច្នៃ និងការទទួលបានសារធាតុចិញ្ចឹម ដែលចាំបាច់សម្រាប់ការលូតលាស់របស់រុក្ខជាតិ។

### ១.៤.២. បរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាព

ការអភិវឌ្ឍប្រកបដោយចីរភាព គឺជាការបំពេញនូវតម្រូវការរបស់ប្រជាជននៅពេលបច្ចុប្បន្ន ដោយមិនជះឥទ្ធិពលដល់ការលទ្ធភាពក្នុងការបំពេញតម្រូវការរបស់ប្រជាជននៅពេលអនាគត។ វាជាការខ្វល់ខ្វាយពីកំណើនសេដ្ឋកិច្ច ភាពគង់វង្សនៃបរិស្ថាន និងសុខុមាលភាពសង្គម។[6]

គោលការណ៍នៃការអភិវឌ្ឍប្រកបដោយចីរភាព ត្រូវបានបង្កើតឡើងដំបូងក្នុងឆ្នាំ១៩៨៧ ជាមួយនឹងការបោះពុម្ពផ្សាយរបាយការណ៍ Brundtland (Brundtland Report)។[7] នៅក្នុងរបាយការណ៍នោះបានរៀបរាប់ពីលទ្ធផលអវិជ្ជមានមកលើបរិស្ថាន ដែលកើតឡើងដោយសារកំណើនសេដ្ឋកិច្ច និងសកលភាវូបនីយកម្ម។ របាយការណ៍នោះក៏បានបញ្ជាក់បន្ថែមទៀតថាបញ្ហាទាំងមានប្រភពដើមមកពីឧស្សាហូបនីយកម្ម និងកំណើនប្រជាជន។

ជាការពិតណាស់ បរិស្ថានពិតជាឧបករណ៍សំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ពីព្រោះថាធនធានធម្មជាតិភាគច្រើនជាវត្ថុធាតុដើមសម្រាប់ផលិតជាផលិតផលប្រើប្រាស់ទាំងឡាយ។ ប៉ុន្តែ ធនធានធម្មជាតិទាំងនោះមានកម្រិត ហើយមួយចំនួនវានឹងបាត់បង់ជារៀងរហូត ប្រសិនបើអ្នកប្រើប្រាស់ទាំងឡាយទាញយកវាតាមតែអំពើរចិត្ត។ មិនតែប៉ុណ្ណោះការទាញយកធនធានមួយចំនួនទៀតដូចជាព្រៃឈើជាដើម ដែលវានឹងមានផលប៉ះពាល់ដល់បរិស្ថានដែលនាំអោយមាន

[6] Acciona, What is sustainable development and what are the global goals, (n.d), ចូលដកស្រង់ថ្ងៃទី០៧ ខែឧសភា ឆ្នាំ ២០១៩, https://www.acciona.com/sustainable-development/

[7] ដូចលេខយោងខាងលើ។

បម្រែបម្រួលអាកាសធាតុនៃភពផែនដី។ លើសពីនេះ កំណើនប្រជាជន និងឧស្សាហូបនីយកម្ម បាននាំអោយមានការរុករានដី និង ការបញ្ចេញកាកសំណល់រឹង រាវ និងឧស្ម័ន ទៅក្នុងបរិស្ថាន ភពផែនដី។ បញ្ហានេះបាននាំអោយគុណភាពបរិស្ថានមានការថយចុះជាលំដាប់។[8]

ចំពោះបញ្ហានេះអ្នកសេដ្ឋកិច្ចទាំងឡាយមានការព្រួយបារម្ភជាខ្លាំង ដោយហេតុថាពួកគេ គិតទៅដល់ផលលំបាកទៅថ្ងៃអនាគតរបស់ប្រជាជនជំនាន់ក្រោយ។ ប្រជាជនជំនាន់ក្រោយនឹង រងនូវទុក្ខលំបាកនៃបម្រែបម្រួលអាកាសធាតុ ការកើនឡើងកម្តៅផែនដី និងកង្វះស្បៀងដែលធ្វើ អោយពួកគេពិបាករស់នៅ។ ហេតុនេះហើយ បើនិយាយការអភិវឌ្ឍត្រូវតែជាការអភិវឌ្ឍប្រកប ដោយចីរភាព ដែលមិនផ្តល់ផលលំបាកដល់អ្នកជំនាន់ក្រោយ ហើយអាចអោយផែនដីមានអាយុ កាលយូរអង្វែង។ បានន័យថាអ្នកសេដ្ឋកិច្ចទាំងឡាយត្រូវគិតគូរពីបរិស្ថាន និងភាពយូរអង្វែង របស់វាផងដែរ។

## ១.៥. ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន *(Environment Impact Assessment)*

### ១.៥.១. និយមន័យ

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) គឺជាដំណើរការនៃការវាយតម្លៃលើផលប៉ះពាល់ បរិស្ថានចំពោះការបង្កើតគម្រោងណាមួយ ហើយស្វែងរកវិធីសាស្ត្រដើម្បីកាត់ន្ថយផលប៉ះពាល់ នេះអោយនៅកម្រិតទាបបំផុត។ គោលបំណងនៃការវាយតម្លៃនេះគឺដើម្បីរលឹកដល់អ្នកសម្រេច ចិត្តទាំងឡាយ ត្រូវគិតពីផលប៉ះពាល់ និងមានការត្រៀមខ្លួនជាមុន មុននឹងសម្រេចចិត្តអនុវត្ត គម្រោងរបស់ខ្លួន។ ការវាយតម្លៃនេះជាឧបករណ៍សំខាន់គាំទ្រដល់គោលការណ៍នៃការអភិវឌ្ឍ ប្រកបដោយចីរភាព។[9]

ជាទូទៅ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានត្រួតពិនិត្យដោយស្ថាប័នរដ្ឋាភិបាល នៃប្រទេសមួយតែត្រូវធ្វើដោយម្ចាស់គម្រោង។

### ១.៥.២. ដើមកំណើតនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ការរៀបចំគំម្រោងថ្មីៗ និងទំនើបជាច្រើននៅជុំវិញពិភពលោកបានចាត់ទុកថាការអភិវឌ្ឍ នាំអោយមានផលប៉ះពាល់ដល់បរិស្ថាន។ នៅឆ្នាំ១៩៤៧ ប្រទេសអង់គ្លេសគឺជាប្រទេសទី១ ដែលអនុញ្ញាតអោយអាជ្ញាធម៌រៀបចំផែនការ ដើម្បីយកកត្តាបរិស្ថានមកពិចារណាក្នុងការដាក់

[8] ដូចលេខយោងខាងលើ។

[9] University of Wollongong, (What is EIA?, n.d), ចូលទស្សនាថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩។ https://www.uow.edu.au/~sharonb/STS218/eis/what.html

ទណ្ឌកម្មលើសំណើអភិវឌ្ឍន៍នានា។ [10] តែទោះជាយ៉ាងណាក៏ដោយ ពុំមានយន្តការជាផ្លូវការណាមួយសម្រាប់អោយអាជ្ញាធមិអនុវត្តនោះទេ។

នៅដើមឆ្នាំ១៨៧២ សហរដ្ឋអាមេរិក បានបង្កើតឧទ្យានជាតិដើម្បីអភិរក្សវាលរហោស្ថាន និងប្រព័ន្ធអេកូឡូស៊ី។ ការកើនឡើងការអភិវឌ្ឍធនធានទឹក និងផ្លូវថ្នល់នាំអោយមានឥទ្ធិពលអវិជ្ជមានជាច្រើន ហើយបញ្ហានេះត្រូវបានគេយកទៅធ្វើការស៊ើបអង្កេត និងរកវិធានការតាំងពីដំណាក់កាលនៃការធ្វើផែនការ។

ក្នុងកំឡុងឆ្នាំ១៩៦០ សាធារណជនកាន់តែមានការព្រួយបារម្ភថាគុណភាពបរិស្ថានអាចនឹងមានការធ្លាក់ចុះខ្លាំងដោយសារតែរោងចក្រឧស្សាហកម្មទាំងឡាយ ដែលមិនបានខ្វាយខ្វល់ពីបញ្ហាបរិស្ថាន។ ទោះបីជា ច្បាប់មានសំរាប់តែត្រួតពិនិត្យទៅលើគម្រោងអភិវឌ្ឍន៍ជាក់លាក់ប៉ុណ្ណោះដូចជាច្បាប់គ្រប់គ្រងការបំពុលជាដើម តែយន្តការមួយចំនួន បានកំណត់ថាគំរោងអភិវឌ្ឍចម្បងទាំងអស់ត្រូវទាមទារអោយមានការត្រួតពិនិត្យលទ្ធផលបរិស្ថាន។[11]

ជាទូទៅ បច្ចេកទេសនៃការវាយតម្លៃសេដ្ឋកិច្ចត្រូវបានគេប្រើដើម្បីវាយតម្លៃទៅលើការចំណាយ និងអត្ថប្រយោជន៍នៃគម្រោង រឺសំណើណាមួយជាក់លាក់។ ទោះជាយ៉ាងណាក៏ដោយ បច្ចេកទេសបែបនេះគេកម្រនឹងយកទៅប្រើលើការវាយតម្លៃផលប៉ះពាល់បរិស្ថានណាស់។ វាពិបាកណាស់ក្នុងការកំណត់ផលប៉ះពាល់ជាទឹកប្រាក់ សម្រាប់បរិស្ថានដែលមានការវិចវឹលក្នុងរយៈពេលយូរ។ ពេលនោះហើយជាពេលចាប់ផ្តើមនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺក្នុងកំឡុងពាក់កណ្តាលទសវត្សឆ្នាំ១៩៦០។[12]

[10] ដូចលេខយោងខាងលើ។

[11] ដូចលេខយោងខាងលើ។

[12] ដូចលេខយោងខាងលើ។

# ជំពូកទី២

# បរិស្ថាន និងការអភិវឌ្ឍនៅកម្ពុជា

## ២.១. ស្ថានភាពបរិស្ថាននៅកម្ពុជា

បរិស្ថានរបស់ប្រទេសកម្ពុជាផ្តល់នូវធនធានធម្មជាតិរួមមាន ព្រៃឈើ ផ្លូវទឹក រុក្ខជាតិ និង សត្វព្រៃ។ ធនធានធម្មជាតិក៏រួមបញ្ចូលផងដែរនូវ រ៉ែ ថាមពល និងឧស្សាហកម្មនិស្សារណកម្ម។ បរិស្ថានគ្របដណ្តប់ដោយទេសភាពផ្សេងៗគ្នាយ៉ាងហោចណាស់ ចំនួន០៧នៅទូទាំងប្រទេស។

ប្រហែលបីភាគបួននៃប្រជាជនកម្ពុជាពឹងផ្អែកលើ កសិកម្ម ទិន្នផលព្រៃឈើ និង នេសាទ ដើម្បីចិញ្ចឹមជីវិត ។ ដូច្នេះ ការថែរក្សាបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ មានសារៈសំខាន់ណាស់។

បរិស្ថានរបស់ប្រទេសកម្ពុជា ក៏ត្រូវបានចាត់ទុកជាធនធានមួយសម្រាប់ពិភពលោក។ ជាផ្នែកមួយនៃតំបន់ឥណ្ឌូចិនភូមា ប្រទេសកម្ពុជា គឺជាទីកំណាប់ធនធានជីវចម្រុះ និងជាប្រទេសដែលមានរុក្ខជាតិ សត្វកម្រ និងសត្វជិតផុតពូជចំនួន២,៤៤៩ប្រភេទ។[13] ទោះយ៉ាងណាក្តី ការអភិវឌ្ឍសេដ្ឋកិច្ចបានបង្កឱ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងចាប់តាំងពីឆ្នាំ ១៩៩០ ជាងមកម្ល៉េះ។

ទោះបីជាភូមិសាស្ត្ររបស់ប្រទេសកម្ពុជា ត្រូវបានគ្រប់ដណ្តប់ដោយតំបន់ទំនាបកណ្តាល ប្រហែលបីភាគបួននៃប្រទេសកម្ពុជា មានទេសភាពខុសៗគ្នាជាច្រើនផ្សេងទៀតគឺព្រៃតំបន់ខ្ពង់រាបរួមមាន តំបន់ភ្នំក្រវាញ ដងរែក ភ្នំឆ្លូង ព្រៃលិចទឹក បឹងទន្លេសាប ប្រព័ន្ធទន្លេមេគង្គ វាលទំនាប ខាងកើត ឬតំបន់ខ្ពង់រាប ព្រៃឈើកណ្តាល តំបន់ឆ្នេរសមុទ្រដែលរួមមានដីល្បាប់កោងកាង និង ឈូងសមុទ្រថៃ។

ប្រហែលពីរភាគបីនៃប្រទេសកម្ពុជារួមមាន បឹងទន្លេសាប ដែលស្ថិតនៅក្នុងអាងទន្លេមេគង្គ គឺជាបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី រួមចំណែកយ៉ាងសំខាន់ដល់សុខមាលភាពនៃតំបន់មេគង្គទាំងមូល ជាពិសេសតំបន់ ដីសណ្តទន្លេមេគង្គ ។ កាលដើមឆ្នាំ ២០០១ អង្គការស្បៀងអាហារនិងកសិកម្ម បានគូសបញ្ជាក់ពី ការផ្លាស់ប្តូរប្រព័ន្ធអេកូទន្លេសាប ដែលបាននាំយកមកនូវកំណល្បាប់ម៉ដ្ឋ គឺមីកសិកម្ម ការបំពុលផ្សេងៗ បម្រែបម្រួល ធារាសាស្ត្រ ការស្រោចស្រព និងការដឹក

---

[13] សហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ និងធនធានធម្មជាតិ (IUCN). "បញ្ជីក្រហមនៃប្រភេទសត្វដែលរងការគំរាមកំហែង របស់អង្គការ IUCN". ចូលអាន ៣០ មេសា ២០១៩ .[ភាសាអង់គ្លេស] www.iucnredlist.org/search/link/560b9516-f31cfec4

ជញ្ជូន ហើយជាការពិត ការផ្លាស់ប្តូរទាំងនេះ នឹងមានផលប៉ះពាល់វិជ្ជមានផង និងអវិជ្ជមានផង ដល់ប្រព័ន្ធទន្លេមេគង្គទាំងមូល។[14]

- គោលនយោបាយបរិស្ថាន

ក្រសួងបរិស្ថាន ជាអ្នកទទួលខុសត្រូវចំពោះការអនុវត្តច្បាប់បរិស្ថាន និងបទប្បញ្ញត្តិពាក់ព័ន្ធនានាស្រប ទៅនឹងអាណត្តិក្នុងរដ្ឋធម្មនុញ្ញដែល រដ្ឋបានទទួលខុសត្រូវក្នុងការ "ការពារបរិស្ថាន និងតុល្យភាពនៃធនធានធម្មជាតិដ៏បរិបូរណ៍"។[15]

នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន បានចេញផ្សាយ គោលនយោបាយការចូលរួមចំណែករបស់កម្ពុជា ដើម្បីអនុវត្តក្របខ័ណ្ឌអនុសញ្ញាសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ(INDC) របស់ខ្លួនកាលពីខែតុលា ឆ្នាំ២០១៥ ដែលផ្តោតសំខាន់លើការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ឱ្យបាន២៧ភាគរយ ពីកម្រិតស្ថានភាពដដែល ដែលបានព្យាករណ៍សម្រាប់ឆ្នាំ២០៣០ លើសពីនេះ គោលនយោបាយនេះ បានកំណត់គោលដៅមួយក្នុងការបង្កើននូវគម្របព្រៃឈើ៦០ភាគរយនៃផ្ទៃដីសរុបនៅឆ្នាំ២០៣០។ មុនពេលចេញផ្សាយគោលនយោបាយនេះ ការចំណាយលើការប្រែប្រួលអាកាសធាតុ ត្រូវបានកំណត់ថានឹងកើនឡើង១.៥ភាគរយនៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ២០១៨។[16]

មានឯកសារយុទ្ធសាស្ត្រជាច្រើនបានផ្តោតលើការការពារបរិស្ថាន និងធនធានធម្មជាតិ។ យុទ្ធសាស្ត្រចតុកោណដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដាក់អាទិភាពខ្ពស់ទៅលើការការពារបរិស្ថាន។ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជាមានចំណុចដៅមួយថា "បញ្ចូលគោលការណ៍អភិវឌ្ឍន៍ប្រកបដោយចីរភាព ទៅក្នុងគោលនយោបាយ និងកម្មវិធីជាតិ និងបង្កើនធនធានបរិស្ថាន"។[17] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ)

[14] Dirk Lambert. អង្គការស្បៀងអាហារ និងកសិកម្មរបស់អង្គការសហប្រជាជាតិ. ២០០១. "ការនេសាទនៅបឹងទន្លេសាប ករណីសិក្សាស្តីពីការនេសាទមងក្រឡានៅតំបន់លិចទឹក". ចូលអាន ៣០ មេសា ២០១៩. [ភាសាអង់គ្លេស], www.fao. org/docrep/004/ab561e/ab561e00.htm

[15] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៥៩

[16] Alessandro Marazzi Sassoon. "ទីដៅបម្រែបម្រួលអាកាសធាតុដាក់គោលដៅខ្ពស់". *ភ្នំពេញប៉ុស្តិ៍*, ២ តុលា ២០១៥។ ចូលអាន ៣០ មេសា ២០១៩. [ភាសាអង់គ្លេស] www.phnompenhpost.com/national/climate-change-targets-aim-high

[17] ក្រសួងផែនការ គោលដៅអភិវឌ្ឍសហវត្សកម្ពុជា (CMDGs). ចូលអាន ៣០ មេសា ២០១៩. www.mop.gov.kh/home/cmdgs/tabid/156/default.aspx

សម្រាប់ឆ្នាំ២០១៤-២០១៨ មានចែងពីសារៈសំខាន់នៃការការពារធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយចីរភាព។[18]

នៅឆ្នាំ១៩៩៣ ព្រះរាជក្រឹត្យស្តីពីការបង្កើតតំបន់ការពារធម្មជាតិ ដែលអនុវត្តដោយក្រសួងបរិស្ថានសម្គាល់តំបន់ការពារ២៣ ដែលនៅពេលនោះគ្របដណ្តប់ជាង១៨ភាគរយ នៃផ្ទៃដីនៃព្រះរាជាណាចក្រកម្ពុជា។[19] ព្រះរាជក្រឹត្យនេះបានចែកតំបន់ការពារជាបួនប្រភេទ៖

- ឧទ្យានធម្មជាតិ
- ដែនជម្រកសត្វព្រៃ
- តំបន់ការពារទេសភាព
- តំបន់ប្រើប្រាស់ច្រើនយ៉ាង។

សន្ទស្សន៍អភិបាលកិច្ចធនធានរបស់កម្ពុជា "ធ្លាក់មកត្រឹមលេខ ៣០" នៃ១០០ពិន្ទុ ក្នុងឆ្នាំ២០១៧ ជាប្រទេសជាប់ចំណាត់ថ្នាក់ទី៧៩ ក្នុងចំណោម៨៩ប្រទេស និងជាប្រទេសជាប់ចំណាត់ថ្នាក់ទី ១៤ ក្នុងចំណោម ១៥ ប្រទេសនៅតំបន់អាស៊ីប៉ាស៊ីហ្វិក។ ពិន្ទុសម្រាប់ការរុករករ៉ែមាសនៅដំណាក់កាលដំបូង ដែលឆ្លុះបញ្ចាំងឱ្យឃើញពីការចាត់ថ្នាក់នៅមានភាពកម្សោយចំពោះថវិកាជាតិ និងអាជ្ញាប័ណ្ណជាពិសេស។[20]

## ២.២. គុណតម្លៃនៃបរិស្ថានមកលើការអភិវឌ្ឍនៅកម្ពុជា

រដ្ឋាភិបាលបានទទួលស្គាល់នូវការចូលរួមចំណែកទាំងផ្នែកសេដ្ឋកិច្ច និងការអភិវឌ្ឍនៅក្នុងវិស័យផ្សេងៗ នៃធនធានបរិស្ថាន និងធម្មជាតិរបស់ជាតិ ។ គោលនយោបាយវិស័យព្រៃឈើជាតិសម្គាល់នូវការអភិវឌ្ឍផ្នែកសេដ្ឋកិច្ចសង្គម និងការកាត់បន្ថយភាពក្រីក្រ ដែលស្ថិតក្នុង

---

[18] ក្រសួងផែនការ. "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) សម្រាប់ឆ្នាំ ២០១៤-២០១៨." ចូលអាន ៣០ មេសា ២០១៩. www.mop.gov.kh/LinkClick.aspx?fileticket=XOvSGmpI4tE%3d&tabid=216&mid=705

[19] សុជាតា លក្ខិណា សាន. "បង្ហាញពីជ័យជម្នះ៖ ការវាយតម្លៃតំបន់ការពារសហគមន៍ នៅកម្ពុជា", នៅក្នុង Sango Mahanty, Jefferson Fox, Michael Nurse, Peter Stephen, និង Leslie McLees. "ការធ្វើឱ្យមានតុល្យភាព សមភាពក្នុងការគ្រប់គ្រងធនធានធម្មជាតិនៅសហគមន៍ នៅក្នុងតំបន់អាស៊ី" RECOFTC (មជ្ឈមណ្ឌលបណ្តុះបណ្តាលព្រៃឈើសហគមន៍ក្នុងតំបន់សម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក), មជ្ឈមណ្ឌលបូព៌ា បស្ចឹម នៅទីក្រុង ហូណូលូលូ ឆ្នាំ ២០០៦.

[20] វិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិ. "ប្រទេសនានា៖ ប្រទេសកម្ពុជា." ចូលអាន ៣០ មេសា ២០១៩. [ភាសាអង់គ្លេស] http://resourcegovernanceindex.org/country-profiles/KHM/mining

ចំណោមកត្តាចលករពីរនៅក្នុងសកម្មភាពគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។[21] យ៉ាងណាក្តី របាយការណ៍មួយចំនួនបានឱ្យដឹងថា ទោះបីជាមានក្របខ័ណ្ឌច្បាប់មួយដែលរឹងមាំសម្រាប់បរិស្ថានក៏ដោយ ក៏របាយការណ៍នោះមិនត្រូវបានអើពើ ឬបោះជំហានទៅម្ខាងទៀតដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនរយៈពេលខ្លី។[22]

ធនាគារពិភពលោកបានប៉ាន់ប្រមាណថា ការជួលព្រៃឈើនៅប្រទេសកម្ពុជា (តម្លៃឈើដែលផលិតបានដកនឹងថ្លៃចំណាយក្នុងការផលិត) មានតម្លៃប្រមាណ ៤.៥ ភាគរយនៃផលិតផលក្នុងស្រុកសរុបរបស់ជាតិ នៅឆ្នាំ២០១៣[23] ដែលស្មើនឹង ៦៧០ លានដុល្លាសហរដ្ឋអាមេរិច ដោយផ្អែកលើផលិតផលក្នុងស្រុកសរុបឆ្នាំ២០១៣។[24]

ការអភិរក្សបរិស្ថាន បានចូលរួមចំណែកដោយប្រយោល ដល់ចំណូលបានមកពីវិស័យទេសចរណ៍ តាមរយៈកម្មវិធីអេកូទេសចរណ៍ ដែលទាក់ទាញភ្ញៀវទេសចរបានចំនួន១.៣ភាគរយនៃចំនួនភ្ញៀវទេសចរណ៍ទាំងអស់ នៅក្នុងឆ្នាំ២០១៤។ ក្នុងឆ្នាំនោះដែរ វិស័យទេសចរណ៍បានចូលរួមចំណែកនូវទឹកប្រាក់ ២.៧៣៦ពាន់លានដុល្លារសហរដ្ឋអាមេរិចដល់សេដ្ឋកិច្ច។[25]

ក្រៅពីគុណតម្លៃខាងហិរញ្ញវត្ថុទៅលើបរិស្ថាន តំបន់ទេសភាពបែបធម្មជាតិរបស់ជាតិមានគុណតម្លៃផ្នែកវប្បធម៌និងជំនឿដ៏ខ្ពង់ខ្ពស់ដល់ក្រុមជនជាតិដើមភាគតិចរបស់ប្រទេស។ ឧទាហរណ៍: បណ្តាញសហគមន៍ព្រៃឡង់ បានរាយការណ៍ថា មានជនជាតិដើមភាគតិចគួយប្រមាណ ២០០,០០០នាក់ ពឹងអាស្រ័យលើតំបន់ព្រៃកណ្តាល ឬហៅថា ព្រៃឡង់ សម្រាប់ជីវភាពរស់នៅ និងទំនៀមទំលាប់ប្រពៃណី ផ្នែកសង្គម និងជំនឿរបស់ពួកគេ ដែលបានផ្សាភ្ជាប់ទៅនឹងព្រៃឈើ។[26] សហគមន៍ជនជាតិដើមភាគតិចនិងខ្មែរ បានអះអាងស្រដៀងគ្នានេះនៅទូទាំងប្រទេស។

---

[21] រដ្ឋបាលឈើ. "របាយការណ៍ស្តីពីគោលនយោបាយ វិស័យព្រៃឈើជាតិ". ចូលអាន ៣០ មេសា ២០១៩ http://www.forestry.gov.kh/Law/ForestPolicy.html

[22] គណប្រតិភូសហភាពអ៊ឺរ៉ុប ប្រចាំកម្ពុជា. "ទម្រង់បរិស្ថានប្រចាំប្រទេស សហភាពអ៊ឺរ៉ុប ប្រទេសកម្ពុជា ឆ្នាំ ២០០២". ទំព័រ ៣៨. ចូលអាន ៣០ មេសា ២០១៩[ភាសាអង់គ្លេស] http://eeas.europa.eu/delegations/cambodia/documents/publications/ country_env_profile_cam_april_2012_en.pdf

[23] ធនាគារពិភពលោក."ការចូលរួមចំណែកនៃប្រភពធនធានធម្មជាតិចំពោះផលិតផលក្នុងស្រុកសរុប". ចូលអាន ៣០ មេសា ២០១៩ [ភាសាអង់គ្លេស] http://wdi.worldbank.org/table/3.15

[24] ធនាគារពិភពលោក. "ផលិតផលក្នុងស្រុកសរុប គិតជាដុល្លាសហរដ្ឋអាមេរិច". ចូលអាន ៣០ មេសា ២០១៩ [ភាសាអង់គ្លេស] http://data.worldbank.org/indicator/NY.GDP.MKTP.CD/countries

[25] ក្រសួងទេសចរ. "របាយការណ៍ស្ថិតិទេសចរ ខែមិថុនា". ចូលអាន ៣០ មេសា ២០១៩. www.tourismcambodia.org/images/mot/statistic_reports/tourism_statistics_jun_2015.pdf

[26] បណ្តាញសហគមន៍ព្រៃឡង់. "ព្រៃឈើ". ចូលអាន ៧ ខែឧសភា ឆ្នាំ ២០១៩. http://preylang.net/the-forest-2/

## ២.៣. ផលប៉ះពាល់នៃការអភិវឌ្ឍមកលើបរិស្ថាននៅកម្ពុជា

ប្រទេសកម្ពុជា មានជីវៈចម្រុះដ៏សម្បូរបែប រួមមាន សត្វ និង រុក្ខជាតិចម្រុះជាច្រើនប្រភេទ និងមានធនធានព្រៃឈើ ដែលប្រជាជនក្រីក្រជាច្រើននៅតាមជនបទពឹងអាស្រ័យលើសម្រាប់ចិញ្ចឹមជីវិតរបស់ពួកគេ។ ទោះជាយ៉ាងណា ប៉ុន្មានឆ្នាំចុងក្រោយនេះធនធានព្រៃឈើកាន់តែស្ថិតនៅក្រោមសម្ពាធពីការប្រើប្រាស់ដីសេដ្ឋកិច្ចខ្លាំងឡើងៗ។ ទន្ទឹមនឹងនោះ ប្រទេសកម្ពុជា ជាប្រទេសងាយរងគ្រោះទៅនឹងផលប៉ះពាល់ នៃបម្រែបម្រួលអាកាសធាតុដោយសារតែសមត្ថភាពនៃការបន្សាំនៅទាប។ ប្រជាជននៅតាមជនបទភាគច្រើនស្ថិតក្នុងហានិភ័យដោយសារព្រឹត្តិការណ៍អាកាសធាតុបំផ្លិចបំផ្លាញ ជាពិសេស ទឹកជំនន់ និងគ្រោះរាំងស្ងួត។[27]

ក្រៅពីនេះក៏មានបញ្ហាមួយចំនួនដែលកើតមានឡើងនៅកម្ពុជាផងដែរ។ បញ្ហាទាំងនោះមានដូចជាការបំពុលខ្យល់ ការបំពុលទឹក កាកសំណល់រឹង និងបម្រែបម្រួលអាកាសធាតុ។

### ២.៣.១. ការបំពុលខ្យល់

ការបំពុលខ្យល់មានប្រភពចេញពីការដុតឥន្ធនៈ តួយ៉ាងប្រេងឥន្ធនៈ ប្រេងម៉ាស៊ូត និងធ្យូងសម្រាប់ការដឹកជញ្ជូន ការប្រើប្រាស់តាមផ្ទះ និងការប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម និងថាមពល។ ការដុតឥន្ធនៈទាំងនេះបានបញ្ចេញផ្សែងពុលចូលទៅក្នុងបរិយាកាសដែលបង្កឱ្យមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ទៅលើគុណភាពខ្យល់ និងសុខភាពរបស់មនុស្ស។

ទោះបីជាប្រទេសកម្ពុជាមិនមែនជាប្រទេសដែលមានឧស្សាហកម្មជឿនលឿនខ្លាំងក៏ដោយកម្ពុជាស្ថិតក្នុងលំដាប់ទី១៦៨ក្នុងចំណោម១៨០ប្រទេស នៅក្នុងសន្ទស្សន៍នៃការអនុវត្តខាងបរិស្ថាន (EPI) សម្រាប់គុណភាពខ្យល់ ក្នុងឆ្នាំ២០១៨។ សន្ទស្សន៍ EPI សម្រាប់ការវាស់ស្ទង់គុណភាពខ្យល់ ដែលត្រូវបានបង្កើតឡើងដោយសាកលវិទ្យាល័យYale (វិទ្យាស្ថានYale សម្រាប់គោលនយោបាយ និងច្បាប់បរិស្ថាន) និងសាកលវិទ្យាល័យ Columbia (វិទ្យាស្ថានសម្រាប់បណ្តាញនៃព័ត៌មានវិទ្យាសាស្ត្រផែនដីអន្តរជាតិ) ក្នុងកិច្ចសហប្រតិបត្តិការជាមួយវេទិកាសេដ្ឋកិច្ចពិភពលោកបានរួមបញ្ចូលនូវសូចនាករចំនួន ៣៖

- ការបំពុលខ្យល់ នៅកម្រិតប៉ះពាល់ជាមធ្យមស្មើ PM2.5 (ភាគល្អិតនិចល)
- ការបំពុលខ្យល់ នៅកម្រិតលើសពី PM2.5

---

[27] កម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិ. "កម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិប្រចាំកម្ពុជា". ចូលអាន ៧ ខែឧសភា ឆ្នាំ ២០១៩ www.kh.undp.org/content/cambodia/en/home/countryinfo.html

- គុណភាពខ្យល់នៅតាមគេហដ្ឋាន។[28]

PM2.5 គឺជាភាគល្អិតនិចលតូចៗនៅក្នុងខ្យល់ ដែលមានអង្កត់ផ្ចិតតូចជាង ២.៥ មីក្រុង ឬប្រហែលពភាគរយនៃអង្កត់ផ្ចិតរបស់សក់មួយសរសៃ។ ភាគល្អិតទាំងនេះមានគ្រោះថ្នាក់ណាស់ ដែលអាចបង្កឱ្យមានការស្លាប់មុនអាយុពីជម្ងឺបេះដូង និងសួត ហើយភាគល្អិតនេះក៏អាចបង្កឱ្យកើតជម្ងឺហឺត រលាកទងសួត និងជម្ងឺដែលពាក់ព័ន្ធនឹងផ្លូវដង្ហើមផ្សេងៗទៀត។

អង្គការសុខភាពពិភពលោកបានកំណត់ការណែនាំគុណភាពខ្យល់សម្រាប់កម្រិត PM2.5 ជាមធ្យមប្រចាំឆ្នាំត្រឹម ១០μg/m$^3$។ ការបំពុលខ្យល់នៅកម្ពុជាមានកម្រិតខ្ពស់ជាងគឺ២៦μg/m$^3$ក្នុងឆ្នាំ២០១៦។[29] តួលេខរបស់ប្រទេសកម្ពុជាមានភាពល្អប្រសើរជាងមធ្យមភាគសកល ទោះបីជាយ៉ាងណាក៏ដោយក៏មាន ៥១ μg/m$^3$។[30]

ក្រសួងបរិស្ថាន ជាអាជ្ញាធរទទួលបន្ទុកតាមឃ្លាំមើលគុណភាពខ្យល់ និងដោះស្រាយបញ្ហាបំពុលនៅប្រទេសកម្ពុជា។ ដោយត្រូវបានបង្កើតឡើងនៅឆ្នាំ២០០០ អនុក្រឹត្យស្តីអំពីការគ្រប់គ្រងការបំពុលខ្យល់ និងការរំខានដោយសម្លេង បានដាក់ចេញនូវស្តង់ដារសម្រាប់គុណភាពខ្យល់ក្នុងបរិយាកាសយ៉ាងជាក់លាក់។[31] យោងទៅតាមច្បាប់ ប្រភពនៃការបំពុលខ្យល់ ត្រូវបានចែកជាប្រភពចល័ត (មានទីតាំងមិនអចិន្ត្រៃយ៍ ដូចជារថយន្ត) និងប្រភពអចល័ត (មានទីតាំងអចិន្ត្រៃយ៍ ដូចជារោងចក្រ)។

### ២.៣.២. ការបំពុលទឹក

អង្គការ UNICEF បានរកឃើញថា ប្រជាជនកម្ពុជាចំនួន ៦.៣ លាននាក់ ក្នុងចំណោម ១៤.៩ លាននាក់ មិនទាន់មានលទ្ធភាពទទួលបានទឹកស្អាតប្រើប្រាស់នៅឡើយទេ។ នៅអំឡុងពេលនៃទិវាទឹកពិភពលោកឆ្នាំ២០១៤ អង្គការUNICEF នៅកម្ពុជា បានជំរុញឱ្យរដ្ឋាភិបាលដោយផ្តោតជាសំខាន់ពីការផ្គត់ផ្គង់ទឹកស្អាតនៅទីជនបទ។ អង្គការនេះក៏បានបញ្ជាក់ផងដែរថាមូលហេតុចម្បង ដែលប្រជាជនកម្ពុជារាប់លាននាក់មិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលបានទឹកស្អាត

---

[28] សន្ទស្សន៍នៃការអនុវត្តខាងបរិស្ថាន, (កម្ពុជា៖ គុណភាពខ្យល់ ឆ្នាំ២០១៨), ចូលអាន ៧ ឧសភា ២០១៩។ http://epi.yale.edu/country/cambodia

[29] វិទ្យាស្ថានផលប៉ះពាល់សុខភាព (២០១៨), *ស្ថានភាពនៃគុណភាពខ្យល់សកល* ឆ្នាំ២០១៨។ របាយការណ៍ពិសេស។ បូស្តុន, រដ្ឋម៉ាសាឈូសេតៈ វិទ្យាស្ថានផលប៉ះពាល់សុខភាព។ចូលអាន ៧ ឧសភា ២០១៩។ https://www.stateofglobalair.org/report

[30] ដូចឯកសារយោងខាងលើ។

[31] អនុក្រឹត្យស្តីពីការគ្រប់គ្រងការបំពុលដោយខ្យល់និងការរំខានដោយសម្លេង, (ឆ្នាំ២០០០)

ប្រើប្រាស់គឺបណ្តាលមកពីរដ្ឋាភិបាលបានដាក់ការផ្តត់ផ្គង់ទឹកស្អាតនៅតំបន់អភិវឌ្ឍន៍ជាអាទិភាពច្រើនជាងនៅទីជនបទ។

ការបំពុលដោយសារធាតុអាសេនិច ត្រូវបានរកឃើញនៅក្នុងទឹកផឹករបស់កម្ពុជាក្នុងកំឡុងពេលនៃការសិក្សាវាយតម្លៃលើគុណភាពទឹកផឹកនៅកម្ពុជា ដែលត្រូវបានធ្វើឡើងរួមគ្នាដោយក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល នៅរវាងឆ្នាំ១៩៩៩ និងឆ្នាំ២០០០។ ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលបានបង្កើតជាស្តង់ដារគុណភាពទឹកផឹករបស់កម្ពុជាមួយនៅក្នុងឆ្នាំ២០០៤។ ជាឧទាហរណ៍ ទឹកផឹកមិនគួរមានផ្ទុកសារធាតុអាសេនិចលើសពី 0.0៥ មីលីក្រាមក្នុងមួយលីត្រនោះទេ។

សារធាតុអាសេនិច ជាធម្មតាអាចត្រូវបានរកឃើញនៅក្នុងទឹកក្រោមដី និងតំបន់អាងទន្លេមេគង្គ។ ខេត្តកណ្តាល ព្រៃវែង កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ និងក្រចេះ ជាបណ្តាខេត្តដែលត្រូវបានរកឃើញថាមានកម្រិតកំហាប់អាសេនិចខ្ពស់បំផុតនៅកម្ពុជា។ ក្នុងចំណោមខេត្តទាំងនេះ ខេត្តកណ្តាល គឺជាខេត្តដែលមានការបំពុលអាសេនិចខ្ពស់ជាងគេបង្អស់។ នៅឆ្នាំ២០១៤កាសែតភ្នំពេញប៉ុស្តិ៍បានរាយការណ៍ថា នៅក្នុងខេត្តកណ្តាល៣៥%នៃអណ្តូងយកទៅធ្វើសំណាកចំនួនជាង១៥,០០០ ត្រូវបានរកឃើញថាមានផ្ទុកសារធាតុអាសេនិចខ្ពស់ជាងកម្រិតថ្នាក់ជាតិ0.0៥មីលីក្រាមក្នុងមួយលីត្រ ហើយអណ្តូងប្រហែល៥៩%មានផ្ទុកអាសេនិចលើសពីកម្រិតស្តង់ដាររបស់អង្គការសុខភាពពិភលោក ចំនួន0.0១ មីលីក្រាមក្នុងមួយលីត្រ។

ទឹក ពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការរក្សាមនុស្ស និងបរិស្ថានឱ្យមានសុខភាពល្អ ទោះដោយផ្ទាល់ ឬដោយប្រយោលក្តី។ ការបំពុលដោយអាសេនិច អាចនឹងធ្វើឱ្យប្រជាជនកម្ពុជារាប់លាននាក់ ប្រឈមនឹងគ្រោះថ្នាក់ ប្រសិនបើគ្មានសកម្មភាពណាមួយត្រូវបានអនុវត្ត។

នៅក្នុងសេចក្តីសង្ខេបមួយរបស់អង្គការ UNICEF បានរកឃើញថា ផលប៉ះពាល់នៃសារធាតុអាសេនិចដែលបានបង្ករឱ្យកើតជំងឺដង្កាត់ផ្សេងៗ ត្រូវបានចងក្រងទុកប្រមាណជាង៥០០ឯកសារ ហើយមានចំនួនអ្នកស្លាប់ និងពិការអវៈយវៈជាច្រើនទៀត។

- ច្បាប់ និងបទប្បញ្ញត្តិ

អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៩។ នៅក្នុងអនុក្រឹត្យនេះចែងថាក្រសួងបរិស្ថានមានតួនាទី និងទំនួលខុសត្រូវក្នុងការដឹកនាំ ត្រួតពិនិត្យនិងរាយការណ៍អំពីសកម្មភាពនានាដែលអាចបណ្តាលឱ្យមានការបំពុលជាយថាហេតុ។ ក្រុមហ៊ុន ឬ

អង្គភាពនានាដែលបញ្ចេញ ឬដឹកជញ្ជូនសំណល់រាវទៅទីដទៃ ចាំបាច់ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន។

អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក បានចែកប្រភេទប្រភពបំពុលទឹកជាពីរះ

- ប្រភេទទី១៖ តម្រូវឱ្យមានសុំការអនុញ្ញាតពីក្រសួងបរិស្ថាន ក្នុងករណីដែលបរិមាណសំណល់រាវរបស់ប្រភពបំពុលនោះមានចំនួនច្រើនជាង ១០មែត្រគូបក្នុងមួយថ្ងៃ។
- ប្រភេទទី២៖ ចាំបាច់តម្រូវឱ្យមានសុំការអនុញ្ញាតពីក្រសួងបរិស្ថាន មុនពេលបញ្ចេញចោល ឬដឹកសំណល់រាវទៅទីដទៃ។

ប្រភពបំពុលច្រើនជាង៦០ប្រភេទ សម្រាប់គម្រោងសាធារណៈ ឬឯកជននានាត្រូវបានដាក់បញ្ចូលទៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។ នៅក្នុងនោះក៏មានរាប់បញ្ចូលទាំងគម្រោងសម្រាប់រោងចក្រកែច្នៃផលិតផលអាហារ រោងចក្រកែច្នៃផលិតផលកសិឧស្សាហកម្ម មជ្ឈមណ្ឌលពាណិជ្ជកម្ម សណ្ឋាគារ ភោជនីយដ្ឋាន មន្ទីរពេទ្យនិងគ្លីនិក ឧស្សាហកម្មធុនស្រាលនិងធុន់ការផលិតឈើនិងក្រដាស ការរុករករ៉ែ រោងចក្រផលិតសារធាតុគីមី រោងចក្រក្រណាត់ និងរោងចក្រថាមពល។

ទោះជាយ៉ាងនេះក្តី ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកបានរាយការណ៍ពីការលេចឡើងនូវករណីមួយចំនួនដែលទាក់ទងទៅនឹងការបំពុលទឹកដែលមិនទាន់ត្រួតពិនិត្យបានល្អ។ ជាឧទាហរណ៍ នៅក្នុងឆ្នាំ២០១៥ អ្នកភូមិជនជាតិដើមភាគតិចកួយ ដែលមកពីស្រុកថាឡាបរិវ៉ាត់នៅក្នុងខេត្តស្ទឹងត្រែងបានរាយការណ៍ថារោងអារឈើមួយកន្លែងបានបំពុលផ្លូវទឹកក្នុងមូលដ្ឋានរបស់គាត់ ដែលបានធ្វើឱ្យប៉ះពាល់ដល់ប្រភពទឹក និងដំណាំ ហើយបានបណ្តាលឱ្យមានជំងឺសើរស្បែកនានាផងដែរ។ វិទ្យុអាស៊ីសេរីបានបញ្ជាក់ដែរថា ទឹកកខ្វក់ត្រូវបានបង្ហូរចូលទៅក្នុងស្ទឹងបឹងបួរដែលជាប្រភពទឹកសម្រាប់ប្រជាជននៅក្នុងតំបន់ប្រើប្រាស់ប្រចាំថ្ងៃ រួមមាន សម្រាប់ងូត ទទួលទាន បោកគក់ និងសម្រាប់ធ្វើម្ហូបអាហារផងដែរ។

ប្រហាក់ប្រហែលនឹងគ្នានេះដែរ កាលពីដើមឆ្នាំ២០១៦ រោងចក្រកែច្នៃដំឡូងមីក្នុងតំបន់មួយនៃខេត្តប៉ៃលិន ត្រូវបានគេចោទថាជាដើមហេតុដែលនាំឱ្យមានការបំពុលទឹក។ កាសែតភ្នំពេញប៉ុស្តិ៍ បានរាយការណ៍ថា សំណល់នានាដែលចេញមកពីការដាំដុះនេះ បានសម្លាប់សត្វត្រីនិងបំពុលទឹកផឹក ហើយក៏បានធ្វើឱ្យប៉ះពាល់ដល់ប្រជាជនប្រមាណជា៣០០គ្រួសារ នៅក្នុងឃុំត្រែង ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបងផងដែរ។ ជាដំណោះស្រាយ អាជីកម្មនានាបានជីក

ត្រពាំងក្បែរទីតាំងផលិតកម្ម របស់ខ្លួនសម្រាប់បង្ហូរសំណល់ ហើយប្រជាជនក្នុងសហគមន៍ត្រូវបានបង្ខំចិត្តទិញទឹកបរិសុទ្ធ ឬជីកអណ្តូងដើម្បីប្រើប្រាស់។

### ២.៣.៣. ភាគសំណល់រឹង

នៅប្រទេសកម្ពុជា ការដុតសំរាមនៅតែជាការអនុវត្តជាទូទៅពិសេសនៅតាមជនបទ ដោយសារតែកង្វះខាតទីកន្លែងសម្រាប់ចាក់សំរាម ឬសេវាប្រមូលសំរាម។ ការដុតសំរាមត្រូវបានទទួលស្គាល់ថាជាវិធីចោលសំរាមដ៏ងាយស្រួលបំផុត។

នៅក្នុងឆ្នាំ២០១៥ អ្នកនាំពាក្យក្រសួងបរិស្ថានលោក សោ សុភាព បានឱ្យដឹងថាកន្លែងចាក់សំរាមនៅកម្ពុជា ភាគច្រើនមិនមានការបែងចែកត្រឹមត្រូវរវាងប្រភេទសំរាមបំបែកសរីរាង្គបាន និងសំរាមមិនអាចបំបែកសរីរាង្គបាននោះទេ។[32]

យោងតាមការសិក្សាមួយនៅក្នុងឆ្នាំ២០១៥ ដែលដឹកនាំដោយវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងអង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជា (COMPED) បានឱ្យដឹងថា កាលពីឆ្នាំ២០១៣ រាជធានីភ្នំពេញបានបញ្ចេញកាកសំណល់ប្រមាណ១,២៨៦តោនក្នុងមួយថ្ងៃ។[33] នៅមុនឆ្នាំ២០៣០ បរិមាណសំរាមត្រូវបានគេទស្សន៍ទាយថានឹងកើនឡើងទ្វេរដងរហូតដល់៣,១១២តោន ក្នុងមួយថ្ងៃ។[34] ការសិក្សានេះក៏បានប្រមើលឃើញថា ទីលានចាក់សំរាមទាំងពីរទីតាំង នៅទីក្រុងភ្នំពេញដែលស្ថិតនៅខណ្ឌដង្កោរនឹងផ្ទុកដល់ចំណុះរបស់វានៅត្រឹមឆ្នាំ២០២០ខាងមុខនេះ។[35]

### ២.៣.៤. បម្រែបម្រួលអាកាសធាតុ

ការប្រែប្រួលអាកាសធាតុត្រូវបានផ្តល់និយមន័យថា ជាការបកស្រាយយោងទៅតាមស្ថិតិស្តីអំពីលំនាំអាកាសធាតុដែលមានការប្រែប្រួលក្នុងរយៈពេលវែងមួយ។ ខណៈពេលអាកាសធាតុនៅលើផែនដីបានឆ្លងកាត់អំឡុងពេលនៃការប្រែប្រួល ភ័ស្តុតាងតាមបែបវិទ្យាសាស្ត្រសម័យទំនើបបានបង្ហាញថា ការកើនឡើងនិងបំរែបំរួលធាតុអាកាសដ៏ឆាប់រហ័សកំពុងតែកើតមានឡើងនៅទូទាំងពិភពលោក ហើយវាត្រូវបានហៅថា "ការប្រែប្រួលអាកាសធាតុ" ដែលជាលទ្ធផលកើត

---

[32] យុត សុភចរិយា, និង Sarah Taguiam. "ទីលានចាក់សំរាមនឹងផ្លាស់ប្តូរមុខមាត់ថ្មី." ភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥។ ចូលអាន ៧ ឧសភា ២០១៩។ http://www.phnompenhpost.com/national/dumpsites-get-makover.

[33] Henderson, Simon និង យួន ណារីម. "អង្គការមិនមែនរដ្ឋាភិបាលលើកយកបញ្ហាសំរាម មកផ្តោតជាសំខាន់"។ ឌឹ ខេមបូឌា ដេលី ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥។ ចូលអាន ៧ ឧសភា ២០១៩។ https://www.cambodiadaily.com/archives/ngo-brings-trash-problem-into-greater-focus-91206/.

[34] ដូចឯកសារយោងខាងលើ។

[35] ដូចឯកសារយោងខាងលើ។

ចេញពីសកម្មភាពរបស់មនុស្សទាក់ទងទៅនឹងការធ្វើឧស្សាហូបនីយកម្ម ការកាប់បំផ្លាញព្រៃឈើ និងបម្រែបម្រួលនៃការប្រើប្រាស់ដី។[36]

ប្រទេសកម្ពុជា ស្ថិតក្នុងចំណាត់ថ្នាក់ជាប្រទេសមួយក្នុងបណ្តាប្រទេសដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុនៅតំបន់អាស៊ីអាគ្នេយ៍។[37] របាយការណ៍គម្របព្រៃឈើឆ្នាំ ២០១៤ ដែលចេញផ្សាយដោយអង្គការទិន្នន័យអំពីការអភិវឌ្ឍ(ODC) បានបង្ហាញពីនិន្នាការដែលកំពុងកើតមានក្នុងការបាត់បង់គម្របព្រៃឈើ ជាពិសេសព្រៃស្រោងនៅទូទាំងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៧៣មក។[38] ជាលើកដំបូងហើយក្នុងរយៈពេល៩១ឆ្នាំកន្លងមក ដែលភាគរយនៃគម្របផ្ទៃដីមិនមែនព្រៃ(៥៨.៩ភាគរយ) មានទំហំធំជាងគម្របព្រៃឈើ(៤៧.៧ភាគរយ)។[39] គួរបញ្ជាក់ផងដែរថា ការកាប់បំផ្លាញព្រៃឈើដែលមានអត្រាខ្ពស់នឹងរួមចំណែកដល់ការបំភាយឧស្ម័នផ្ទះកញ្ចក់។

ប្រទេសកម្ពុជាងាយទទួលរងផលប៉ះពាល់ខ្លាំងពីការប្រែប្រួលអាកាសធាតុ ដោយសារកម្ពុជាពឹងផ្អែកខ្លាំងលើវិស័យនានាដែលពាក់ព័ន្ធទៅនឹងធាតុអាកាសដូចជា វិស័យកសិកម្ម ដីធ្លី ធនធានទឹក ព្រៃឈើ និងជលផលជាដើម។[40] ដោយសារកម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍន៍ ជាមួយនឹងលទ្ធភាពឆ្លើយតបនឹងបំរែបំរួលអាកាសធាតុនៅទន់ខ្សោយ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធនៅមានកម្រិតនៅឡើយ ហេតុនេះជីវភាពរស់នៅរបស់ប្រជាជននៅតាមជនបទ ជាពិសេសស្ត្រីនិង

---

36 របាយការណ៍អភិវឌ្ឍន៍មនុស្សកម្ពុជាឆ្នាំ២០១១, ការកសាងភាពធន់៖ អនាគតរបស់អ្នកជនបទក្នុងការប្រឈមមុខនឹងការប្រែប្រួលអាកាសធាតុ. ក្រសួងបរិស្ថាន និងអង្គការ UNDP កម្ពុជា, ២០១១.

37 Arief A. Yusuf, Herminia A. Francisco.ការវិភាគផែនទី. ការកំណត់ផែនទីភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុចំពោះតំបន់អាស៊ីអាគ្នេយ៍. EEPSEA: ២០០៩. ដកស្រង់ ៥ ខែ ឧសភា ២០១៩. http://www.eepsea.org/pub/tr/12324196651Mapping_Report.pdf

38 "គម្របព្រៃឈើ." អង្គការទិន្នន័យអំពីការអភិវឌ្ឍ. ១០ មេសា ២០១៥. ដកស្រង់ ៥ ឧសភា ២០១៩. http://www.opendevelopmentcambodia.net/briefing/forest-cover/.

39 ដូចលេខយោងខាងលើ។

40 ក្រសួងបរិស្ថាន. ឯកសារគោលនយោបាយ. ផែនការយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា ២០១៤-២០២៣. ក្រសួងបរិស្ថាន៖ ២០១៤. ដកស្រង់ ៥ ឧសភា ២០១៩. http://www.camclimate.org.kh/en/documents-and-media/library/category/127-national-strategic-plan.html?download=474:cambodia-climate-change-strategic-plan-2014-2023-en-final.

ក្រុមងាយរងគ្រោះដទៃទៀត នឹងមានឧបសគ្គក្នុងការដោះស្រាយបញ្ហាផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។[41]

យោងតាមការសិក្សាតាមបែបវិភាគមួយរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ(USAID) ដែលបានអនុវត្តការព្យាករអាកាសធាតុសម្រាប់ឆ្នាំ២០៥០ ចំពោះសេដ្ឋកិច្ចនៅតំបន់អាងទន្លេមេគង្គនាពេលបច្ចុប្បន្ននេះ បង្ហាញឲ្យឃើញពីការខាតបង់សេដ្ឋកិច្ចដោយសារការប្រែប្រួលអាកាសធាតុនាពេលអនាគត អាចនឹងកើនរហូតដល់ទៅ៦១ភាគរយនៃផលិតផលក្នុងស្រុកសរុបនៅតាមទីជនបទក្នុងមនុស្សម្នាក់នៅប្រទេសកម្ពុជា។[42] គួរកត់សម្គាល់ផងដែរថា ការព្យាករអាកាសធាតុឆ្នាំ២០៥០ នឹងប៉ះពាល់ប្រជាជនកម្ពុជាប្រមាណ៧លាននាក់ដែលប្រកបមុខរបរក្នុងវិស័យកសិកម្ម និងប្រមាណ ២៤០,០០០នាក់ នៅក្នុងវិស័យសំណង់ ដែលបង្កឱ្យមានផលប៉ះពាល់សេដ្ឋកិច្ចសរុបប្រមាណ១.៥ពាន់លានដុល្លារសហរដ្ឋអាមេរិក។[43]

រាជរដ្ឋាភិបាលកម្ពុជា បានព្យាករណ៍ថា សីតុណ្ហភាពប្រចាំខែជាមធ្យម នឹងកើនឡើងចន្លោះពី០.០១៣អង្សាសេនិងកើនឡើង០.០៣៦អង្សាសេក្នុងមួយឆ្នាំនៅឆ្នាំ២០៩៩។[44]

របាយការណ៍វិភាគអំពីការខូចខាត និងការបាត់បង់ដោយសារគ្រោះមហន្តរាយនៅកម្ពុជាបង្ហាញថា ទឹកជំនន់ប្រមាណ៤២ភាគរយ គ្រោះរាំងស្ងួត១៥ភាគរយ អគ្គីភ័យ១៧ភាគរយ ខ្យល់ព្យុះ១៨ភាគរយ រន្ទះបាញ់៧ភាគរយ និងការរាតត្បាតកក្តាសត្វចង្រៃ១ភាគរយ បានកើតឡើងនៅក្នុងប្រទេសកម្ពុជាពីឆ្នាំ១៩៩៦ ដល់ឆ្នាំ២០១៣។[45] គួរឱ្យកត់សម្គាល់ផងដែរថា ក្នុងកំឡុង

---

[41] ណាង ភិរុណ. ការបន្សាំការប្រែប្រួលអាកាសធាតុនិងការចិញ្ចឹមជីវិតក្នុងការលើកកម្ពស់កំណើនសេដ្ឋកិច្ច៖ ការពិនិត្យឡើងវិញនៃផលប៉ះពាល់ការប្រែប្រួលអាកាសធាតុនិងការកសាងសមត្ថភាពបន្សាំនៅកម្ពុជា. CDRI៖ ២០១៣. ដកស្រង់ ៤ ឧសភា ២០១៩. http://www.cdri.org.kh/webdata/download/wp/wp82e.pdf

[42] Talberth, John. Reytar, Katie. ការប្រែប្រួលអាកាសធាតុនៅតំបន់អាងទន្លេមេគង្គក្រោម. ញូវយ៉ក៖ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID), ២០១៤. ដកស្រង់ ៧ ឧសភា ២០១៩. http://mekongarcc.net/sites/default /files/usaid_marcc_values_at_risk_report_with_exesum-revised.pdf

[43] ដូចលេខយោងខាងលើ។

[44] ក្រសួងបរិស្ថាន. ឯកសារគោលនយោបាយ. ផែនការយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា ២០១៤-២០២៣. ក្រសួងបរិស្ថាន៖ ២០១៤. ដកស្រង់ ៥ ឧសភា ២០១៩. http://www.camclimate.org.kh/en/documents-and-media/library/category/127-national-strategic-plan.html?download=474:cambodia-climate-change-strategic-plan-2014-2023-en-final.

[45] គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិនៅកម្ពុជា. របាយការណ៍វិភាគ. របាយការណ៍វិភាគការខូចខាតនិងការបាត់បង់ដោយសារគ្រោះមហន្តរាយនៅកម្ពុជា ១៩៩៦-២០១៣. ដកស្រង់

ពេលនេះ (២០១៦) គ្រោះមហន្តរាយបានសម្លាប់មនុស្សចំនួន២,០៥០នាក់ ដែលការស្លាប់នោះគឺដោយសារទឹកជំនន់មានប្រមាណ៥៣ភាគរយនៃទិន្នន័យសរុប។[46]

៧ ឧសភា ២០១៩. http://www.kh.undp.org/content/dam/cambodia/docs/EnvEnergy/Cambodia-Disaster-Loss-and-Damage-Analysis-Report%201996-%202013.pdf.

[46] ដូចលេខយោងខាងលើ។

# ជំពូកទី៣
# នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

## ៣.១. ប្រវត្តិនៃការបង្កើតក្រសួង

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយ ដែលសម្បូរទៅដោយសម្បត្តិធម្មជាតិដ៏មានតម្លៃ និងបរិស្ថានស្រស់ស្អាត។ ដើម្បីរក្សាសម្បត្តិដ៏មានតម្លៃនេះឱ្យគង់វង្សយូរអង្វែង រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ មាត្រា៥៩ បានចែងថា"រដ្ឋត្រូវរក្សាការពារបរិស្ថាននិងតុល្យភាពនៃភោគទ្រព្យធម្មជាតិហើយត្រូវចាត់ចែងឲ្យមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រងមានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាតនិងឧស្ម័នថ្មនិងខ្សាច់ ត្បូងថ្ម ព្រៃឈើ និង អនុផលព្រៃឈើពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផល។ ក្នុងស្មារតីនេះព្រះបាទ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់បានឡាយព្រះហត្ថលេខាលើព្រះរាជក្រឹត្យស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣។

ក្រសួងបរិស្ថានត្រូវបានបង្កើតឡើងដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន និងមានអនុក្រឹត្យលេខ២០អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន។ គោលបំណងនៃច្បាប់នេះ គឺធានានូវការគ្រប់គ្រងការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាព និងការរស់នៅដោយចីរភាពសម្រាប់ជាឧត្តមប្រយោជន៍យូរអង្វែងរបស់ប្រជាជនកម្ពុជាគ្រប់រូប និងគ្រប់ជំនាន់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អនុក្រឹតនេះកំណត់បេសកកម្មការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាននិងបណ្តាអង្គភាពក្រោមឱវាទក្រសួង។

## ៣.២. ចក្ខុវិស័យ និងបេសកកម្ម

ក្រសួងបរិស្ថាន បានអនុវត្តកាតព្វកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវ និងមានចក្ខុវិស័យច្បាស់លាស់។ ចក្ខុវិស័យរបស់ក្រសួងបរិស្ថាន គឺការលើកស្ទួយកិច្ចគាំពារការពារបរិស្ថាន និងអភិរក្សធនធានធម្មជាតិនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីរួមចំណែកកែលម្អគុណភាពបរិស្ថាន ទ្រទ្រង់សុខភាពសាធារណៈ វប្បធម៌ជាតិ និងសេដ្ឋកិច្ចសង្គម។[47]

[47] ផែនការយុទ្ធសាស្ត្រក្រសួងបរិស្ថានឆ្នាំ ២០០៩-២០១៣

ក្រសួងបរិស្ថានមានតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំ និងគ្រប់គ្រងការងារបរិស្ថាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ មុខងារ និងភារកិច្ចដ៏ចម្បងនេះ ត្រូវបានចង្អុលឱ្យអនុវត្តតាមរយៈការបំពេញមុខងារអាទិភាពមួយចំនួនដូចជា[48]៖

- ជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការរៀបចំទស្សនៈវិស័យ យុទ្ធសាស្ត្រ និងគោលនយោបាយ ព្រមទាំងកំណត់អាទិភាពអភិវឌ្ឍន៍ដោយចីរភាពរបស់ជាតិ
- គ្រប់គ្រងនិងដឹកនាំគាំពារបរិស្ថាន ការអភិរក្សជីវចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិដោយសនិទានភាព
- រៀបចំផែនការសមស្រប និងអនុវត្តគោលនយោបាយបរិស្ថានដែលមានសង្គតិភាព និងគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព និងស្ថេរភាពដោយសហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ
- តាក់តែង និងអនុវត្តបរិធានច្បាប់បរិស្ថានដើម្បីលើកកម្ពស់ និងធានាការអភិវឌ្ឍដោយចីរភាព និងស្ថេរភាព
- រៀបចំ និងអនុវត្តដំណើរការពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់គម្រោង និងសកម្មភាពដែលស្នើឡើង ឬមានស្រាប់របស់ម្ចាស់គម្រោងឯកជន ឬសាធារណៈ និងធានាឱ្យមានការគោរពតាមសេចក្តីសម្រេចនានារបស់ក្រសួងបរិស្ថាន អំពីការពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- ផ្តល់យោបល់ដល់ក្រសួង ភ្នាក់ងារ និងស្ថាប័នពាក់ព័ន្ធនានាដើម្បីធានាថារាល់ការអភិរក្សការអភិវឌ្ឍ ការគ្រប់គ្រង និងការប្រើប្រាស់ធនធានធម្មជាតិទាំងអស់បានធ្វើឡើងប្រកបដោយសនិទានភាព និរន្តរភាព និងស្ថេរភាព
- គ្រប់គ្រងតំបន់ការពារធម្មជាតិរបស់ជាតិដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ
- រៀបចំសារពើភណ្ឌ ប្រភព ប្រភេទ និងបរិមាណសំណល់រឹង-រាវ សារធាតុបំពុល សារធាតុពុល សារធាតុគ្រោះថ្នាក់ ផ្សែង សំឡេង រំញ័រ ព្រមទាំងតាក់តែងនូវវិធានការទប់ស្កាត់កាត់បន្ថយ និងត្រួតពិនិត្យការបំពុលបរិស្ថាន ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ
- រៀបចំនីតិវិធីសម្រាប់ធ្វើអធិការកិច្ចលើប្រភពបំពុល និងអធិការកិច្ចប្រភពបំពុលទាំងនោះដោយសហការជាមួយក្រសួងពាក់ព័ន្ធ រៀបចំចងក្រងរបាយការណ៍ស្តីពីបទល្មើសជូន

[48] អនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

ស្ថាប័នមានសមត្ថកិច្ច ធ្វើការដាក់ពិន័យ ចេញបញ្ជា អនុវត្តទោសបញ្ញត្តិ និងអនុវត្តនីតិវិធីរដ្ឋបាល និងតុលាការ ស្របតាមច្បាប់ និងបទប្បញ្ញត្តិនានាដែលមានជាធរមាន

- ប្រមូល វិភាគ និងគ្រប់គ្រងទិន្នន័យបរិស្ថាន និងធនធានធម្មជាតិ និងរៀបចំរបាយការណ៍ជាទៀងទាត់ និងផលិតផលព័ត៌មានដទៃទៀតស្តីពីស្ថានភាពបរិស្ថាននៅព្រះរាជាណាចក្រកម្ពុជា
- ផ្តល់ព័ត៌មានស្តីពីសកម្មភាពរបស់ខ្លួនទាក់ទងនឹងកិច្ចគាំពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិជូនសាធារណជន
- លើកកម្ពស់ការយល់ដឹងជាសាធារណៈ និងលើកទឹកចិត្តឱ្យមានការចូលរួមជាសាធារណៈក្នុងកិច្ចគាំពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិតាមរយៈការផ្សព្វផ្សាយព័ត៌មាន និងសកម្មភាពបង្កើនការយល់ដឹងក៏ដូចជាតាមរយៈនីតិវិធីនានាសម្រាប់ការផ្តល់យោបល់ជាសាធារណៈនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចនានាអំពីបរិស្ថាន
- តាក់តែង និងអនុវត្តកម្មវិធីអប់រំបរិស្ថានសម្រាប់គ្រប់ស្រទាប់នៃសង្គម ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិនានា
- ផ្តល់យោបល់នានាជូនរាជរដ្ឋាភិបាលអំពីការចូលរួមក្នុងកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារអន្តរជាតិនានាដែលទាក់ទងនឹងបរិស្ថាន និងការអភិរក្សធនធានធម្មជាតិ ព្រមទាំងអនុវត្តកិច្ចការជំនាញពាក់ព័ន្ធសម្រាប់ជាមូលដ្ឋានជូនរាជរដ្ឋាភិបាលកម្ពុជាក្នុងការបំពេញកាតព្វកិច្ច និងការទទួលខុសត្រូវនៅក្រោមកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារទាំងនោះ
- ជំរុញ និងលើកទឹកចិត្តឱ្យមានការវិនិយោគសមស្របក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិដោយនិរន្តរភាព និងគ្រប់គ្រងមូលនិធិពិសេសដែលបង្កើតឡើងក្នុងគោលដៅគាំពារបរិស្ថាន និងអភិរក្សធនធានធម្មជាតិ
- សហការជាមួយអង្គការជាតិ និងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ មូលដ្ឋាន និងបណ្តាប្រទេសនានា ដើម្បីធានាឱ្យមានកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិដោយនិរន្តរភាពក្នុងព្រះរាជាណាចក្រកម្ពុជា
- អនុវត្តភារកិច្ចដទៃទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

## ៣.៣. រចនាសម្ព័ន្ធក្រសួង

ក្រសួងបរិស្ថាន ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់បេសកម្មឱ្យដឹកនាំនិងគ្រប់គ្រងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងមាន

និរន្តរភាព និងការរស់នៅប្រកបដោយចីរភាព សម្រាប់ជាឧត្តមប្រយោជន៍យូរអង្វែងរបស់ប្រជាជនកម្ពុជាគ្រប់រូប និងគ្រប់ជំនាន់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដូចមានចែងក្នុងអនុក្រឹត្យ លេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ខែកក្កដាឆ្នាំ២០១៦ ក្រសួងបរិស្ថានមានអគ្គនាយកដ្ឋានចំណុះទីស្តីការក្រសួងចំនួនបួនអគ្គាធិការដ្ឋានមួយ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពចំនួនមួយ ដែលក្នុងនោះមាន៣៥នាយកដ្ឋានជំនាញ (ភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ)។

រចនាសម្ព័ន្ធនេះត្រូវបានធ្វើឡើង ដើម្បីឆ្លើយតបទៅនឹងតម្រូវការនាពេលបច្ចុប្បន្នក៏ដូចជាពេលអនាគត ក្នុងការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ ទៅតាមភូមិសាស្ត្រនៃរបៀងអភិរក្សជីវៈចម្រុះ ការលើកស្ទួយជីវភាព រស់នៅរបស់ប្រជាសហគមន៍មូលដ្ឋាន និងការពង្រឹងទំនាក់ទំនងជាមួយប្រជាសហគមន៍មូលដ្ឋានឱ្យកាន់តែជិតស្និទ្ធ ក្នុងដំណើរអភិវឌ្ឍន៍សហគមន៍។

យោងតាមអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន ដែលត្រូវបានចុះហត្ថលេខានៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ ដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ដែលជាអគ្គនាយកដ្ឋានថ្មីរបស់ក្រសួងបរិស្ថាន មាននាយកដ្ឋានចំណុះចំនួន៤រួមមាន[49]៖

១. នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
២. នាយកដ្ឋានជីវភាពសហគមន៍
៣. នាយកដ្ឋានតំបន់បេតិកភណ្ឌ
៤. នាយកដ្ឋានទេសចរណ៍ធម្មជាតិ។

នៅក្នុងរចនាសម្ព័ន្ធនៃអគ្គនាយកដ្ឋានថ្មីនេះមាន នាយកដ្ឋានចំនួន៣ត្រូវបានបំបែកចេញពីនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ហើយនាយកដ្ឋានថ្មីចំនួនមួយត្រូវបានបង្កើតគឺនាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ។

ដោយឡែកអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិដែលពីមុនមាន៨នាយកដ្ឋានត្រូវបានកែសម្រួលឱ្យមកនៅត្រឹម៧នាយកដ្ឋានវិញរួមមាន[50]៖

១. នាយករដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ

[49] ក្រសួងបរិស្ថាន, អំពីក្រសួងបរិស្ថាន, ចូលដកស្រង់ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩។ http://www.moe.gov.kh/about-moe

[50] ដូចលេខយោងខាងលើ។

២. នាយកដ្ឋាន អភិរក្សតំបន់ការពារធម្មជាតិដីគោក ខាងកើតទន្លេមេគង្គ

៣. នាយកដ្ឋាន អភិរក្សតំបន់ការពារធម្មជាតិដីគោក ខាងជើងបឹងទន្លេសាប

៤. នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោក ខាងត្បូងបឹងទន្លេសាប

៥. នាយកដ្ឋានអភិរក្សតំបន់ដីសើមទឹកសាប

៦. នាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរ

៧. នាយកដ្ឋានអធិការកិច្ច និងការពង្រឹងការអនុវត្តច្បាប់។

នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកត្រូវបានបែងចែជា ៣ គឺៈ

១. នាយកដ្ឋាន អភិរក្សតំបន់ការពារធម្មជាតិដីគោក ខាងកើតទន្លេមេគង្គ

២. នាយកដ្ឋាន អភិរក្សតំបន់ការពារធម្មជាតិដីគោក ខាងជើងបឹងទន្លេសាប

៣. នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោក ខាងត្បូងបឹងទន្លេសាប។

### ៣.៤. បុព្វហេតុនៃការបង្កើតនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

នាយកដ្ឋាន អង្កេតពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានបង្កើតឡើង និងទទួលស្គាល់ជាផ្លូវការដោយអនុក្រឹតលេខ៥៧ អនក្រ.ក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧។ រីឯតម្រូវការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងអភិវឌ្ឍន៍ត្រូវបានបង្កើតឡើងដោយ អនុក្រឹតលេខ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩។

អនុក្រឹតនេះមានគោលបំណងៈ

- កំណត់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើរាល់គម្រោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈហើយត្រូវបានពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថានមុនដាក់ជូនរដ្ឋាភិបាលសម្រេច
- កំណត់ប្រភេទ និងទំហំគម្រោង សកម្មភាពដែលស្នើឡើងព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន ទាំងសាធារណៈ ដែលត្រូវវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បំផុសឱ្យមានការចូលរួមពីសាធារណៈជន ក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិយោបល់មកធ្វើការពិចារណា ក្នុងកិច្ចដំណើរការអនុម័តគម្រោង។

អនុក្រឹតនេះ មានវិសាលភាពអនុវត្តចំពោះគម្រោងដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់និងកំពុងដំណើរការ ដែលជាបុគ្គលឯកជន ក្រុមហ៊ុនឯកជន ក្រុមហ៊ុនចំរុះរដ្ឋ ឬ

ក្រុមហ៊ុនរដ្ឋ ក្រសួង-ស្ថាប័នរដ្ឋ ដែលមានចែងនៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ លើកលែងតែគម្រោងដែលមានលក្ខណៈពិសេស និងចាំបាច់បន្ទាន់ ដែលសម្រេចដោយរាជរដ្ឋាភិបាល។

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ គឺតម្រូវឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ដើម្បីចងក្រងជារបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ហើយរបាយការណ៍នេះគឺត្រូវឆ្លងកាត់ការពិនិត្យ និងផ្តល់យោបល់ពីក្រសួងបរិស្ថាន និងក្រសួងស្ថាប័នពាក់ព័ន្ធ មុននឹងដាក់ជូនរាជរដ្ឋាភិបាលកម្ពុជាដើម្បីធ្វើការអនុម័តលើគម្រោងអភិវឌ្ឍន៍។

## ៣.៥. រចនាសម្ព័ន្ធនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន




## ៣.៦. តួនាទីរបស់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានតួនាទីនិងភារកិច្ចដូចខាងក្រោមៈ

– រៀបចំសេចក្តីព្រាងគោលនយោបាយលិខិតបទដ្ឋានគតិយុត្ត ផែនការ និងថវិកា លើកស្ទួយកិច្ចសហការជាមួយអ្នកពាក់ព័ន្ធ កសាងសមត្ថភាពមន្ត្រីនាយកដ្ឋាន គ្រប់គ្រងហិរញ្ញវត្ថុ អង្កេត តាមដានការងារផ្ទៃក្នុង និងគ្រប់គ្រងការងាររដ្ឋបាលនានា ដែលពាក់ព័ន្ធនឹងតួនាទី និងភារកិច្ចរបស់នាយកដ្ឋាន

- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានាពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម
- ជំរុញការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម និងកិច្ចសន្យាការពារបរិស្ថាន ដោយសម្របសម្រួលនិងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ
- រៀបចំ និងអនុវត្តវិធានផ្ទៃក្នុងសម្រាប់គ្រប់គ្រងការពិនិត្យលើដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម
- រៀបចំឯកសារស្តីពីការណែនាំ និងលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃក្រុមហ៊ុន ដែលស្នើសុំចុះបញ្ជីជាក្រុមហ៊ុនទីប្រឹក្សាសម្រាប់សិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម
- ពិនិត្យ វាយតម្លៃ និងផ្តល់យោបល់លើការស្នើសុំចុះបញ្ជីជាក្រុមហ៊ុនទីប្រឹក្សាសម្រាប់សិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម
- ពិនិត្យ វាយតម្លៃ និងផ្តល់យោបល់លើការស្នើសុំចុះបញ្ជីជាក្រុមហ៊ុនទីប្រឹក្សាសម្រាប់សិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម
- ពិនិត្យ និងផ្តល់យោបល់លើរាល់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនៃគម្រោងវិនិយោគសាធារណៈ និងគម្រោងវិនិយោគឯកជន
- ធានានូវការទទួលបានព័ត៌មាន និងជំរុញឱ្យមានការចូលរួមជាប្រចាំរបស់សាធារណៈជននៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម
- ពិនិត្យ និងវាយតម្លៃលើចំណាត់ថ្នាក់គម្រោង និងលក្ខខណ្ឌការងារគម្រោង ដើម្បីកំណត់អំពីតម្រូវការសម្រាប់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ឬ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ឬកិច្ចសន្យាការពារបរិស្ថានកំណត់លក្ខខណ្ឌសម្រាប់ផែនការគ្រប់គ្រងបរិស្ថាន និងកិច្ចសន្យាការពារបរិស្ថានជាមួយម្ចាស់គម្រោងដែលរួមទាំងកម្រៃ ដែលត្រូវបង់មូលនិធិទាយជ្ជទានបរិស្ថាន និងមូលនិធិបរិស្ថាន និងសង្គម
- ជំរុញការអនុវត្តការបង់មូលនិធិទាយជ្ជទានបរិស្ថាន និងមូលនិធិបរិស្ថាន និងសង្គម

- សម្របសម្រួលជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីចុះអង្កេត តាមដាន និងពង្រឹងការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដែលមានចែងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម និងកិច្ចសន្យាការពារបរិស្ថាន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីអគ្គនាយក។

# ជំពូកទី៤

# នីតិវិធីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

## ៤.១. បទប្បញ្ញត្តិផ្សេងៗទាក់ទងនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

យោងតាមមាត្រា៦ នៃព្រះរាជក្រមលេខ១២៩៦ នស.រកម.៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីការប្រកាសអោយប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិៈ

- កំណត់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន លើរាល់គម្រោង និងសកម្មភាពឯកជន ឬ សាធារណៈហើយត្រូវបានត្រួតពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថានមុនដាក់ជូនរដ្ឋាភិបាលសម្រេច។
- ការវាយតម្លៃក៏ត្រូវអនុវត្តផងដែរចំពោះសកម្មភាព ដែលមានស្រាប់ និងកំពុងដំណើរការ ហើយដែលពុំទាន់វាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅឡើយ
- ប្រភេទនិងទំហំគំរោង និងសកម្មភាពដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន និងសាធារណៈ ដែលត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននោះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន។

បន្ថែមពីនេះ ក្នុងការវាយតម្លៃគម្រោងនេះផងដែរ ក្រសួងក៏បានបំផុសអោយមានការចូលរួមពីសាធារណជនក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិយោបល់ មកធ្វើការពិចារណាក្នុងកិច្ចដំណើរការអនុម័តគម្រោង។ មួយវិញទៀត ក្រសួងតម្រូវម្ចាស់គម្រោងត្រូវធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់ដំបូង ចំពោះគម្រោងដែលតម្រូវអោយមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ បន្ទាប់មកម្ចាស់គម្រោង ត្រូវដាក់ពាក្យសុំពិនិត្យ របាយការណ៍នេះ ព្រមទាំងរបាយការណ៍សិក្សាបុរេលទ្ធភាពទៅក្រសួងបរិស្ថាន។ មិនតែប៉ុណ្ណោះ ម្ចាស់គម្រោងត្រូវដាក់ពាក្យសុំពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ និងរបាយការណ៍លទ្ធភាពទៅក្រសួងបរិស្ថាន ចំពោះគម្រោងដែលអាចបង្កហេតុប៉ះពាល់បរិស្ថានធ្ងន់ធ្ងរដល់ធនធានធម្មជាតិ អេកូស្ថែម សុខភាព និងសុខមាលភាពសាធារណៈ។[51]

ជាពិសេស ក្រសួងបានធ្វើប្រតិភូកម្មអំណាច ទៅអោយមន្ទីរបរិស្ថានខេត្ត-ក្រុង មានសិទ្ធពិនិត្យផ្តល់យោបល់ និងសម្រេចលើរបាយការណ៍ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញរបស់គំរោងដែលស្នើឡើង ជាបុគ្គលឯកជន ក្រុមហ៊ុនឯកជន ក្រុមហ៊ុនចំរុះរដ្ឋ ឬ

[51] អនុក្រឹត្យលេខ ៧២អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ក្រុមហ៊ុនរដ្ឋ ឬក្រសួងស្ថាប័ន ដែលមានទំហំវិនិយោគក្រោមពីរលាន (២.០០០.០០០) ដុល្លារសហរដ្ឋអាមេរិកដូច មានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ។[52]

ចំណាំ[53]៖

- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង(វ.ហ.ប.ដ) ៖ គឺជាការសិក្សាដំបូងលើធនធានបរិស្ថានរូបសាស្ត្រ ជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម ហើយភាគច្រើនគឺពឹងផ្អែកទៅលើទិន្នន័យមានស្រាប់ដែលមាននៅក្នុង និងជុំវិញតំបន់គំរោង ដើម្បីជាមូលដ្ឋានកំណត់ ព្យាករណ៍ និងវិភាគនូវសក្តានុពលនៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដែលអាចកើតមានឡើងដោយសារសកម្មភាពរបស់គម្រោង សំដៅរកវិធានការកាត់បន្ថយនូវហេតុប៉ះពាល់អវិជ្ជមានឱ្យដល់កម្រិតអប្បបរមា និងបង្កើនហេតុប៉ះពាល់វិជ្ជមានឱ្យដល់កម្រិតអតិបរមា។ ប្រសិនបើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង មានផលប៉ះពាល់ដល់បរិស្ថាន និងសង្គមធ្ងន់ធ្ងរ នោះទាមទារអោយម្ចាស់គម្រោងត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ។
- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ (វ.ហ.ប) ៖ គឺជាការសិក្សាលម្អិតលើធនធានបរិស្ថានរូបសាស្ត្រ បរិស្ថានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម ហើយភាគច្រើនពឹងផ្អែកទៅលើទិន្នន័យចម្បង ដែលមាននៅក្នុង និងជុំវិញតំបន់គម្រោង ដើម្បីជាមូលដ្ឋានក្នុងការកំណត់ ព្យាករណ៍ និងវិភាគនូវសក្តានុពលនៃហេតុប៉ះពាល់បរិស្ថាន និងសង្គមធ្ងន់ធ្ងរដែលអាចកើតមានឡើងដោយសារសកម្មភាពរបស់គម្រោង សំដៅរកវិធានការកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានឱ្យដល់កម្រិតអប្បបរមា និងបង្កើនហេតុប៉ះពាល់វិជ្ជមានអោយដល់កម្រិតអតិបរមា។

## ៤.២. ការជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា

ម្ចាស់គម្រោងអាចមានជម្រើសពីរនៅក្នុងការសរសេររបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ទី១ ម្ចាស់គម្រោងអាចប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុនទីប្រឹក្សា ដែលជាអ្នកទទួលខុសត្រូវផ្ទាល់ក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ

---

[52] ប្រកាសលេខ២៣០ ប្រ.ក ប.ស្ត ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០០៥ ស្តីពីប្រតិភូកម្មអំណាចក្នុងការធ្វើសេចក្តីសម្រេចក្នុងនាមក្រសួងចំពោះគំរោងវិនិយោគ ជូនមន្ទីរបរិស្ថានខេត្ត-ក្រុង

[53] ឧបសម្ព័ន្ធនៃប្រកាសលេខ ៣៧៦ ប្រក ប.ស្ត ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់ដំបូង និងពេញលេញ

ដោយគោរពទៅតាមគោលការណ៍ណែនាំទូទៅនេះ។ ទី២ ករណីម្ចាស់គម្រោងអាចសរសេររបាយការណ៍ដោយខ្លួនឯងផ្ទាល់ នោះក្រុមសរសេររបាយការណ៍ត្រូវតែមានសមត្ថភាពជំនាញគ្រប់គ្រាន់ក្នុងការរៀបចំរបាយការណ៍ ដោយមានការទទួលស្គាល់ពីក្រសួងបរិស្ថាន។[54]

ក្រុមហ៊ុនទីប្រឹក្សាទាំងឡាយតម្រូវអោយមានការចុះបញ្ជី និងទទួលស្គាល់ពីក្រសួងបរិស្ថាន។ ហើយ ក្រសួងបរិស្ថានក៏បានកំណត់នូវលក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យរបស់ក្រុមហ៊ុនទីប្រឹក្សាក្នុងគោលបំណងដើម្បីអោយក្រុមហ៊ុនទីប្រឹក្សានោះ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ប្រកបដោយគុណភាព ប្រសិទ្ធភាព និងតម្លាភាព ដើម្បីឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ មិនតែប៉ុណ្ណោះ ក្រុមហ៊ុនទីប្រឹក្សា ត្រូវបង់ថ្លៃសេវាចុះបញ្ជីដល់ក្រសួងបរិស្ថាន។ ថ្លៃសេវានេះត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ជាពិសេស បើយោងតាមប្រសាសន៍របស់**លោក ជា ឡេង** អនុប្រធាននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន បានលើកឡើងថា ក្រុមហ៊ុនទីប្រឹក្សាត្រូវតែជាក្រុមហ៊ុនក្នុងស្រុក បើទោះបីជាក្រុមហ៊ុនបរទេសក៏ត្រូវសហការជាមួយក្រុមហ៊ុនក្នុងស្រុកដែរ ទើបក្រសួងអាចពិចារណាអនុញ្ញាតឱ្យធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានបាន។ លោកបានមានប្រសាសន៍បន្តថា ការធ្វើបែបនេះគឺមានគោលបំណងលើកកម្ពស់ និងផ្តល់ចំណូលដល់ក្រុមហ៊ុនក្នុងស្រុក។ ម្យ៉ាងវិញទៀត ក៏បានជួយដល់ការលើកកម្ពស់ ការប្រើប្រាស់ធនធានមនុស្សក្នុងប្រទេសយើងផងដែរ។ លោកក៏បានបន្ថែមទៀតថា ក្រសួងមិនចង់អោយមានក្រុមហ៊ុនបរទេសខ្លះមកវិនិយោគនៅកម្ពុជាហើយ ថែមទាំងយកក្រុមហ៊ុនវាយតម្លៃជាជនជាតិគេទៀតនោះទេ។

### ៤.២.១. លក្ខណៈវិនិច្ឆ័យ

ក្រុមហ៊ុនទីប្រឹក្សាត្រូវមាននាយកក្រុមហ៊ុន ប្រធានក្រុមបច្ចេកទេស អ្នកជំនាញការបច្ចេកទេស និងជំនួយការបច្ចេកទេស ដែលត្រូវមានលក្ខណៈវិនិច្ឆ័យ ដែលបានតម្រូវដោយក្រសួងបរិស្ថានដូចខាងក្រោម។[55]

[54] ប្រការ៤ និងប្រការ៥ នៃប្រកាសលេខ ៣៧៦ ប្រក ប.ស្ត ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់ដំបូង និងពេញលេញ

[55] ប្រការ៤ និងប្រការ៥ នៃប្រកាសលេខ ៣៧៦ ប្រក ប.ស្ត ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់ដំបូង និងពេញលេញ

នាយកក្រុមហ៊ុនទីប្រឹក្សាត្រូវមានលក្ខណៈវិនិច្ឆ័យដូចតទៅ៖

– មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ
– មានបទពិសោធន៍ក្នុងការគ្រប់គ្រងទូទៅ ឬបទពិសោធន៍ទាក់ទងនឹងការគ្រប់គ្រងបរិស្ថាន និងសង្គម យ៉ាងតិច០៥ឆ្នាំ និងធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។

ប្រធានក្រុមបច្ចេកទេសរបស់ក្រុមហ៊ុនទីប្រឹក្សា ត្រូវមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

– មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់សមមូលផ្នែកវិទ្យាសាស្រ្ត
– មានបទពិសោធន៍ទាក់ទងនឹងការគ្រប់គ្រងបរិស្ថានទូទៅយ៉ាងតិច០៥ឆ្នាំ
– មានបទពិសោធន៍ទាក់ទងនឹងការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថានយ៉ាងតិច០៥ឆ្នាំ
– មានសមត្ថភាពបច្ចេកទេសខ្ពស់ក្នុងការសិក្សាស្រាវជ្រាវ វិភាគ និងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬជំនាញបរិស្ថាន ព្រៃឈើ ជលផល សំណង់។ល។

អ្នកជំនាញការបច្ចេកទេស ត្រូវមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

– មានបរិញ្ញាបត្រសមមូលផ្នែកវិទ្យាសាស្រ្ត
– មានបទពិសោធន៍ពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថានទូទៅយ៉ាងតិច ០៣ឆ្នាំ
– មានបទពិសោធន៍ពាក់ព័ន្ធនឹងការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថានយ៉ាងតិច០៣ឆ្នាំ
– មានវិញ្ញាបនបត្របញ្ជាក់ការបណ្តុះបណ្តាលស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
– មានសមត្ថភាពបច្ចេកទេសខ្ពស់ក្នុងការសិក្សាស្រាវជ្រាវ វិភាគ និងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬជំនាញបរិស្ថាន ព្រៃឈើ ជលផល សំណង់។ល។

អ្នកជំនួយការបច្ចេកទេសរបស់ក្រុមហ៊ុនទីប្រឹក្សា ត្រូវមានលកខណៈវិនិច្ឆ័យដូចតទៅ៖

– មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ ឬសញ្ញាបត្រសមមមូលផ្នែកវិទ្យាសាស្រ្ត
– មានបទពិសោធន៍ពាក់ព័ន្ធនឹងការងារបរិស្ថានយ៉ាងតិច០១ឆ្នាំ
– មានវិញ្ញាបនបត្របញ្ជាក់ការបណ្តុះបណ្តាលស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
– មានការយល់ដឹងទូទៅស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

### ៤.២.២. លក្ខខណ្ឌដែលក្រុមហ៊ុនទីប្រឹក្សាត្រូវបំពេញ

ក្រៅពីលក្ខណៈវិនិច្ឆ័យខាងលើ ដើម្បីបានចុះបញ្ជី និងទទួលស្គាល់ពីក្រសួងបរិស្ថាន ក្រុមហ៊ុនទីប្រឹក្សាត្រូវបំពេញលក្ខខណ្ឌដូវខាងក្រោម[56]៖

- ពាក្យស្នើសុំ
- លិខិតចុះបញ្ជីពាណិជ្ជកម្មដែលចេញដោយក្រសួងពាណិជ្ជកម្ម
- លិខិតបញ្ជាក់ទីតាំងការិយាល័យក្រុមហ៊ុនអាជ្ញាធរមូលដ្ឋាន
- លក្ខន្តិកៈក្រុមហ៊ុន
- រចនាសម្ព័ន្ធក្រុមហ៊ុន
- សារវតាក្រុមហ៊ុន
- ឯកសារពាក់ព័ន្ធ និងបទពិសោធន៍ផ្សេងៗ។

ក្រសួងបរិស្ថាននឹងផ្តល់វិញ្ញាបនបត្រទទួលស្គាល់ ដែលមានសុពលភាពសម្រាប់រយៈពេល ០៥ឆ្នាំ ដល់ក្រុមហ៊ុនទីប្រឹក្សា ដែលបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យដូចខាងលើ។

ក្រៅពីនេះក្រសួងក៏បានចងនូវករណីមួយចំនួនដូចខាងក្រោម៖

- វិញ្ញាបនបត្រទទួលស្គាល់ក្រុមហ៊ុនទីប្រឹក្សា ត្រូវបានព្យួរពីរយៈពេល០៦ខែ ដល់៣ឆ្នាំក្នុងករណីដូចខាងក្រោម៖
  - ក្រុមហ៊ុនមានការធ្វេសប្រហែសនៅពេលចុះសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម
  - ក្រុមហ៊ុនបានចម្លងទិន្នន័យពីឯកសារ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមផ្សេងៗ ដោយគ្មានឯកសារយោង
  - ក្រុមហ៊ុនខកខានមិនបានជូនដំណឹងមកក្រសួងក្នុងករណីមានការផ្លាស់ប្តូរសមាសភាពសំខាន់ ដែលមានក្នុងលក្ខណៈវិនិច្ឆ័យខាងលើ។
- វិញ្ញាបនបត្រទទួលស្គាល់ក្រុមហ៊ុនទីប្រឹក្សាត្រូវបានលុបចោលក្នុងករណីដូចខាងក្រោម៖
  - ក្រុមហ៊ុនមានកំហុសចេតនាដោយមិនបង្ហាញពីហេតុប៉ពាល់វិជ្ជមាន និងអវិជ្ជមានតាមលទ្ធផលជាក់ស្តែងនៃការសិក្សា

[56] ប្រកាសលេខ ២១៥ប្រកប.ស្ត ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការចុះបញ្ជីក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

- របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម គ្មានគុណភាព និង/ឬមានបាតុភូតកុហក ក្លែងបន្លំធ្ងន់ធ្ងរ ដែលបណ្តាលអោយខូចខាតផលប្រយោជន៍ជាតិ
- ក្រុមហ៊ុនទីប្រឹក្សា ត្រូវបានផ្តន្ទាទោសពីបទព្រហ្មទណ្ឌ។

ក្រុមហ៊ុនទីប្រឹក្សាមិនអាចដាក់ពាក្យស្នើសុំចុះបញ្ជីទទួលស្គាល់ឡើងវិញ ក្នុងរយៈពេលប្រាំឆ្នាំ បន្ទាប់ពីវិញ្ញាបនបត្រទទួលស្គាល់ត្រូវបានលុបចោល។

តារាង១: បញ្ជីឈ្មោះក្រុមហ៊ុនទីប្រឹក្សាសំរាប់ការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

| ល.រ | ឈ្មោះ | លិខិតអនុញ្ញាត | | |
|---|---|---|---|---|
| | | លេខ | | កាលបរិច្ឆេទ |
| 1 | E & A CONSULTANT CO., LTD. | 358 | សជណ.បស្ត | 01-07-2014 |
| 2 | CES CO., LTD. | 359 | សជណ.បស្ត | 01-07-2014 |
| 3 | PPIC CO., LTD. | 517 | សជណ.បស្ត | 17-07-2014 |
| 4 | S B K RESEARCH AND DEVELOPMENT CO., LTD. | 518 | សជណ.បស្ត | 18-07-2014 |
| 5 | CEATIVE GREEN DESIGN CO., LTD. | 551 | សជណ.បស្ត | 01-08-2014 |
| 6 | ENVIROTECH SERVICE CO., LTD. | 561 | សជណ.បស្ត | 04-08-2014 |
| 7 | GREEN ENVIRONMENT GROUP CO., LTD. | 571 | សជណ.បស្ត | 05-08-2014 |
| 8 | SAWAC CONSULTANTS( CAMBODIA ) CO., LTD | 578 | សជណ.បស្ត | 06-08-2014 |
| 9 | RCRCC CO., LTD | 727 | សជណ.បស្ត | 03-10-2014 |
| 10 | ឃី ខនសាល់ធិន(ខេមបូឌា) | 582 | សជណ.បស្ត | 29-06-2015 |
| 11 | SUSTINAT GREEN CO., LTD | 687 | សជណ.បស្ត | 28-07-2015 |
| 12 | G I G BUSINESS INVESTMENT CAMBODIA CO., LTD | 1005 | សជណ.បស្ត | 26-10-2015 |
| 13 | ព្រៃក្តូច ឌីវេឡុបមិន ខនសាល់ធិនស៊ី | 1345 | សជណ.បស្ត | 31-12-2015 |
| 14 | ប៊ីចល អ៊ិនវ៉ាយរ៉ិនមិនថល សឺលូសិន ឯ.ក | 810 | សជណ.បស្ត | 22-08-2015 |
| 15 | ខេមបូ ខនសាល់ធេន អ៊ិនធើណេសិនណល(ស៊ីស៊ីអាយ) | 894 | សជណ.បស្ត | 08-09-2017 |

*ដកស្រង់ពីសៀវភៅកម្រងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលរៀបចំដោយនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន របស់ក្រសួងបរិស្ថាន*

## ៤.៣. ប្រភេទនៃគម្រោងដែលត្រូវវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានបែងចែកជា០៤(បួន)វិស័យគឺៈ

- វិស័យឧស្សាហកម្ម និងសុខាភិបាល
- វិស័យរ៉ែ និងថាមពល
- វិស័យកសិកម្ម និងធនធានទឹក
- វិស័យហេដ្ឋារចនាសម្ព័ន្ធ និងទេសចរណ៍។

តារាងទី២ : ចំណាត់ថ្នាក់គម្រោងដែលតម្រូវអោយវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

| **ល.រ** | **ប្រភេទអាជីវកម្ម** | **ទំហំ** |
|---|---|---|
| **១** | **វិស័យឧស្សាហកម្ម** | |
| ១.១ | មូលដ្ឋានកែច្នៃម្ហូបអាហារ និងគ្រឿងកំប៉ុង | ≥៥០០ តោន/ឆ្នាំ |
| ១.២ | មូលដ្ឋានផលិតភេសជ្ជៈ-ទឹកផ្លែឈើគ្រប់ប្រភេទ | ≥១.៥០០ លីត្រ/ថ្ងៃ |
| ១.៣ | មូលដ្ឋានផលិតដំណាប់ផ្លែឈើ | ≥៥០០ តោន/ឆ្នាំ |
| ១.៤ | មូលដ្ឋានផលិតទឹកក្រូច | គ្រប់ទំហំ |
| ១.៥ | មូលដ្ឋានផលិតស្រា | គ្រប់ទំហំ |
| ១.៦ | មូលដ្ឋានផលិតស្រាបៀរ-អាល់កុល | គ្រប់ទំហំ |
| ១.៧ | មូលដ្ឋានផលិតទឹកស្អាត | ≥ ១០.០០០នាក់ប្រើប្រាស់ |
| ១.៨ | មូលដ្ឋានផលិតបារី | ≥ ១០.០០០ កញ្ចប់/ថ្ងៃ |
| ១.៩ | មូលដ្ឋានផលិត និងកែច្នៃសន្លឹកថ្នាំជក់ | ≥ ៣៥០ តោន/ឆ្នាំ |
| ១.១០ | មូលដ្ឋានផលិតស្ករស | ≥ ៣.០០០ តោន/ឆ្នាំ |
| ១.១១ | មូលដ្ឋានកិនស្រូវ និងគ្រាប់ធញ្ញជាតិ | ≥ ៣.០០០ តោន/ឆ្នាំ |
| ១.១២ | មូលដ្ឋានផលិតទឹកត្រី - ទឹកស៊ីអ៊ីវ - សៀង - ម្ទេស - ប៉េងប៉ោះ | ≥៥០០.០០០ លីត្រ/ឆ្នាំ |
| ១.១៣ | រោងចក្រតម្បាញ - ជ្រលក់ពណ៌ | គ្រប់ទំហំ |
| ១.១៤ | រោងចក្រកាត់ដេរ - បោកគក់ - បោះពុម្ព - ជ្រលក់ពណ៌ | គ្រប់ទំហំ |

| | | |
|---|---|---|
| ១.១៥ | រោងចក្រសំលាប់ស្បែក - កែច្នៃស្បែក - ធ្វើការស្បែកគោក្របី | គ្រប់ទំហំ |
| ១.១៦ | រោងចក្រផលិតអេប៉ុង - កៅស៊ូមូស | គ្រប់ទំហំ |
| ១.១៧ | រោងចក្រក្តារបន្ទះ | ≥ ១០០.០០០ ម$^{៣}$/ឆ្នាំ ឈើមូល |
| ១.១៨ | មូលដ្ឋានផលិតគ្រឿងសង្ហារឹម | ≥ ១ .០០០ម$^{៣}$/ឆ្នាំឈើមូល |
| ១.១៩ | រោងចក្រអារឈើ | ≥ ៥០ .០០០ម$^{៣}$/ឆ្នាំឈើមូល |
| ១.២០ | រោងចក្រផលិតក្រដាស | គ្រប់ទំហំ |
| ១.២១ | រោងចក្រផលិតម្សៅក្រដាស និងកែច្នៃក្រដាស | គ្រប់ទំហំ |
| ១.២២ | រោងចក្រប្លាស្ទិក | គ្រប់ទំហំ |
| ១.២៣ | រោងចក្រកៅស៊ូកង់ និងពោះវៀនកង់គ្រប់ប្រភេទ | ≥៥០០ តោន/ឆ្នាំ |
| ១.២៤ | រោងចក្រកៅស៊ូក្រែប | ≥ ១.០០០ តោន/ឆ្នាំ |
| ១.២៥ | រោងចក្រផលិតអាគុយ និងថ្មពិល | គ្រប់ទំហំ |
| ១.២៦ | រោងចក្រគីមី | គ្រប់ទំហំ |
| ១.២៧ | រោងចក្រផលិតជីគីមី | ≥ ១០.០០០ តោន/ឆ្នាំ |
| ១.២៨ | រោងចក្រផលិតថ្នាំសម្លាប់សត្វល្អិត | គ្រប់ទំហំ |
| ១.២៩ | រោងចក្រថ្នាំលាបគ្រប់ប្រភេទ | គ្រប់ទំហំ |
| ១.៣០ | រោងចក្រគីមីប្រេងកាត | គ្រប់ទំហំ |
| ១.៣១ | រោងចក្រផលិតម្សៅសាប៊ូ - សាប៊ូដុំ - សាប៊ូទឹក | គ្រប់ទំហំ |
| ១.៣២ | រោងចក្រស៊ីម៉ងត៍ | គ្រប់ទំហំ |
| ១.៣៣ | រោងចក្រចំរាញ់ប្រេងកាត | គ្រប់ទំហំ |
| ១.៣៤ | រោងចក្រផលិតឧស្ម័ន | គ្រប់ទំហំ |
| ១.៣៥ | សំណង់បង្ហូរប្រេង និងឧស្ម័ន | ≥ ២ គ.ម |
| ១.៣៦ | កន្លែងផ្ទុកប្រេងឥន្ទនៈសម្រាប់ចែកចាយ | ≥ ១.០០០.០០០ លីត្រ |

| | | |
|---|---|---|
| ១.៣៧ | ស្ថានីយប្រេងឥន្ធនៈ | ≥ ២០.០០០ លីត្រ |
| ១.៣៨ | ការធ្វើអាជីវកម្មរ៉ែ | គ្រប់ទំហំ |
| ១.៣៩ | រោងចក្រផលិតកែវ - ដបគ្រប់ប្រភេទ | គ្រប់ទំហំ |
| ១.៤០ | មូលដ្ឋានផលិតក្បឿង | ≥ ១៥០.០០០ ដុំ/ខែ |
| ១.៤១ | មូលដ្ឋានផលិតឥដ្ឋក្រាល - ឥដ្ឋការ៉ូ | ≥ ៩០.០០០ ដុំ/ខែ |
| ១.៤២ | រោងចក្រផលិតថ្មស្អុយ | គ្រប់ទំហំ |
| ១.៤៣ | មូលដ្ឋានផលិតគ្រឿងសំណង់បេតុង | ≥ ៩០០ តោន/ខែ |
| ១.៤៤ | រោងចក្រផលិតខ្លាញ់គោ - ប្រេងម៉ាស៊ីន | គ្រប់ទំហំ |
| ១.៤៥ | ការសិក្សាស្រាវជ្រាវអាជីវកម្មរ៉ែប្រេងកាត(ការខួងសាកល្បង, ការធ្វើឱ្យរញ្ជួយដី) | គ្រប់ទំហំ |
| ១.៤៦ | រោងចក្រផលិតគ្រឿងយន្ត | គ្រប់ទំហំ |
| ១.៤៧ | រោងចក្រតម្លើងគ្រឿងយន្ត | គ្រប់ទំហំ |
| ១.៤៨ | សហគ្រាសជួសជុលគ្រឿងយន្ត និងនាវា | គ្រប់ទំហំ |
| ១.៤៩ | រោងចក្រកែច្នៃលោហៈគ្រប់ប្រភេទ - ដែកគោល - បន្លាលួស - សំណាញ់ | ≥ ៣០០ តោន/ខែ |
| ១.៥០ | រោងចក្រស្លដែក - ដែកថែប - អាលុយមីនីញ៉ូម | គ្រប់ទំហំ |
| ១.៥១ | រោងចក្រស្លលោហៈគ្រប់ប្រភេទ | គ្រប់ទំហំ |
| ១.៥២ | មូលដ្ឋានកែច្នៃសំណល់ - ដុតសំណល់ | គ្រប់ទំហំ |
| ១.៥៣ | មូលដ្ឋានសំអាតទឹកសំអុយ | គ្រប់ទំហំ |
| ១.៥៤ | រោងចក្រអគ្គិសនី | ≥ ៥ MW |
| ១.៥៥ | រោងចក្រវារីអគ្គិសនី | ≥ ១ MW |
| ១.៥៦ | រោងចក្រផលិតសំឡី | ≥ ១៥ តោន/ខែ |
| ១.៥៧ | រោងចក្រផលិតចំណីសត្វ | ≥ ១០.០០០ តោន/ឆ្នាំ |
| **២** | **វិស័យកសិកម្ម** | |
| ២.១ | ព្រៃសម្បទាន | ≥ ១០.០០០ ហិចតា |

| | | |
|---|---|---|
| ២.២ | អាជីវកម្មព្រៃគប់ | ≥ ៥០០ ហិចតា |
| ២.៣ | ផ្ទៃដីដែលមានព្រៃឈើ | ≥ ៥០០ ហិចតា |
| ២.៤ | ផ្ទៃដីដំណាំកសិកម្ម - ឧស្សាហកម្ម | ≥ ១០.០០០ ហិចតា |
| ២.៥ | ផ្ទៃដីលិចទឹក និងដីតំបន់ឆ្នេរ | គ្រប់ទំហំ |
| ២.៦ | ប្រព័ន្ធស្រោចស្រព | ≥ ៥.០០០ ហិចតា |
| ២.៧ | ប្រព័ន្ធរំដោះទឹក | ≥ ៥.០០០ ហិចតា |
| ២.៨ | ដៃនេសាទ | គ្រប់ទំហំ |
| **៣** | **វិស័យទេសចរណ៍** | |
| ៣.១ | តំបន់ទេសចរណ៍ | ≥ ៥០ ហិចតា |
| ៣.២ | ទីលានវាយកូនគោល | ≥ ១៨ រន្ធ |
| **៤** | **ហេដ្ឋារចនាសម្ព័ន្ធ** | |
| ៤.១ | ការអភិវឌ្ឍទីក្រុង | គ្រប់ទំហំ |
| ៤.២ | តំបន់ឧស្សាហកម្ម | គ្រប់ទំហំ |
| ៤.៣ | សំណង់ស្ពានថ្នល់ | ទ្រទំងន់ ≥ ៣០ តោន |
| ៤.៤ | សំណង់អាគារ | កំពស់ ≥១២ ម. ឬ<br>ក្រឡាផ្ទៃ ៨.០០០ ម$^{២}$ |
| ៤.៥ | ភោជនីយដ្ឋាន | ≥ ៥០០ កៅអី |
| ៤.៦ | សំណង់សណ្ឋាគារ | ≥ ៦០ បន្ទប់ |
| ៤.៧ | សំណង់សណ្ឋាគារតំបន់ឆ្នេរ | ≥ ៨០ បន្ទប់ |
| ៤.៨ | សំណង់ផ្លូវជាតិ | ≥ ១០០ គ.ម |
| ៤.៩ | សំណង់ផ្លូវដែក | គ្រប់ទំហំ |
| ៤.១០ | សំណង់កំពង់ផែ | គ្រប់ទំហំ |
| ៤.១១ | សំណង់អាកាសយានដ្ឋាន | គ្រប់ទំហំ |
| ៤.១២ | ការបូមភក់ - ល្បាប់ | ≥ ៥០.០០០ ម$^{៣}$ |
| ៤.១៣ | កន្លែងចាក់សំរាមទីក្រុង | ≥ ប្រជាជន ២០០.០០០ នាក់ |

*ដកស្រង់ពី តារាងឧបសម្ព័ន្ធនៃ អនុក្រឹត្យលេខ៧២អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន*

## ៤.៤. កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

### ៤.៤.១. គម្រោងស្នើសុំ

ក្នុងដំណាក់កាលដំបូង ម្ចាស់គម្រោង/ក្រុមហ៊ុនវិនិយោគត្រូវលើកយកគម្រោងវិនិយោគរបស់ខ្លួនមកពិភាក្សាជាមួយក្រសួងបរិស្ថាន ឬមន្ទីបរិស្ថានរាជធានី-ខេត្ត(ចំពោះគម្រោងដែលមានទុនវិនិយោគក្រោមពីរលានដុល្លាអាមេរិក) ដោយភ្ជាប់មកនូវឯកសារទាក់ទងនឹងទីតាំងគម្រោង និងឯកសារពាក់ព័ន្ធនានា។

អ្វីដែលម្ចាស់គម្រោងចង់ដឹងក្នុងដំណាក់កាលនេះ តើគម្រោងវិនិយោគដែលក្រុមហ៊ុនបានស្នើមកក្រសួងបរិស្ថាន/មន្ទីបរិស្ថានត្រូវបំពេញកាតព្វកិច្ចច្បាប់អ្វីខ្លះ?

ដូចនេះក្រសួងបរិស្ថាន ឬមន្ទីបរិស្ថានបានធ្វើការផ្ទៀងផ្ទាត់ និងជ្រើសរើសគម្រោងទៅតាមលក្ខខណ្ឌមួយចំនួនដូចចំណុចខាងក្រោម។

### ៤.៤.២. ការជ្រើសរើសគម្រោង

ជាទូទៅ ការជ្រើសរើសគម្រោង ត្រូវកំណត់ដោយក្រសួងបរិស្ថាន ដូចបានបង្ហាញនៅចំណុច**៤.៣**ខាងលើ។ ករណីដែលគម្រោងវិនិយោគទាំងនោះមិនមានបញ្ជាក់នៅក្នុងចំណុចខាងលើនេះ ក្រសួងអាចប្រើប្រាស់តារាងកំណត់ទំហំហេតុប៉ះពាល់ជំនួស។ តារាងកំណត់ទំហំនេះបង្ហាញឲ្យដឹងពីគម្រោងមួយត្រូវធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន រឺមិនតម្រូវអោយវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដូចមានបញ្ជាក់លម្អិតខាងក្រោម៖

- តម្រូវអោយម្ចាស់គម្រោងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញចំពោះ គម្រោងដែលមានការប៉ះពាល់បរិស្ថានធ្ងន់ធ្ងរ ឬ
- តម្រូវអោយម្ចាស់គម្រោងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាដំបូងចំពោះគម្រោង ដែលមានហេតុប៉ះពាល់បរិស្ថានមធ្យម ឬ
- ពុំតម្រូវអោយវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចំពោះគម្រោងទាំងបីប្រភេទដូចខាងក្រោម៖
    - គម្រោងដែលរដ្ឋាភិបាលកំណត់ថាជាប្រភេទគម្រោងពិសេស ឬបន្ទាន់
    - តម្រូវអោយមានការរៀបចំផែនការគ្រប់គ្រងបរិស្ថាន
    - តម្រូវអោយរៀបចំកិច្ចសន្យាការពារបរិស្ថានចំពោះគម្រោងដែលមានហេតុប៉ះពាល់អវិជ្ជមានតិចតួច ដូចជារោងចក្រកាត់ដេរសម្លៀកបំពាក់ជាដើម។

### ៤.៤.៣. ការកំណត់វិសាលភាព

ការកំណត់វិសាលភាព គឺជាដំណាក់កាលដំបូងនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន បន្ទាប់ពីការជ្រើសរើសគម្រោងបានបញ្ចប់។ ដំណាក់កាលកំណត់វិសាលភាពនេះមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញដើម្បីកំណត់បានសមាសភាគមួយចំនួនដូចជា៖

- កំណត់ប៉ារ៉ាម៉ែត្រដែលត្រូវសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាន
- កំណត់ និងផ្តល់ពតិមានដល់អ្នកពាក់ព័ន្ធ
- កំណត់វិសាលភាពនៃការសិក្សា
- ឯកភាពលើវិធីសាស្ត្រនសការចូលរួមជាសាធារណៈ និងវិធីសាស្ត្រនៃការសិក្សា
- កំណត់ពីសញ្ញាណនៃហេតុប៉ះពាល់ដើម្បីធ្វើការសិក្សា
- បង្កើតអោយមានលក្ខខណ្ឌការងារ។

ភាគីពាក់ព័ន្ធក្នុងដំណាក់កាលកំណត់វិសាលភាពនេះមានដូចជា៖

- ក្រសួងបរិស្ថាន
- ម្ចាស់គម្រោង
- ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងអ្នកជំនាញនានា
- ភ្នាក់ងារទទួលខុសត្រូវផ្សេងទៀត
- សាធារណជនដែលទទួលរងផលប៉ះពាល់
- សាធារណជនដែលទទួលបានផលប្រយោជន៍ពីគម្រោង។

### ៤.៤.៤. ការវិភាគហេតុប៉ះពាល់បរិស្ថាន

ក្នុងការវិភាគពីហេតុប៉ះពាល់បរិស្ថាន និងដំណាក់កាលវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញគឺតម្រូវអោយមានការវិភាគលើបីចំណុចគឺ៖

១. ការកំណត់ប្រភេទនៃហេតុប៉ះពាល់

២. ការព្យាករណ៍អំពីទំហំដែលកើតមានឡើង និងវិសាលភាពនៃហេតុប៉ះពាល់

៣. ការកំណត់ពីសញ្ញាណនៃហេតុប៉ះពាល់។

ចំណាំ៖ហេតុប៉ះពាល់បរិស្ថាននាំអោយមានការផ្លាស់ប្តូរទម្រង់បរិស្ថាន ដែលមានស្រាប់ ហើយហេតុប៉ះពាល់ទាំងនោះអាចជាហេតុប៉ះពាល់ដោយផ្ទាល់ និងប្រយោល ឬជាបណ្តុំ។

### ៤.៤.៥. វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន

វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានជាសកម្មភាព ឬវិធានការជៀសវាង ឬធ្វើឱ្យមានការថយចុះនៃហេតុប៉ះពាល់បរិស្ថានអវិជ្ជមានពីសកម្មភាពគម្រោង។ វិធានការកាត់បន្ថយសំដៅទៅលើប្រព័ន្ធអេកូឡូស៊ី សេដ្ឋកិច្ច សង្គម និងវប្បធម៌។ ផែនការ និងការអនុវត្តគម្រោងអាចរួមបញ្ចូលនូវវិធានការជាច្រើនវិធីសាស្ត្រ ឬជាច្រើនជម្រើសដូចរៀបរាប់ខាងក្រោម៖

- ការរៀបចំផែនការលើទីតាំង ឬពេលវេលានៃសកម្មភាព ដើម្បីជៀសវាងឥទ្ធិពលលើធនធានជាក់លាក់មួយ ឬតំបន់ងាយទទួលរងការប៉ះពាល់
- បញ្ចូលនូវវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន នៅក្នុងដំណាក់កាលរចនាគម្រោង ឬធ្វើផែនការដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានជាមុន
- ធានារ៉ាប់រងរាល់កម្មវិធីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដែលកើតឡើងទន្ទឹមគ្នាជាមួយគម្រោង
- ធានារ៉ាប់រងលើកម្មវិធីកាត់បន្ថយ បន្ទាប់ពីសកម្មភាពស្តារនូវធនធានដែលប៉ះពាល់ ឬតំបន់ដែលទទួលរងការប៉ះពាល់ ឬជំនួសនូវអ្វីដែលបាត់បង់ ឬធនធានដែលខូចខាតនៅក្នុងតំបន់រងផលប៉ះពាល់ ឬតំបន់នានាដែលពាក់ព័ន្ធ។ ឧទាហរណ៍ ការបាត់បង់ប្រភេទត្រីទឹកសាបអាចកាត់បន្ថយ តាមរយៈការផ្តល់ពូជត្រី ឬការស្តារទន្លេដែលជាជម្រករបស់ត្រីជាដើម។

វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន អាចត្រូវបានកំណត់ក្នុងកំឡុងពេលមុនប្រតិបត្តិគម្រោង(ដំណាក់កាលរចនាគម្រោង និងសងសង់) ដំណាក់កាលប្រតិបត្តិគម្រោង និងដំណាក់កាលបញ្ចប់គម្រោងដោយត្រួតពិនិត្យទៅលើកត្តាសំខាន់ៗដូចខាងក្រោម៖

- លទ្ធផលនៃការពិគ្រោះយោបល់ជាសាធារណៈ ឬបទពិសោធន៍កន្លងមកផ្តល់ជាវិធានការកាត់បន្ថយដែលត្រូវបានកំណត់ភ្លាមៗ នៅក្នុងដំណាក់កាលរចនាគម្រោង និងការវាយតម្លៃនៃគម្រោងស្នើសុំ។
- វិធានការកាត់បន្ថយអាចត្រូវបានបង្កើតឡើងក្នុងការឆ្លើយតបទៅនឹងហេតុប៉ះពាល់ជាក់លាក់ដែលត្រូវបានកំណត់នៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងក្នុងដំណាក់កាលអនុវត្តគម្រោង។
- វិធានការអាចបង្កើតទៅជាការកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមាន រហូតដល់ការបញ្ចប់គម្រោង។

### ៤.៤.៦. ការរៀបចំរបាយការណ៍ហេតុប៉ះពាល់បរិស្ថាន

ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ម្ចាស់គម្រោង ឬក្រុមហ៊ុនទីប្រឹក្សាត្រូវចំណាយពេលយ៉ាងតិច០៣ខែ ដើម្បីសិក្សា និងប្រមូលទិន្នន័យដែលមានស្រាប់ (Secondary Data) ទាក់ទងនឹងធនធានរូបសាស្ត្រ និងធនធានជីវសាស្ត្រ ព្រមទាំងការពិគ្រោះយោបល់ជាមួយអាជ្ញាធមិដែនដី សហាគមន៍ជាតិ ប្រជាពលរដ្ឋរងការប៉ះពាល់ និងអ្នកពាក់ព័ន្ធនានា។ ដោយឡែកការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ម្ចាស់គម្រោង ឬក្រុមហ៊ុនទីប្រឹក្សាត្រូវចំណាយពេលចាប់ពី៦ខែឡើងទៅ ដើម្បីធ្វើការសិក្សា និងប្រមូលទិន្នន័យបឋម (Primary Data) ដែលទាក់ទងនឹងធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនឹងគម្រោង ដូចជាអាជ្ញាធរដែនដី អង្គភាពពាក់ព័ន្ធ សហាគមន៍មូលដ្ឋានប្រជាពលរដ្ឋទទួលរងការប៉ះពាល់ និងអ្នកពាក់ព័ន្ធនានា។

គំរូរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ៖

- សេចក្តីសង្ខេប
- សេចក្តីផ្តើម
- ក្របខណ្ឌច្បាប់
- ការពិពណ៌នាពីគម្រោង
- ការពិពណ៌នាពីធនធានបរិស្ថានដែលមានស្រាប់
- ការចូលរួមជាសាធារណៈ
- ការវាយតម្លៃហេតុប៉ះណាល់បរិស្ថាន និងវិធានការកាត់បន្ថយ
- ផែនការគ្រប់គ្រងបរិស្ថាន
- ការវិភាគពីការខូចខាតបរិស្ថាន និងផលចចំណេញផ្នែកសេដ្ឋកិច្ច (សម្រាប់តែរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ)
- សេចក្តីសន្និដ្ឋាន និងអនុសាសន៍។

### ៤.៤.៧. ការពិនិត្យ និងធ្វើសេចក្តីសម្រេចលើរបាយការណ៍

ជាគោលការណ៍ច្បាប់ ក្រសួងបរិស្ថានមានតួនាទីជាអ្នកពិនិត្យលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផ្តល់ការឯកភាព ឬមិនឯកភាពលើរបាយការណ៍នេះ។

រយៈពេលនៃការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៃគម្រោងអភិវឌ្ឍន៍មានរយៈពេល៣០ថ្ងៃនៃថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលក្រសួងបរិស្ថានបានទទួលរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ និងរបាយការណ៍បុរេ/សមិទ្ធិលទ្ធភាពគម្រោង។

នីតិវិធីក្នុងការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញនៅក្រសួបរិស្ថានមានដូចជាៈ

- កិច្ចប្រជុំរបស់មន្ត្រីជំនាញរបស់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការចុះពិនិត្យទីតាំងជាក់ស្តែង
- កិច្ចប្រជុំអន្តរនាយកដ្ឋានរបស់ក្រសួងបរិស្ថាន
- កិច្ចប្រជុំអន្តរក្រសួងដែលមានការចូលរួមពីក្រសួង/ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនឹងគម្រោងវិនិយោគដោយមាន **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន** ជាប្រធានអង្គប្រជុំ
- ជាចុងក្រោយនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានរៀបចំលិខិតផ្តល់យោបល់ដោយបញ្ចូលនូវមតិយោបល់ដែលទទួលបានពីអង្គប្រជុំទាំងបួនខាងលើ ដើម្បីអោយម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាកែតម្រូវឡើងវិញនូវរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

### ៤.៤.៨. ការអង្កេតតាមដានគម្រោង

ជាបន្តទៅទៀត ម្ចាស់គម្រោងត្រូវអនុវត្តទៅតាមផែនការគ្រប់គ្រងបរិស្ថានដែលមានចែងនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ការអង្កេតតាមដានគម្រោងត្រូវពិនិត្យទៅលើហេតុប៉ះពាល់ ការផ្ទៀងផ្ទាត់នៃការព្យាករ និងការឆ្លើយតបទៅនឹងវិធានការកាត់បន្ថយដូច ដែលមានបញ្ជាក់នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ មួយវិញទៀតម្ចាស់គម្រោងត្រូវរៀបចំរបាការណ៍ត្រួតពិនិត្យបរិស្ថានរៀងរាល់០៣ខែ ឬ០៦ខែម្តង មកនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន។

ក្នុងករណីដែលម្ចាស់គម្រោងមិនអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថាន ក្រសួងបរិស្ថានសហការជាមួយក្រសួង/ស្ថាប័នពាក់ព័ន្ធ ដើម្បីបញ្ឈប់សកម្មភាពដែលកំពុងដំណើរការ ឬមានស្រាប់របស់គម្រោងទៅតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

# ជំពូកទី៥
# តួនាទីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមកលើការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា

## ៥.១. ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់រោងចក្រ និងសិប្បកម្ម

គំរូលក្ខខណ្ឌការងារនេះកំណត់នូវសកម្មភាពគម្រោង ទំហំ និងវិធីសាស្ត្រនៃការសិក្សា និងទម្រង់នៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង សម្រាប់ប្រើប្រាស់នៅក្នុងក្របខណ្ឌក្រសួងបរិស្ថាន ម្ចាស់គម្រោង ក្រុមហ៊ុនទីប្រឹក្សា និងអ្នកពាក់ព័ន្ធដែលជាប់ទាក់ទងនឹងគម្រោងបង្កើតរោងចក្រ និងសិប្បកម្ម។

### ៥.១.១. សេចក្តីផ្តើម

ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវធ្វើការរៀបរាប់នូវចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ចក្ខុវិស័យ ទស្សនទាន និងគោលបំណងវិនិយោគក្នុងការចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិលើ

  វិស័យឧស្សាហកម្ម
- កាតព្វកិច្ចច្បាប់ដែលតម្រូវឱ្យក្រុមហ៊ុនវិនិយោគរៀបចំលក្ខខណ្ឌការងារសម្រាប់ការសិក្សារៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង
- សារៈសំខាន់នៃលក្ខខណ្ឌការងារក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងសម្រាប់គម្រោងអភិវឌ្ឍន៍វិស័យរោងចក្រ និងសិប្បកម្ម។

### ៥.១.២. គោលបំណងនៃលក្ខខណ្ឌការងារ

គោលបំណងសំខាន់ៗនៃលក្ខខណ្ឌការងារនេះគឺ៖

- ជាផែនទីបង្ហាញផ្លូវដើម្បីរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងប្រកបដោយគុណភាព និងសុក្រិតភាព

- កំណត់ទំហំ និងវិធីសាស្ត្រក្នុងការសិក្សាទៅលើធនធានបរិស្ថានមានស្រាប់ដូចជាធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម
- កំណត់នូវអ្នកពាក់ព័ន្ធ និងសាធារណជនដើម្បីធ្វើការពិគ្រោះយោបល់
- កំណត់នូវទម្រង់របាយការណ៍ហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង សមាសភាពក្រុមអ្នកសិក្សា និងតារាងផែនការនៃការសិក្សា។

### ៥.១.៣. ការពិពណ៌នាគម្រោង

ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវបង្ហាញពី៖

- គោលបំណង និងអត្ថប្រយោជន៍នៃការវិនិយោគ
- ប្រវត្តិ និងបទពិសោធន៍របស់ក្រុមហ៊ុនពាក់ព័ន្ធនឹងការអនុវត្តគម្រោង
- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងគម្រោង
- ប្រភេទគម្រោងវិនិយោគ (វិស័យសាធារណៈ ឬវិស័យឯកជន ឬដៃគូរអភិវឌ្ឍន៍)
- ទុនវិនិយោគ និងអ្នកទទួលខុសត្រូវ
    - ដើមទុនចុះបញ្ជីពាណិជ្ជកម្ម
    - ដើមទុនវិនិយោគសរុប
    - សមាជិកភាគហ៊ុនទទួលខុសត្រូវ
    - រចនាសម្ព័ន្ធគ្រប់គ្រង
- ទីតាំងភូមិសាស្ត្រ៖ បង្ហាញទីតាំងភូមិសាស្ត្រ ព្រំប្រទល់ ទំហំផ្ទៃដីគម្រោង និងទីតាំងគម្រោងធៀបនឹងតំបន់សំខាន់ៗ ដោយភ្ជាប់ផែនទីរដ្ឋបាល (ប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum QGS 1984 និងចំណុចនិយាមកា) និងផែនទីGoogle Earth
- ផែនការវិនិយោគគម្រោង (វដ្ត និងរយៈពេលនៃគម្រោង)
- ផែនការបែងចែកផ្ទៃដីសម្រាប់គម្រោង (ភ្ជាប់ប្លង់ស្ថាបត្យកម្ម និងប្លង់បែងចែកការប្រើប្រាស់ដីជាក់ស្តែង)
- ផែនការផលិតផល និងខ្សែសង្វាក់ផលិតកម្ម៖
    - ផែនការផលិត និងទីផ្សារផ្គត់ផ្គង់ (បរិមាណគិតជាខែ និងឆ្នាំ)
    - សង្វាក់ផលិតកម្ម (ករណីជាម៉ាស៊ីនត្រូវបញ្ជាក់ពីកម្លាំង និងសមត្ថភាពផលិត)
- តម្រូវការគ្រឿងចក្រ ឧបករណ៍ សម្ភារៈ និងបរិក្ខារផ្សេងៗ

– តម្រូវការវត្ថុធាតុដើម
– តម្រូវការសារធាតុគីមី ឬ សារធាតុបន្សំ
– តម្រូវការប្រើប្រាស់អគ្គិសនី (បញ្ជាក់ប្រភព និងបរិមាណ)
  - អគ្គិសនីរដ្ឋ ឬ ឯកជន (កម្លាំងប្រើប្រាស់)
  - ម៉ាស៊ីនភ្លើង (ចំនួន និងកម្លាំង)
  - ថាមពលអគ្គិសនីប្រើបដោយពន្លឺព្រះអាទិត្យ ក្នុងករណីបើមាន (កម្លាំងផលិត)
  - ឡចំហាយ និងឡដុតធ្យូងថ្ម (បង្ហាញពីដំណើរការសង្ខេប និងបញ្ជាក់ពីលក្ខណៈបច្ចេកទេស និងអ្នកឯកទេស)
  - ប្រើប្រាស់ថាមពល ប្រេងឥន្ធនៈ ធ្យូងថ្ម ជីវៈឥន្ធនៈ (បញ្ជាក់ប្រភព បរិមាណ និងប្រភេទ)
– តម្រូវការប្រើប្រាស់ទឹក (បញ្ជាក់ពីប្រភព បរិមាណ និងការប្រើប្រាស់)
– តម្រូវការកម្លាំងពលកម្ម (ចំនួន តួនាទី ជនជាតិ និងប្រាក់បៀវត្ស)
– ការគ្រប់គ្រងសំណល់រឹង-រាវ ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេងនិងរំញ័រ
  - សំណល់រាវ (ប្រភពបញ្ចេញ បរិមាណ ការសម្អាត និងបង្ហូរចេញ)
  - សំណល់រឹង (បរិមាណទៅតាមប្រភេទនីមួយៗ)
  - សំណល់គ្រោះថ្នាក់ (សំណល់ភក់-ផេះ ធុងគីមី ថ្នាំពណ៌-គីមី ជាដើម)
  - ធូលី
  - ផ្សែង និងឧស្ម័ន
  - សំឡេង និងរំញ័រ
  - បរិយាកាសក្នុងអគារផលិតកម្ម
– ការគ្រប់គ្រងហានិភ័យ សុវត្ថិភាពការងារ សុខភាពបុគ្គល-កម្មករ និងសុខភាពសាធារណៈ
  - ប្រព័ន្ធការពារសុវត្ថភាព និងទប់ស្កាត់អគ្គីភ័យ
  - ការដាក់ស្លាកសញ្ញាគ្រោះថ្នាក់
  - ការអប់រំ បណ្តុះបណ្តាលអំពីសង្គ្រោះ ជម្លៀសខ្លួន និងសុវត្ថិភាពក្នុងការងារ
  - ពេទ្យប្រចាំការ និងគិលានដ្ឋាន
– តារាងសង្ខេបពីពេលវេលាសកម្មភាពគម្រោង។

### ៥.១.៤. ទំហំ និងវិធីសាស្ត្រនៃការសិក្សា

#### ៥.១.៤.១. ធនធានបរិស្ថាន

ការកំណត់ទំហំ និងវិធីសាស្ត្រនៃការសិក្សារបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវសិក្សាវាយតម្លៃលើធនធានបរិស្ថានមានស្រាប់ ដែលគ្របដណ្តប់លើផ្ទៃដីរបស់គម្រោង និងនៅជុំវិញទីតាំងគម្រោងដូចជា ធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម។ ក្នុងការប្រមូលទិន្នន័យ ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវផ្តែកលើះ

ទិន្នន័យបន្ទាប់បន្សំ៖ ត្រូវប្រមូល និងដកស្រង់ចេញពីឯកសារបច្ចេកទេសរបស់គម្រោងសំខាន់ៗរួមមាន របាយការណ៍បច្ចេកទេសរបស់ក្រុមហ៊ុន ផែនការមេ និងឯកសារពាក់ព័ន្ធនានា។

ទិន្នន័យបឋម៖ ត្រូវធ្វើការចុះសិក្សា អង្កេតជាក់ស្តែងនៅក្នុង និងជុំវិញទីតាំងគម្រោង ដោយផ្តោតសំខាន់ទៅលើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម ព្រមទាំងប្រើប្រាស់នូវវិធីសាស្ត្រលម្អិត និងមានលក្ខណៈវិទ្យាសាស្ត្រ។

ក. ធនធានរូបសាស្ត្រ

- ដី

– សណ្ឋានដី/ឋានលេខា៖ ត្រូវសិក្សាអំពីរយៈកម្ពស់ និងចំណាត់ថ្នាក់ទីជម្រាលដោយភ្ជាប់ផែនទី និងប្រភព ព្រមទាំងកំណត់វិធីសាស្ត្រ ឧបករណ៍-សម្ភារសិក្សា។

– ភូគព្ភសាស្ត្រ៖ ត្រូវកំណត់វិធីស្រាស្ត្រ និងការប្រើប្រាស់ទិន្នន័យមានស្រាប់។

ចំណាត់ថ្នាក់ប្រភេទដី៖ ត្រូវសិក្សាបង្ហាញអំពីប្រភេទដី កម្រិតជីជាតិដី(ទាប មធ្យម ខ្លាំង)។

- អាកាសធាតុ៖ ត្រូវកំណត់យកទិន្នន័យសីតុណ្ហភាព របបទឹកភ្លៀង សំណើម ទិស-ល្បឿនខ្យល់ ដោយប្រើប្រាស់ទិន្នន័យ ៥ឆ្នាំចុងក្រោយ របស់ក្រសួងធនធានទឹក និងឧតុនិយម ឬមន្ទីរធនធានទឹក និងឧតុនិយម និងទិន្នន័យពាក់ព័ន្ធនឹងទឹកជំនន់ និងគ្រោះធម្មជាតិដែលធ្លាប់កើតឡើងនៅក្នុង និងជុំវិញតំបន់គម្រោង។
- គុណភាពខ្យល់៖ សម្រាប់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ម្ចាស់គម្រោងនិងក្រុមហ៊ុនទីប្រឹក្សាត្រូវវិភាគសំណាកខ្យល់យ៉ាងតិច ០១ទីតាំង ស្ថិតនៅក្នុងទីតាំងគម្រោង។ ដោយឡែក របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ម្ចាស់គម្រោងនិងក្រុមហ៊ុនទីប្រឹក្សាត្រូវវិភាគសំណាកខ្យល់យ៉ាងតិច០២ទីតាំង

ដោយមួយសំណាកស្ថិតនៅក្នុងទីតាំងគម្រោង និងសំណាកផ្សេងទៀតស្ថិតនៅទីតាំងពាក់ព័ន្ធ ឬតាមទិសខ្យល់បក់ ឬទីតាំងភូមិសាស្ត្រ ដោយកំណត់ក្នុងកាំរង្វង់រហូតដល់ ៥គីឡូម៉ែត្រ ហើយវាស់នៅតំបន់ភូមិករប្រជាជន។

- សំឡេង និងរំញ័រ៖ សម្រាប់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ម្ចាស់គម្រោងនិងក្រុមហ៊ុនទីប្រឹក្សាត្រូវវាស់កម្រិតសម្លេង និងរំញ័រយ៉ាងតិច ០១ទីតាំងស្ថិតនៅក្នុងទីតាំងគម្រោង។ ដោយឡែក របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ម្ចាស់គម្រោងនិងក្រុមហ៊ុនទីប្រឹក្សាត្រូវវាស់កម្រិតសម្លេង និងរំញ័រយ៉ាងតិច ០២ទីតាំង ដោយមួយសំណាកស្ថិតនៅក្នុងទីតាំងគម្រោង និងសំណាកផ្សេងទៀតស្ថិតនៅទីតាំងពាក់ព័ន្ធ ឬវាស់នៅតំបន់ទីប្រជុំជន ឬតំបន់ដែលងាយរងគ្រោះ (សាលារៀន មន្ទីរពេទ្យ វត្តអារាម ទីតាំងគោរពសាសនា) ដើម្បីទទួលបានទិន្នន័យគោលសម្រាប់ផ្ទៀងផ្ទាត់នៅពេលអនាគត។
- ជលសាស្ត្រ និងប្រភពទឹក៖ ត្រូវសិក្សាអំពីប្រភព/ប្រព័ន្ធផ្លូវទឹកសាធារណៈ ដូចជា លំហូរចរន្តទឹក ឈ្មោះ/រូបរាង/ទំហំ/ប្រវែង និងការតភ្ជាប់ប្រព័ន្ធផ្លូវទឹក (សមុទ្រ ទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ លូ បឹង ត្រពាំង ស្រះ) ដែលមាននៅក្នុង និងក្បែរទីតាំងគម្រោង។ ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវកំណត់កាំរង្វង់សិក្សាប្រព័ន្ធផ្លូវទឹក និងប្រភពទឹកសាធារណៈ (ខាងលើខ្សែទឹកនិងខាងក្រោមខ្សែទឹកទីតាំងគម្រោង) ចម្ងាយក្នុងកាំរង្វង់រហូតដល់ ៥០០ ម៉ែត្រជុំវិញទីតាំងគម្រោង ដោយកំណត់វិធីសាស្ត្រ ឧបករណ៍-សម្ភារសិក្សា និងភ្ជាប់ផែនទីប្រព័ន្ធផ្លូវទឹក។
- គុណភាពទឹកលើដី៖ ការកំណត់ចំនួនសំណាក និងទីតាំងយកសំណាក គឺផ្អែកលើស្ថានភាពភូមិសាស្ត្រជាក់ស្តែង និងប្រព័ន្ធផ្លូវទឹកដែលអាចទទួលរងផលប៉ះពាល់អវិជ្ជមានពីគម្រោង ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវកំណត់ទីតាំង និងចំនួនសំណាកទឹកមកវិភាគយ៉ាងតិចចំនួន ០១សំណាក ដោយកំណត់វិធីសាស្ត្រ ឧបករណ៍-សម្ភារសិក្សា និងភ្ជាប់ផែនទីយកសំណាកទឹកលើដី។
- គុណភាពទឹកក្រោមដី

– ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវពណ៌នាសង្ខេបអំពីប្រភពទឹកក្រោមដីនៅក្នុង និងក្បែរតំបន់គម្រោង។

– ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវកំណត់ទីតាំង និងចំនួនសំណាក ដោយកំណត់យក វិធីសាស្ត្រក្នុងការយកសំណាកទឹក ឧបករណ៍-សម្ភារសិក្សា និងភ្ជាប់ផែនទីយកសំណាក ទឹកក្រោមដី។

ខ. ធនធានជីវសាស្ត្រ

- ធនធានព្រៃឈើ៖ ពណ៌នាសង្ខេបអំពីស្ថានភាពព្រៃឈើនៅក្នុងទីតាំងគម្រោង ដោយភ្ជាប់ជាមួយនូវផែនទីគម្របព្រៃឈើឆ្នាំ២០១០ របស់រដ្ឋបាលព្រៃឈើ និងគោលបំណងក្នុងការសិក្សា ទំហំ និងវិធីសាស្ត្រក្នុងការសិក្សាធនធានព្រៃឈើដោយភ្ជាប់ជាមួយផែនទីគម្រប់ព្រៃឈើដែលបានធ្វើបច្ចុប្បន្នភាព ជាផ្លូវការបំផុត
  - គោលបំណងក្នុងការសិក្សា៖ ដើម្បីដឹងអំពីស្ថានភាពព្រៃឈើ ដំណុះរុក្ខជាតិ និងប្រភេទឈើជាដើម
  - វិធីសាស្ត្រ និងឧបករណ៍សិក្សា៖ ត្រូវចុះអង្កេតផ្ទាល់ដោយប្រើប្រាស់ផែនទីជំនួយអនុលោមតាមប្រព័ន្ធ Geographic Information System (GIS) និងការសម្ភាសជាមួយជនបង្គោល អ្នកជំនាញព្រៃឈើ និងអ្នកពាក់ព័ន្ធថែមទៀត
  - វិធីសាស្ត្រនៃការវិភាគទិន្នន័យ៖ ត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីវិធីសាស្ត្រនៃការវិភាគទិន្នន័យ ដូចជា SPSS, Excel ឬកម្មវិធីវិភាគទិន្នន័យ Software ផ្សេងៗទៀត។
- ធនធានសត្វព្រៃ និងជីវៈចម្រុះ៖ គោលបំណងនៃការសិក្សា ដែនកំណត់ (ការសិក្សាឡើងនៅក្នុងទីតាំងគម្រោង និងជុំវិញទីតាំងក្នុងកាំរង្វង់សិក្សារហូតដល់ ២គីឡូម៉ែត) និងវិធីសាស្ត្រក្នុងការសិក្សាធនធានសត្វ និងឧករណ៍សម្រាប់ជំនួយដល់ការសិក្សា
  - គោលបំណងនៃការសិក្សា៖ ដើម្បីដឹងអំពីវត្តមាន/អវត្តមាន
  - វិធីសាស្ត្រ និងឧបករណ៍ការសិក្សា៖ ទី១. ការចុះអង្កេតផ្ទាល់ដោយកំណាត់បន្ទាត់ត្រង់ស៊ិក (ចំនួន ប្រវែង ទីតាំង និងវិធីសាស្ត្រក្នុងការអង្កេត) និងចំណុចទីតាំងអង្កេតសិក្សា និង ទី២. ការសម្ភាសជាមួយជនបង្គោល (កំណត់អត្តសញ្ញាណជនបង្គោល អាយុ ភេទ ជាដើម)។
  - វិធីសាស្ត្រនៃការវិភាគទិន្នន័យ៖ ត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីវិធីសាស្ត្រនៃការវិភាគទិន្នន័យ ដូចជា SPSS, Excel ឬកម្មវិធីវិភាគទិន្នន័យ Software ផ្សេងៗទៀត។
- ធនធានជលផល និងជីវៈចម្រុះក្នុងទឹក៖ គោលបំណង ទំហំ និងវិធីសាស្ត្រក្នុងការសិក្សាធនធានជលផល និងជីវៈចម្រុះក្នុងទឹក

- គោលបំណងក្នុងការសិក្សា៖ ដើម្បីដឹងអំពីវត្តមាន ជម្រក-ចរាចរណ៍ ប្រភពចំណី និង ភាពងាយរងគ្រោះ ជាដើម
- វិធីសាស្ត្រ៖ ទី១. ការចុះអង្កេតផ្ទាល់តាមរយៈការដាក់មង បង់សំណាញ់ ជាដើម និង ទី២.ការសម្ភាសជាមួយជនបង្គោល (កំណត់អត្តសញ្ញាណជនបង្គោល អាយុ ភេទ ជាដើម) ដោយភ្ជាប់នូវផែនទីទីតាំងអង្កេត និងចំណុចនិយាមកា
- វិធីសាស្ត្រនៃការវិភាគទិន្នន័យ៖ ត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីវិធីសាស្ត្រនៃការវិភាគ ទិន្នន័យ ដូចជា SPSS, Excel ឬកម្មវិធីវិភាគទិន្នន័យ Software ផ្សេងៗទៀត។

គ. ធនធានសេដ្ឋកិច្ច-សង្គម

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាត្រូវកំណត់ទំហំ និងវិធីសាស្ត្រនៃការសិក្សាទៅលើ ធនធានសេដ្ឋកិច្ច និងសង្គម ឱ្យបានច្បាស់លាស់ដោយកំណាតើកាំរង្វង់សិក្សារហូតដល់ ៥គីឡូម៉ែត្រ ដោយផ្អែកលើ ១.ទីតាំងលំនៅ ២.ទីតាំងភូមិសាស្ត្រ ៣.ទិសខ្យល់។ ក្រុមហ៊ុនត្រូវប្រើ វិធីសាស្ត្រជួបសម្ភាសចៃដន្យ និងប្រើរូបមន្ត Taro Yamane ឬរូបមន្តវិទ្យាសាស្ត្រស្រាវជ្រាវណាមួយ ដែលសមស្របសម្រាប់ការកំណត់យកចំនួនសំណាកប្រជាជនដែលត្រូវសម្ភាសន៍ និងភ្ជាប់មក ជាមួយនូវគម្រោងសំណួរ។ ការកំណត់ចំនួនសំណាកដែលត្រូវសម្ភាសត្រូវយកកម្រិតលម្អៀង ចន្លោះពី ៥-10ភាគរយ អាស្រ័យទៅតាមស្ថានភាពភូមិសាស្ត្រជាក់ស្តែង។

នៅក្នុងការសិក្សាធនធានសេដ្ឋកិច្ច-សង្គម ក្រុមហ៊ុនត្រូវសិក្សាអំពី៖

- ប្រជាសាស្ត្រ
- ការតាំងទីលំនៅ
- ការប្រើប្រាស់ដីធ្លី
- មុខរបរ និងសកម្មភាពសេដ្ឋកិច្ច (ចំណូល-ចំណាយ និងអត្រាភាពក្រីក្រ)
- ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- ការប្រើប្រាស់ថាមពល (ប្រភពថាមពល)
- ការប្រើប្រាស់ទឹក
- ការគ្រប់គ្រងសំណល់រឹង-រាវ
- សុខមាលភាពសាធារណៈ
- ការអប់រំ
- តំបន់ទេសចរណ៍

– ទេសភាព
– វប្បធម៌ (បេតិកភណ្ឌវប្បធម៌ តំបន់ទីសក្ការបូជា តំបន់អារក្ស ព្រៃកប់ខ្មោច សហគមន៍ព្រៃឈើ សហគមន៍នេសាទ ទំនៀមទំលាប់ ប្រពៃណី និង ជនជាតិដើមភាគតិច)
– ការគ្រប់គ្រងការបំពុលបរិស្ថាន សំណល់រឹង រាវ សំណល់គ្រោះថ្នាក់ ចេញពីសកម្មភាពប្រជាជនរស់នៅក្នុង និងជុំវិញតំបន់គម្រោង។

**៥.១.៤.២. ការចូលរួមពីសាធារណៈជន**

ផែនការនៃការចូលរួមសាធារណៈមាន ០៣ដំណាក់កាល៖

ក. ដំណាក់កាលផ្សព្វផ្សាយអំពីគម្រោងវិនិយោគនៅទីតាំងពាក់ព័ន្ធនឹងគម្រោង

ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវធ្វើការផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធនៅក្នុង ឬជុំវិញតំបន់ គម្រោង ដើម្បីជូនជាព័ត៌មានគម្រោង វិសាលភាពគម្រោង ទំហំនៃការប៉ះពាល់ ព្រមទាំងទទួលបានព័ត៌មាន បឋមពីអាជ្ញាធរមូលដ្ឋាន អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋរងការប៉ះពាល់។

– សមាសភាពចូលរួម៖ មន្ទីរបរិស្ថានរាជធានី/ខេត្ត មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី/ខេត្ត អាជ្ញាធរមូលដ្ឋានឃុំ/សង្កាត់-ភូមិ សហគមន៍ និងប្រជាពលរដ្ឋរងការប៉ះពាល់។
– ទីកន្លែង៖ អាចធ្វើឡើងនៅទីតាំងគម្រោង ឬទីតាំងសាធារណៈ (វត្តអារាម ឬសាលារៀន) ឬ ទីតាំងសាលប្រជុំណាមួយ។
– រយៈពេលនៃការផ្សព្វផ្សាយ៖ យ៉ាងតិច ០១ថ្ងៃ។

ខ. ដំណាក់កាលសម្ភាសន៍ជាមួយអាជ្ញាធរដែនដី មន្ទីរពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធ

• សម្ភាសន៍ជាមួយអាជ្ញាធរដែនដី និងមន្ទីរពាក់ព័ន្ធ

ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវសម្ភាសដាច់ដោយឡែកពីគ្នាជាមួយនឹងអាជ្ញាធរដែនដី មន្ទីរពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធ ដើម្បីទទួលបានមតិយោបល់ និងអនុសាសន៍ទៅលើគម្រោងបង្កើតរោងចក្រ និង សិប្បកម្ម។

– សមាសភាពអ្នកចូលរួម៖ អាជ្ញាធររាជធានី/ខេត្ត អាជ្ញាធរក្រុង/ស្រុក/ខណ្ឌ មន្ទីរបរិស្ថាន មន្ទីរ ឧស្សាហកម្ម និងសិប្បកម្ម មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរធនធានទឹក និងឧតុនិយម មន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីរកិច្ចការនារី មន្ទីរ ទេសចរណ៍ និងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មន្ទីរការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ និងមន្ទីរសុខាភិបាល។
*កំណត់សម្គាល់៖ មន្ទីរជំនាញអាចមានការប្រែប្រួលអាស្រ័យទៅតាមប្រភេទគម្រោង។*

– ទីកន្លែង៖ អាចធ្វើឡើងនៅទីតាំងគម្រោង ឬទីតាំងសាធារណៈ (វត្តអារាម ឬសាលារៀន។ល។) ឬទីតាំងសាលប្រជុំណាមួយ។
– រយៈពេលនៃការសម្ភាសៈ យ៉ាងតិច ០១សប្តាហ៍។

• សម្ភាសន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធ

ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវរៀបចំប្រជុំពិភាក្សាជាក្រុម ឬសម្ភាសដាច់ដោយឡែកជាមួយអ្នកពាក់ព័ន្ធដើម្បីទទួលបានមតិយោបល់ និងអនុសាសន៍ទៅលើគម្រោងបង្កើតរោងចក្រ និងសិប្បកម្ម។

– សមាសភាពអ្នកចូលរួម៖ អាជ្ញាធរឃុំ/សង្កាត់ ភូមិ សហគមន៍ អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋរងការប៉ះពាល់។
– ទីកន្លែង៖ អាចធ្វើឡើងនៅទីតាំងគម្រោង ឬទីតាំងសាធារណៈ (វត្តអារាម ឬសាលារៀន) ឬ ទីតាំងសាលប្រជុំណាមួយ។
– រយៈពេលនៃការសម្ភាសៈ យ៉ាងតិច ០៤សប្តាហ៍។

គ. ដំណាក់កាលសិក្ខាសាលាពិគ្រោះយោបល់

ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សា ត្រូវរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈ ដើម្បី បង្ហាញពីលទ្ធផលនៃការសិក្សារបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមពេញលេញ។

– សមាសភាពចូលរួម៖ ក្រសួងបរិស្ថាន (នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន អាជ្ញាធររាជធានី/ខេត្ត មន្ទីរបរិស្ថាន មន្ទីរឧស្សាហកម្មនិងសិប្បកម្ម មន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់និងសុរិយោដី មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរធនធានទឹក និងឧតុនិយម មន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីរកិច្ចការនារី មន្ទីរទេសចរណ៍ និងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អង្គការសង្គមស៊ីវិល សហគមន៍ និងប្រជាពលរដ្ឋរងការប៉ះពាល់ ជា ដើម។
– ទីកន្លែង៖ អាចធ្វើឡើងនៅទីតាំងគម្រោង ឬទីតាំងសាធារណៈ ឬទីតាំងសាលប្រជុំណាមួយ។
– រយៈពេលនៃការធ្វើការពិគ្រោះសិក្ខាសាលាៈ យ៉ាងតិច ០១ថ្ងៃ។

### ៥.១.៤.៣. ការកំណត់សក្តានុពលនៃហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ

ក. ហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ

ម្ចាស់គម្រោងនិងក្រុមហ៊ុន ទីប្រឹក្សាត្រូវបញ្ជាក់អំពីទំហំនិងវិធីសាស្ត្រក្នុងការកំណត់សក្តានុពលនៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ក្នុងដំណាក់កាលមុនប្រតិបត្តិគម្រោង (ដំណាក់កាលរចនាគម្រោង និងដំណាក់កាលសាងសង់) ដំណាក់កាលប្រតិបត្តិគម្រោង និងដំណាក់កាលបញ្ចប់គម្រោង តាមរយៈការប្រើ ប្រាស់វិធីសាស្ត្រមួយចំនួនដូចជា៖

- តារាងម៉ាទ្រិក (Matrix) សម្រាប់បង្ហាញពីទំនាក់ទំនងរវាងសកម្មភាពគម្រោង និងហេតុប៉ះពាល់ទៅលើបរិស្ថាន និងសង្គម ដើម្បីកំណត់សក្តានុពលកម្រិតនៃហេតុប៉ះពាល់(មានឬគ្មាន)
- ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ Geographic Information System (GIS) ដោយប្រើប្រាស់ Tool Overlay ដើម្បីកំណត់ទីតាំងដែលគម្រោងអាចនឹងបង្កហេតុប៉ះពាល់ដល់បរិស្ថាន
- តារាងអត្តសញ្ញាណកម្មនៃហេតុប៉ះពាល់ (Check List) សម្រាប់កំណត់ហេតុប៉ះពាល់ទៅលើបរិស្ថាន និងសង្គម (តិច មធ្យម ខ្លាំង)

ចំពោះគម្រោងស្នើសុំ ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវសិក្សាវាយតម្លៃដោយផ្តោតទៅលើដំណាក់កាលមុនប្រតិបត្តិគម្រោង ដំណាក់កាលប្រតិបត្តិគម្រោង និងដំណាក់កាលបញ្ចប់គម្រោង ។ ចំពោះគម្រោងដែលមានស្រាប់ ឬកំពុងដំណើរការ ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវសិក្សាវាយតម្លៃដោយផ្តោតទៅលើដំណាក់កាលប្រតិបត្តិគម្រោង និងដំណាក់កាលបញ្ចប់គម្រោង។

- ដំណាក់កាលមុនប្រតិបត្តិ៖ ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវរៀបចំជាពីរដំណាក់កាលគឺដំណាក់កាលរចនាគម្រោង និងដំណាក់កាលសាងសង់ ដោយកំណត់នូវហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយលើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម
- ដំណាក់កាលប្រតិបត្តិគម្រោង៖ ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវកំណត់នូវហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយលើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម

- ដំណាក់កាលបញ្ចប់គម្រោង៖ ក្រោយពីបញ្ចប់សកម្មភាពការងាររបស់ក្រុមហ៊ុន ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវកំណត់នូវហេតុប៉ះពាល់បរិស្ថាន វិធានការកាត់បន្ថយ និងវិធានការស្តារបរិស្ថានឡើងវិញលើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម។

ខ.ហេតុប៉ះពាល់បរិស្ថានជាបណ្តុំសម្រាប់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ

ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវសិក្សាវាយតម្លៃហេតុប៉ះពាល់ជាបណ្តុំដោយកំណត់កាំ! រង្វង់សិក្សា ៥គីឡូម៉ែត្រជុំវិញតំបន់គម្រោង ផ្តោតទៅលើសកម្មភាពរួមគ្នារវាងគម្រោង និងគម្រោង ឬសកម្មភាព ផ្សេងទៀត ដោយផ្តោតទៅលើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម *(ភ្ជាប់ផែនទី ទីតាំងគម្រោង ឬសកម្មភាពផ្សេងទៀត)*។ បន្ថែមពីនេះ ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវបញ្ជាក់អំពី ទំហំ និងវិធីសាស្ត្រក្នុងការកំណត់សក្តានុពលនៃហេតុប៉ះពាល់បរិស្ថាន និងសង្គមជាប តាមរយៈ ការប្រើ ប្រាស់វិធីសាស្ត្រប្រព័ន្ធព័ត៌មានភូមិសាស្ត្រ Geographic Information System (GIS) ដោយប្រើប្រាស់ Tool Overlay ដើម្បីកំណត់ទីតាំងដែលគម្រោងអាចនឹងបង្កហេតុប៉ះពាល់ដល់បរិស្ថាន និងភ្ជាប់មកជាមួយនូវ ផែនទីទីតាំងគម្រោង ជាមួយនឹងគម្រោង ឬសកម្មភាពផ្សេងទៀត។

**៥.១.៤.៤. ផែនការគ្រប់គ្រងបរិស្ថាន**

ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវរៀបរាប់ពីផែនការគ្រប់គ្រងបរិស្ថានដោយលើកយកតែផែនការសំខាន់ៗសម្រាប់អង្កេតតាមដានបរិស្ថាន និងបង្កើតតារាងកម្មវិធីអង្កេតតាមដានបរិស្ថានស្តីពីការ ត្រួតពិនិត្យបរិស្ថានក្នុងដំណាក់កាលសាងសង់ ដំណាក់កាលប្រតិបត្តិ និងដំណាក់កាលបញ្ចប់គម្រោង ដោយក្នុងនោះក្រុមហ៊ុនត្រូវរៀបចំនូវ៖

១. សេចក្តីផ្តើម

២. ការសង្ខេបហេតុប៉ះពាល់និងវិធានការកាត់បន្ថយដើម្បីឈានទៅរៀបចំផែនការគ្រប់គ្រងបរិស្ថាន

៣. ការរៀបចំស្ថាប័នត្រួតពិនិត្យ និងទទួលខុសត្រូវ

ក). ស្ថាប័នត្រួតពិនិត្យថ្នាក់ជាតិ

ខ). ស្ថាប័នត្រួតពិនិត្យថ្នាក់ក្រោមជាតិ

គ). ស្ថាប័នទទួលខុសត្រូវ

៤. កម្មវិធីបណ្តុះបណ្តាល

៥. កម្មវិធីអង្កេតតាមដាន

កំណត់ធនធានបរិស្ថាន ទីតាំង ប៉ារ៉ាម៉ែត្រ និងឧបករណ៍សម្ភារសម្រាប់ធ្វើការត្រួតពិនិត្យ អ្នកទទួលខុសត្រូវ ស្ថាប័នត្រួតពិនិត្យ និងថវិកាសម្រាប់ធ្វើការត្រួតពិនិត្យចងក្រង វិភាគទិន្នន័យ និងធ្វើការប្រៀបធៀបទៅនឹងទិន្នន័យគោល និងការអនុវត្តបទដ្ឋាន បច្ចេកទេស។

៦. ផែនការថវិកាសម្រាប់កម្មវិធីអង្កេតតាមដាន

៧. ការរៀបចំរបាយការណ៍អង្កេតតាមដានរៀងរាល់៦ខែ/ម្តង (ក្នុងករណីគម្រោងមានការប៉ះពាល់ធ្ងន់ធ្ងរគឺរៀបចំរបាយការណ៍តាមដាន ៣ខែ/ម្តង)

៨. មូលនិធិបរិស្ថាន និងសង្គមៈ អនុលោមតាមអនុក្រឹត្យលេខ ២៣៨ អនក្រ.បក ចុះថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការបង្កើតមូលនិធិបរិស្ថាន និងសង្គម និងប្រកាសអន្តរក្រសួងរវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ៥.១.៤.៥. ការវិភាគសេដ្ឋកិច្ច និងការខូចខាតបរិស្ថានសម្រាប់របាយការណ៍វាយតម្លៃហេតុប៉ះពាល់ បរិស្ថាន និងសង្គមពេញលេញ

ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវបញ្ជាក់អំពីទំហំ វិធីសាស្ត្រ រូបមន្ត គោលបំណង និង សូចនាករនៃការធ្វើការវិភាគសេដ្ឋកិច្ច និងសង្គម ដោយផ្តោតសំខាន់ទៅលើការវិភាគហិរញ្ញវត្ថុ ការវិភាគសេដ្ឋកិច្ច និងការវិភាគតម្លៃខូចខាតបរិស្ថាន ដោយបញ្ជាក់ពីឯកសារយោង និងប្រភព។

ក. ការវិភាគហិរញ្ញវត្ថុៈ ផ្អែកលើការសិក្សាចំណេញខាតរបស់ម្ចាស់គម្រោង

ខ. ការវិភាគសេដ្ឋកិច្ចៈ ផ្អែកលើការផលចំណេញរបស់ក្រុមហ៊ុនបង់ចូលរដ្ឋ

គ. ការវិភាគនៃតម្លៃខូចខាតបរិស្ថានៈ វិភាគតម្លៃដោយផ្ទាល់ និងប្រយោលទៅលើៈ

- ធនធានរូបសាស្ត្រៈ ការបំពុលខ្យល់ ការរំខានដោយសំឡេង-រំញ័រ គុណភាពទឹកលើដី/ក្រោមដី។ល។
- ធនធានជីវសាស្ត្រៈ ធនធានសត្វព្រៃ(បក្សី) ធនធានមច្ឆជាតិ។ល។
- ធនធានសេដ្ឋកិច្ច-សង្គមៈ មុខរបរ ប្រាក់ចំណូល ចរាចរណ៍ សុខភាពសាធារណៈ។ល។

### ៥.១.៥. ការកំណត់ទម្រង់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងពេញលេញ ឬ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមសង្គមដំបូង

ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សា ត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ទៅតាមប្រកាសស្តីពីគោលការណ៍ណែនាំ ទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ឬរបាយការណ៍វាយតម្លៃប៉ះ ពាល់បរិស្ថាន និងសង្គមដំបូង របស់ក្រសួងបរិស្ថាន និងត្រូវរៀបរាប់ សង្ខេបអំពីចំណុចដែលត្រូវសិក្សានៅតាមជំពូក នីមួយៗ។

### ៥.១.៦. សមាសភាពក្រុមហ៊ុនទីប្រឹក្សាចុះសិក្សា

ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវបង្ហាញពីឈ្មោះប្រធានក្រុមការងារសិក្សា អ្នកជំនាញការ និងជំនួយការសម្រាប់សិក្សាស្រាវជ្រាវគម្រោងណាមួយ ហើយអ្នកទាំងនោះសុទ្ធមាននៅក្នុងបញ្ជីរចនាសម្ព័ន្ធរបស់ក្រុមហ៊ុនប្រឹក្សា ដែលបានចុះបញ្ជីទទួលស្គាល់នៅក្រសួងបរិស្ថាន។ ករណីម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាសហការណ៍ជាមួយដៃគូជាទីប្រឹក្សាឯកជន ឬអ្នកជំនាញនានា ដែលពុំមាននៅក្នុងពាក្យសុំចុះបញ្ជីនោះម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវជូនដំណឹងមកក្រសួងបរិស្ថានឱ្យបានមុន០១ខែ។

### ៥.១.៧. តារាងការងារ/សកម្មភាពការងាររបស់ក្រុមហ៊ុនទីប្រឹក្សាសិក្សាលើម្ចាស់គម្រោង

ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវកំណត់ពីពេលវេលានៃការសិក្សាតាំងពីដំបូងរហូតដល់បញ្ជូនរបាយការណ៍នេះ មកក្រសួងបរិស្ថានពិនិត្យ និងផ្តល់យោបល់។

### ៥.១.៨. ឧបសម្ព័ន្ធ

ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវភ្ជាប់ឯកសារផ្លូវច្បាប់ ដែលពាក់ព័ន្ធនានាទៅនឹងគម្រោង។ ឧទាហរណ៍៖ លិខិតចុះបញ្ជីពាណិជ្ជកម្ម លិខិតចុះបញ្ជីក្រុមហ៊ុនទីប្រឹក្សានៅក្រសួងបរិស្ថាន លិខិតផ្តល់សិទ្ធិឱ្យក្រុមហ៊ុនវិនិយោគ និងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងបរិស្ថាន និងអាជ្ញាធរពាក់ព័ន្ធ។ល។

## ៥.២. ការវិភាគអត្ថប្រយោជន៍ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើវិស័យឧស្សាហកម្ម

យោងតាមការអង្កេតទៅលើ កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការរៀបចំរបាយការណ៍នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើគម្រោងឧស្សាហកម្ម និងសិប្បកម្មរួចមក

យើងខ្ញុំសង្កេតឃើញថាការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពិតជាមានសក្តានុពលជាខ្លាំងទៅលើការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ ការវាយតម្លៃនេះបានធ្វើអោយមានលក្ខណៈសាំញ៉ាំដល់ដំណើរការវិនិយោគរបស់វិនិយោគិន ដោយសារតែក្រសួងត្រូវតម្រូវអោយគម្រោងទាំងអស់(គម្រោងដែលត្រូវវាយតម្លៃហេតុប៉ះពាល់បរិស្ថាន)ធ្វើការវាយតម្លៃ ដែលជាការចំណាយរបស់ម្ចាស់គម្រោង/វិនិយោគិន។ មិនតែប៉ុណ្ណោះ ក្រសួងក៏បានតម្រូវអោយគម្រោងត្រូវមានវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានតាមរយៈ ការសាងសង់ប្រព័ន្ធគ្រប់គ្រងផ្សេងៗ។ លើសពីនេះទៅទៀត វាបានបង្អាក់ទឹកចិត្តរបស់វិនិយោគិនផងដែរ ដោយម្ចាស់គម្រោងត្រូវចំណាយពេលវេលាសម្រាប់ធ្វើការវាយតម្លៃមុនដំណើរការ។ ម្យ៉ាងវិញទៀតបើយោងតាម **លោក ជា ឡេខ** អនុប្រធាននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៃក្រសួងបរិស្ថាន បានមានប្រសាសន៍ថា ថ្មីៗក្រសួងមានការសហការជាមួយក្រសួងពាក់ព័ន្ធ ដូចជាក្រសួងរ៉ែ និងថាមពលជាដើម ដោយរាល់គម្រោងដែលស្នើសុំទៅក្រសួងទាំងនោះ ត្រូវតម្រូវអោយធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាមុនសិន មុននឹងចេញអាជ្ញាប័ណ្ណអោយ។ បើមើលទៅដំណើរការហាក់ដូចជាសាំញ៉ាំក៏ពិតមែន ក៏ប៉ុន្តែវាពិតជាល្អសម្រាប់វិនិយោគិនដែលមានចក្ខុវិស័យវែងឆ្ងាយ ហើយវាក៏ល្អផងដែរសម្រាប់ការអភិវឌ្ឍរបស់ប្រទេសមួយ។

សព្វថ្ងៃនេះយើងឃើញថាផលប៉ះពាល់នៃបរិស្ថានមួយចំណែកធំគឺកើតឡើងដោយសារការកើនឡើងនៃរោងចក្រសហគ្រាស រឺឧស្សាហកម្មផ្សេងៗដែលបានបញ្ចេញកាកសំនល់ទាំងរឹងរាវ និងឧស្ម័ន។ ជាការពិតណាស់ ការរីកចម្រើននៃវិស័យឧស្សាហកម្មគឺជាសញ្ញាណនៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសមួយ ប៉ុន្តែប្រសិនបើការកើនឡើងនោះពុំមានការគ្រប់គ្រងកាកសំណល់បានត្រឹមត្រូវ មិនបានពិនិត្យពិច័យលើការប្រើប្រាស់ធនធានបានត្រឹមត្រូវ ព្រមទាំងការទាញយកធនធានមកប្រើប្រាស់តាមអំពើរចិត្ត(សម្រាប់គម្រោងដូចជាទាញយករ៉ែក្រោមដី កាយថ្មភ្នំ ជាដើម នោះការរីកចម្រើននេះច្បាស់ណាស់ថាគ្មានស្ថេរភាពនោះទេ។ មួយវិញទៀតទោះបីជាគម្រោងទាំងនោះបានរុញកំណើនសេដ្ឋកិច្ចរបស់កម្ពុជាក៏ដោយ ក៏ប៉ុន្តែផលប៉ះពាល់ទៅលើបរិស្ថាននិងការបាត់បង់នូវធនធានធម្មជាតិសំខាន់ៗមួយចំនួន ដែលយើងមិនអាចគិតជាទឹកប្រាក់នោះ នឹងបង្កជាផលវិបាកនៅថ្ងៃក្រោយជាក់ជាមិនខាន។ ជាក់ស្តែងណាស់យើងឃើញថាការប្រែប្រួលអាកាសធាតុគឺជាលទ្ធផលនៃការមិនយកចិត្តទុកដាក់ទាំងនោះ ហើយវាក៏បានបង្កជាផលលំបាកជាច្រើនជាបន្តបន្ទាប់ផងដែរ។

បើតាមការសិក្សាពីទ្រឹស្តីនៃការអភិវឌ្ឍសេដ្ឋកិច្ច យើងខ្ញុំសង្កេតឃើញថា វាជាការជំរុញកំណើនសេដ្ឋកិច្ច ដែលក្នុងគោលបំណងផ្តល់នូវសុខុមាលភាពប្រជាជន។ ជាការពិតណាស់ គោលបំណងធំនៃការអភិវឌ្ឍគឺជាសុខុមាលភាពប្រជាជន ដូច្នេះអ្វីដែលអ្នកសេដ្ឋកិច្ច ក៏ដូចជាថ្នាក់ដឹកនាំនៃប្រទេសមួយត្រូវគិត មុនគេនោះគឺការផ្តល់នូវភាពសុខុដុមរមនាដល់ប្រជាជន មិនមែនគ្រាន់តែជាការជំរុញកំណើនសេដ្ឋកិច្ចនោះទេ។ ហេតុនេះហើយ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានគឺជារឿងមួយសំខាន់ណាស់ដែលត្រូវគិតផងដែរ ក្នុងការជម្រុញកំណើនសេដ្ឋកិច្ច ស្របពេលជាមួយនឹងការគិតពីសុខុមាលភាពប្រជាជន។ មិនតែប៉ុណ្ណោះ ការគិតគូរទៅដល់បរិស្ថានក៏ជាឧបករណ៍សំខាន់បំផុតសម្រាប់គោលការណ៍នៃការអភិវឌ្ឍប្រកបដោយចីរភាព។

តើការវាយតម្លៃហេតុប៉ះពាល់បិស្ថានបានរួមចំណែកដោយរបៀបណាខ្លះក្នុងការអភិឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពរបស់កម្ពុជា?

ខាងក្រោមនេះ យើងនឹងបង្ហាញពីអត្ថប្រយោជន៍នៃការធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលសំដៅទៅដល់ ២ភាគីគឺសម្រាប់ម្ចាស់គម្រោង និងសម្រាប់សង្គម/ប្រទេសទាំងមូលផងដែរ។ ទាំងនេះសុទ្ធសឹងតែជាមូលដ្ឋានគ្រិះនៃគោលការណ៍អភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចីរភាព។

### ៥.២.១. អត្ថប្រយោជន៍នៃការធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើគម្រោងឧស្សាហកម្មសម្រាប់ម្ចាស់គម្រោង

#### ៥.២.១.១. ឥទ្ធិពលលើការសម្រេចចិត្ត

គ្រប់អ្នកវិនិយោគទាំងឡាយ សុទ្ធសឹងតែមានគោលដៅមួយគឺចង់បាននូវប្រាក់ចំណេញសម្រាប់អាជីវកម្មរបស់ខ្លួន ជាពិសេសសម្រាប់គម្រោងឧស្សាហកម្មដែលជាគម្រោងមួយមានហានិភ័យខ្ពស់ និងបានចំណាយដើមទុនច្រើន។ ហេតុដូចនេះ មុននឹងសម្រេចចិត្តថាត្រូវបង្កើតឧស្សាហកម្មណាមួយ រឺមិនបង្កើត អ្នកវិនិយោគបានចំណាយដើមទុនយ៉ាងច្រើនទៅលើការសិក្សាទីផ្សារ ដើម្បីអោយដឹងតម្រូវការទីផ្សារ ត្រូវផលិតអ្វី និងផលិតប៉ុន្មានក្នុងមួយឆ្នាំសម្រាប់បំពេញតម្រូវការនោះ។ បន្ទាប់មកអ្នកវិនិយោគទាំងនោះត្រូវស្វែងរកទីតាំងសម្រាប់ដាក់រោងចក្រឧស្សាហកម្មទាំងនោះដែលមានលក្ខណៈងាយស្រួល និងផ្តល់ផលចំណេញ សមស្របតាមតម្រូវការរបស់អ្នកវិនិយោគ។ បន្ទាប់ពីនោះទៀត ពួកគេត្រូវធ្វើការគិតពិចារណាលើការសាងសង់និងត្រូវបញ្ចូលនូវបច្ចេកទេសនិងបច្ចេកវិទ្យាអ្វីខ្លះ សម្រាប់គម្រោងរបស់ពួកគេ។

យ៉ាងណាមិញ ការសាងសង់ទាំងឡាយ ត្រូវមានការអនុញ្ញាតពីស្ថាប័នពាក់ព័ន្ធ និងបុគ្គលដែលពាក់ព័ន្ធ ដោយមានការសហការជាមួយសាម៉ីប្រទេសជាមុនសិន។ អ្នកវិនិយោគមិនអាចគ្រាន់តែគិត ហើយធ្វើតែតាមអំពើចិត្តរបស់ខ្លួននោះទេ ដោយហេតុថាវាអាចនឹងមានហេតុប៉ះពាល់ផ្សេងៗទៅលើអ្នកទៃ និងជាការគ្រប់គ្រងសណ្តាប់ធ្នាប់សង្គមផងដែរ។ មួយក្នុងចំណោមនោះ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានគឺជាអន្តរាគមន៍មួយរបស់រដ្ឋ សម្រាប់បញ្ចៀសនូវផលប៉ះពាល់ផ្សេងៗទៅលើបរិស្ថាន និងលើប្រជាជននៅជុំវិញតំបន់នោះផងដែរ។

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបានតម្រូវអោយម្ចាស់គម្រោងសិក្សាតាំងពីឫសគល់ដើមហេតុ មើលទៅលើផលប៉ះពាល់គ្រប់ប្រភេទ ដើម្បីអោយម្ចាស់គម្រោងត្រៀមរកវិធានការរួចជាស្រេច។ មិនតែប៉ុណ្ណោះ ការវាយតម្លៃនេះក៏បានបំផុសអោយមានការចូលរួមជាសាធារណៈតាមរយៈការអញ្ជើញអោយអ្នកពាក់ព័ន្ធទាំងអស់ (អ្នកទទួលប្រយោជន៍ អ្នករងផលប៉ះពាល់...) ចូលរួមផ្តល់យោបល់ រឺលើកពីទុក្ខលំបាករបស់ខ្លួនទៅដល់ម្ចាស់គម្រោងនៅពេលដែលមានការសាងសង់រោងចក្រនៅក្បែរទីលំនៅរបស់ពួកគាត់ ដើម្បីធ្វើការរកនូវវិធានការ និងដំណោះស្រាយយ៉ាងណាកុំអោយមានបញ្ហាទៅថ្ងៃមុខ។ លើសពីនេះទៅទៀត ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក៏បានតម្រូវអោយម្ចាស់គម្រោងភ្ជាប់មកជាមួយនូវរបាយការណ៍បុរេលទ្ធភាព ឬរបាយការណ៍សមិទ្ធិលទ្ធភាព ដើម្បីពិចារណាឱ្យច្បាស់លាស់ថាម្ចាស់គម្រោងពិតជាមានលទ្ធភាពក្នុងការដំណើរការគម្រោងនេះបាន។

ដូចនេះ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ មិនត្រឹមតែគិតលើបរិស្ថានមួយមុខ តែក៏មានគោលបំណងក្នុងការជួយដល់ម្ចាស់គម្រោងក្នុងការសម្រេចថា តើគួរដំណើរការគម្រោងនេះយ៉ាងណា ដើម្បីកុំអោយមានបញ្ហារាំងស្ទះណាមួយនៅថ្ងៃខាងមុខ ដែលជាការជួយកាត់បន្ថយនូវថ្លៃចំណាយសម្រាប់ដោះស្រាយបញ្ហានោះផង។ មួយវិញទៀត ក្រោយពីការវាយតម្លៃរួចរាល់ម្ចាស់គម្រោងក៏មានទំនុកចិត្តក្នុងការដំណើរការគម្រោងរបស់ខ្លួន។

### ៥.២.១.២. ការត្រៀមបង្ការ និងកាត់បន្ថយហានិភ័យ

យើងដឹងថាហានិភ័យផ្សេងៗតែងតែកើតឡើងដោយមិនអាចប្រាប់យើងមុននោះទេ។ ការកើតមាននូវហានិភ័យ សុទ្ធតែជាការខាតបង់ ឬការចំណាយរបស់ម្ចាស់អាជីវកម្ម។ បើអាជីវកម្មធំដុំដូចជាអាជីវកម្មដែលមានកិច្ចសន្យា ឬមានការកម្មង់ទិញមុន ហើយត្រូវផលិតអោយទាន់តាមពេលវេលាដែលកំណត់ នោះម្ចាស់ឧស្សាហកម្មមានទំនួលខុសត្រូវធំធេងមែនទែន ប្រសិនបើ

ដំណើរការផលិតកម្មមានបញ្ហា ឬត្រូវបានរាំងស្ទះដោយកត្តាណាមួយនោះ។ ហេតុនេះហើយ ហានិភ័យណាដែលយើងអាចប៉ាន់ស្មានដឹងមុន យើងត្រៀមបង្ការទុកមុនក៏ជាការល្អដែរ។

ការពិនិត្យតាមដានជាប្រចាំទាក់ទងនឹងបរិស្ថាន ត្រូវបានគេធ្វើក្នុង៦ខែម្តង រឺផ្សេងពីនេះ តាមការតម្រូវរបស់ក្រសួងបរិស្ថាន ដើម្បីពិនិត្យ និងទប់ស្កាត់នូវបម្រែបម្រួលផ្សេងៗ។ មិនតែប៉ុណ្ណោះ ម្ចាស់គម្រោងត្រូវផ្ញើរបាយការណ៍ពិនិត្យតាមដាននេះជាប្រចាំទៅក្រសួងបរិស្ថាន។ ការធ្វើបែបនេះ ម្ចាស់គម្រោងមានការប្រុងប្រៀបខ្លួនជាប្រចាំទាក់ទងនឹងការបម្រែបម្រួលផ្សេងៗ។ ដោយសារការពិនិត្យជាប្រចាំនេះបានជួយដល់ម្ចាស់គម្រោងចៀសវាងនូវហានិភ័យផ្សេងៗបានទាន់ពេលវេលា ពីព្រោះថាបើកាលណាមានបម្រែបម្រួលណាមួយតែបន្តិច អ្នកសិក្សានឹងកត់សម្គាល់ឃើញជាក់ជាមិនខាន។

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានក៏តម្រូវអោយមានការចូលរួមជាសាធារណៈ ពីសំណាក់អ្នកដែលទទួលប្រយោជន៍ និងអ្នកដែលរងផលប៉ះពាល់ពីការសាងសង់ឧស្សាហាកម្ម។ ការធ្វើបែបនេះ ភាគីទាំងអស់បានចូលរួមពិភាក្សាគ្នា ចរចាគ្នា រកដំណោះស្រាយរួមណាមួយ ដើម្បីកុំអោយមានបញ្ហានៅថ្ងៃក្រោយ ដែលអាចនាំអោយមានការរាំងស្ទះដំណើរការផលិតកម្មរបស់រោងចក្រឧស្សាហាកម្ម។

### ៥.២.១.៣. ភាពយូរអង្វែង និងស្ថិតស្ថេរនៃអាជីវកម្ម ឬគម្រោង

គ្រប់ម្ចាស់អាជីវកម្មទាំងអស់សុទ្ធតែប្រាថ្នាចង់បាននូវភាពស្ថិតស្ថេរនៃអាជីវកម្មរបស់ខ្លួន។ គេចង់អោយអាជីវកម្មរបស់គេអាចដំណើរការបានយូរអង្វែង ដោយមិនចង់អោយមានការអាក់ខាន ឬការបិទទ្វាអាជីវកម្មនោះទេ។ ជាទូទៅ ភាពយូរអង្វែងនៃអាជីវកម្មគឺអាស្រ័យលើដំណើរប្រព្រឹត្តនៃអាជីវកម្មនោះនៅក្នុងដំណើរការសេដ្ឋកិច្ច(ការស្វែងកប្រាក់ចំណូល)របស់ពួកគេ។ ប៉ុន្តែកត្តាខាងក្រៅមួយចំនួនក៏ជាកត្តាដែលអាចនាំអោយមានផលប៉ះពាល់ដល់ដំណើការអាជីវកម្មផងដែរ។

កត្តាបំពុលបរិស្ថាន ក៏ជាកត្តាមួយសំខាន់សម្រាប់រោងចក្រឧស្សាហាកម្មគួរគិតពិចារណាផងដែរ។ ការបំពុលបរិស្ថាន គឺបណ្តាលមកពីការបញ្ចេញផ្សែងឬឧស្ម័ន កាកសំណល់រឹង-រាវ និងការបង្ហូរទឹកកង្វក់ច្រើនលើសលុបចេញពីរោងចក្រឧស្សាហាកម្ម ដែលជាហេតុនាំឱ្យមានការបំពុលខ្យល់ ការបំពុលទឹក និងការបំពុលដីទៅក្នុងបរិយាកាស។ ការបំពុលនេះធ្វើឱ្យមានការប៉ះពាល់ដល់ប្រយោជន៍សាធារណៈ និងការរស់នៅប្រជាជននៅក្បែរនោះដូចជា ប៉ះពាល់ដល់សុខភាពប្រជាជន តាមរយៈការដង្ហើម ការប្រើប្រាស់ទឹកមិនស្អាត ខូចគុណភាពដី និងប្រែប្រួល

អាកាសធាតុ។ ការបំពុលទាំងនេះកើតចេញពីការប្រើប្រាស់គ្រឿងម៉ាស៊ីន ឬសកម្មភាពផ្សេងៗក្នុងដំណើរការផលិតរបស់រោងចក្រឧស្សាហកម្ម។ ហេតុនេះ ទើបរដ្ឋាភិបាលតម្រូវឱ្យវិនិយោគិនបំពាក់នូវបច្ចេកវិទ្យាផ្សេងៗ ដើម្បីបន្សុទ្ធ ឬកាត់បន្ថយជាតិពុលទាំងនោះឱ្យនៅត្រឹមកម្រិតទាបស្របតាមការកំណត់របស់រដ្ឋ ដើម្បីជៀសវាងការតវ៉ា ឬការអន្តរាគមន៍ពីរាជរដ្ឋាភិបាលនៅថ្ងៃមុខ។ ការអន្តរាគមន៍នោះ អាចជាការព្រមាន ឬឈានដល់ការបិទទ្វាអាជីវកម្មផងដែរ។

ករណីគម្រោងនោះមានការចុះអន្តរាគមន៍ពីរាជរដ្ឋាភិបាល នាំឱ្យគម្រោងនោះមានការខូចខាត ឬការរាំងស្ទះផ្សេងៗ និងបង្កឱ្យមានហានិភ័យក្នុងការផ្គត់ផ្គង់ទំនិញដល់ដៃគូរពាណិជ្ជកម្មផងដែរ។ មួយវិញទៀត ប្រសិនជាបញ្ហាកើតឡើងញឹកញយពេក វាក៏អាចមានបញ្ហាដល់កេរ្តិ៍ឈ្មោះក្រុមហ៊ុន ក៏ដូចជាទំនុកចិត្តរបស់អតិថិជនផងដែរ។ ទាំងនេះសុទ្ធសឹងតែជាមូលហេតុប្រឈមដល់ភាពស្ថិតស្ថេរនៃអាជីវកម្មរបស់ក្រុមហ៊ុនទាំងឡាយ។ ហេតុនេះ ទើបម្ចាស់គម្រោងត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាមុន មុននឹងអាចដំណើរការអាជីវកម្មរបស់ពួកគាត់ និង ត្រូវធ្វើការពិនិត្យនិងវាយតម្លៃហេតុប៉ះពាល់បរិស្ថានជារៀងរាល់៦ខែម្តង។

### ៥.២.២. អត្ថប្រយោជន៍នៃការធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើគម្រោងឧស្សាហកម្មសម្រាប់សង្គមជាតិទាំងមូល

ការបង្កើតគម្រោងឧស្សាហកម្ម និងការសាងសង់រោងចក្រឧស្សាហកម្ម បានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់សង្គមជាតិកម្ពុជាទាំងមូលតាមរយៈ ការបង្កើតការងារដល់ប្រជាពលរដ្ឋ ការកាត់បន្ថយភាពក្រីក្រ ការផ្តល់នូវស្តង់ដានៃការរស់នៅដល់ប្រជាជន និងគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាពផងដែរ។

#### ៥.២.២.១ បង្កើតការងារដល់ប្រជាពលរដ្ឋ

ការបង្កើតការងារដល់ប្រជាពលរដ្ឋគឺជាកត្តាសំខាន់បំផុតសម្រាប់ប្រទេសជាតិនីមួយៗ មិនថានៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ឬប្រទេសអភិវឌ្ឍន៍នោះទេ។ ប៉ុន្តែ ក៏គ្មានប្រទេសណាដែលអាចជៀសផុតពីអត្រានៃភាពឥតការងារសោះនោះដែរ គ្រាន់តែប្រទេសខ្លះមានអត្រានិកម្មភាពទាប និងប្រទេសខ្លះមានអត្រានិកម្មភាពខ្ពស់តែប៉ុណ្ណោះ ពិសេសគឺប្រទេសកំពុងអភិវឌ្ឍន៍នេះឯងដែលមានអត្រានិកម្មភាពខ្ពស់ជាងប្រទេសអភិវឌ្ឍន៍។ កត្តានេះហើយ ដែលធ្វើឱ្យគ្រប់បណ្តាលប្រទេសលើសកលលោកខិតខំរិះគ្រប់មធ្យោបាយ ដើម្បីបង្កើតការងារដល់ប្រជាពលរដ្ឋរបស់ពួកគេ។ ដោយឡែក ការបង្កើតគម្រោងឧស្សាហកម្ម និងការសាងសង់រោងចក្រឧស្សាហកម្មបានផ្តល់ឱកាសការងារដល់ប្រជាពលរដ្ឋកម្ពុជាជាច្រើនកន្លែង។

ការបង្កើតគម្រោងឧស្សាហកម្ម បានផ្តល់ឱកាសការងារដល់ប្រជាពលរដ្ឋកម្ពុជាតាមរយៈការផ្តល់ការងារដល់មន្ត្រីរាជការនិងបុគ្គលិក ដែលបម្រើការងារនៅក្នុងនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងបុគ្គលិកបម្រើការងារក្នុងក្រុមហ៊ុនទីប្រឹក្សាឯកជនផងដែរ។

ករណីដែលគម្រោងឧស្សាហកម្មត្រូវបានអនុញ្ញាតឱ្យសាងសង់ នោះឱកាសការងារសម្រាប់ប្រជាពលរដ្ឋកម្ពុជាក៏មានកាន់តែច្រើនថែមទៀត តាមរយៈការសាងសង់រោងចក្រ និងការបម្រើការងារក្នុងរោងចក្រទាំងនោះ។

ជាធម្មតា រាល់ការសាងសង់រោងចក្រឧស្សាហកម្ម គឺតែងតែត្រូវការកម្មករ អ្នកជំនាញទាំងផ្នែកសាងសង់និងស្ថាបត្យកម្ម និងអ្នកផ្គត់ផ្គង់។ មានន័យថា ការសាងសង់រោងចក្រសហគ្រាសនីមួយៗបានផ្តល់ការងារឱ្យកម្មករសំណង់ ស្ថាបនិក ស្ថាបត្យករ និង កម្មករឬបុគ្គលិកដែលបម្រើការងារដល់ក្នុងអាជីវកម្មផ្គត់ផ្គង់សម្ភារៈសំណង់ និងគ្រឿងសង្ហារឹមផ្សេងៗ។

បន្ទាប់ពីគម្រោងបានសាងសង់រួចរាល់ រោងចក្រឧស្សាហកម្មនឹងធ្វើការជ្រើសរើសកម្មករបុគ្គលិក អ្នកជំនាញ និងដៃគូពាណិជ្ជកម្មផ្សេងៗ ដើម្បីបម្រើការក្នុងដំណើរការអាជីវកម្មរបស់ពួកគេ។ ដូច្នេះ ការបង្កើតគម្រោងឧស្សាហកម្មពិតជាបានផ្តល់ការងារដល់ប្រជាពលរដ្ឋកម្ពុជាយ៉ាងច្រើន។

#### ៥.២.២.២. កាត់បន្ថយភាពក្រីក្រ

ប្រទេសជាតិមួយអាចរីកចម្រើនទៅបាន លុះត្រាតែជីវភាពរបស់ប្រជាជនក្នុងប្រទេសនោះមានភាពប្រសើរឡើង។ បញ្ហាភាពក្រីក្រ គឺជាបញ្ហាធំមួយសម្រាប់គ្រប់បណ្តាប្រទេសលើសាកលលោក ដែលពួកគេបាននិងកំពុងតែព្យាយាមធ្វើការកាត់បន្ថយផងដែរ។ បញ្ហាភាពក្រីក្រនេះអាចកាត់បន្ថយបាន នៅពេលដែលប្រជាពលរដ្ឋរបស់ប្រទេសមួយមានការងារធ្វើ និងអត្រានិកម្មភាពនៃប្រទេសនោះចុះទាប។

ដោយសារតែ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបានផ្តល់ការងារជាច្រើនដល់ប្រជាពលរដ្ឋកម្ពុជា តាមរយៈនេះ បានបង្ហាញឱ្យឃើញថា ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក៏មានតួនាទីយ៉ាងសំខាន់ផងដែរក្នុងការកាត់បន្ថយនូវអត្រាភាពក្រីក្រក្នុងប្រទេសកម្ពុជា។

#### ៥.២.២.៣. ស្តង់ដារនៃការរស់

ក្រៅពីការផ្តល់ការងារ និងការចូលរួមកាត់បន្ថយភាពក្រីក្រ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក៏បានផ្តល់នូវស្តង់ដានៃការរស់នៅដល់ប្រជាជនកម្ពុជាផងដែរ។ ជាក់ស្តែង រាល់ការបង្កើតគម្រោងឧស្សាហកម្មត្រូវបានពិនិត្យបរិមាណផ្សេងដែលសាយភាយទៅក្នុងបរិយាកាស

និងការបញ្ចេញនូវកាកសំណល់ផ្សេងៗ ដែលនាំឱ្យមានការប៉ះពាល់ដល់សុខភាពប្រជាជន។ ការបំពុលបរិយាកាស ការបំពុលទឹក និងការបំពុលដី ពិតជាប៉ះពាល់ដល់សុខភាពប្រជាជនជាខ្លាំងតាមរយៈការដង្ហើម ការប្រើប្រាស់ទឹកមិនស្អាត និងការបរិភោគអាហារដែលមានជាតិពុល។ ដោយឡែក ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើគម្រោងឧស្សាហកម្មបានធ្វើការទប់ស្កាត់ និងកាត់បន្ថយរាល់ការបំពុលទាំងអស់ ដើម្បីជួយគាំទ្រដល់ការរស់នៅរបស់ប្រជាជនកម្ពុជា។

**៥.២.២.៤. កាត់បន្ថយការប្រែប្រួលអាកាសធាតុ**

សព្វថ្ងៃនេះយើងឃើញថាអាកាសធាតុមានការប្រែប្រួលខ្លាំងគួរអោយកត់សម្គាល់។ ហើយការប្រែប្រួលនេះសុទ្ធសឹងតែជាស្នាដៃរបស់មនុស្ស ដែលបានបំផ្លាញទៅលើស្រទាប់ផែនដីតាមរយៈការបំពុលផ្សេងៗ ជាការពិតណាស់ ចាប់តាំងពីសម័យបដិវត្តន៍ឧស្សាហកម្មដំបូងមកដល់បច្ចុប្បន្ន មនុស្សបានធ្វើសកម្មភាពដែលបានបង្កជាផ្សែងទៅបរិយាកាសយ៉ាងច្រើនសន្ធឹកសន្ធាប់។ ការបំពុលផ្សែភាគ ច្រើនគឺបង្កឡើងដោយយានយន្ត និងរោងចក្រឧស្សាហកម្មនេះឯងដែលជាហេតុធ្វើឱ្យមានការប្រែប្រួលអាកាសធាតុគួរឱ្យកត់សំគាល់។

ការប្រែប្រួលអាកាសធាតុនេះបានធ្វើឱ្យមានផលប៉ះពាល់ដល់ការអភិវឌ្ឍប្រទេសជាតិមួយផ្នែកធំផងដែរ ទើបក្រសួងបរិស្ថានតម្រូវឱ្យគ្រប់ម្ចាស់គម្រោងឧស្សាហកម្មធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

នៅក្នុងរបាយកាណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន បានតម្រូវអោយរាល់ម្ចាស់គម្រោងឧស្សាហកម្មពិនិត្យបរិមាណផ្សេងដែលបានបញ្ចេញទៅក្នុងបរិយាកាស ក្នុងគោលដៅទប់ស្កាត់ការប្រែប្រួលអាកាសធាតុបានមួយកម្រិត ពីព្រោះថា ការប្រែប្រួលអាកាសធាតុផ្តល់នូវផលអាក្រក់ជាច្រើនដូចជាគ្រោះរាំងស្ងួត ការកើនឡើងកម្តៅផែនដី សីតុណ្ហភាពក្តៅពេក សីតុណ្ហភាពត្រជាក់ពេក គ្រោះទឹកជំនន់ និងការរលាយនូវផ្ទាំង-ទឹកកកជាដើម ដែលបញ្ហាទាំងអស់នេះសុទ្ធសឹងតែជាឧបសគ្គរាំងស្ទះក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជាទាំងមូល។

**៥.២.២.៥. គាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព**

ការអភិវឌ្ឍទាំងអស់ មិនប្រាកដថាជាការអភិវឌ្ឍប្រកបដោយចីរភាពនោះទេ ប្រសិនបើអ្នកប្រើប្រាស់ធនធានមិនសំចៃ ឬលើសកម្រិត ពិសេសគឺធនធានធម្មជាតិដែលងាយនឹងបាត់បង់។ អ្នកសេដ្ឋកិច្ចតែងប្រាថ្នាចង់បានការអភិវឌ្ឍណាដែលប្រកបដោយចីរភាព ឬការអភិវឌ្ឍដែលមានភាពគង់ វង្សយូរអង្វែង ព្រោះថាបើកាលណា ប្រទេសជាតិមួយមានការអភិវឌ្ឍមានត្រឹមតែរយៈពេលខ្លី នោះប្រទេសជាតិនោះ ពុំមែនជាប្រទេសអភិវឌ្ឍពិតប្រាកដនោះទេ។ ដើម្បីទទួល

បាននូវការអភិវឌ្ឍប្រកប ដោយចីរភាព អ្នកប្រើប្រាស់ទាំងអស់ត្រូវយល់ដឹងពីរបៀបនៃការប្រើប្រាស់ធនធានធម្មជាតិឱ្យបានត្រឹមត្រូវ ដោយធ្វើយ៉ាងណាឱ្យការប្រើប្រាស់នោះប្រកបដោយប្រសិទ្ធភាព និងរក្សាធនធានធម្មជាតិទាំងនោះឱ្យអ្នកជំនាន់ក្រោយបានប្រើប្រាស់ផងដែរ នោះការអភិវឌ្ឍនឹងមានភាពស្ថិតស្ថេរ។ ផ្ទុយទៅវិញ ប្រសិនបើអ្នកប្រើប្រាស់ពុំបានយល់ដឹងពីការប្រើប្រាស់ធនធានធម្មជាតិឱ្យបានត្រឹមត្រូវនោះទេ នោះការអភិវឌ្ឍក៏មិនមានភាពស្ថិតស្ថេរដែរ។

ថ្វីត្បិតតែ ការបង្កើតរោងចក្រឧស្សាហកម្មបានធ្វើឱ្យប្រទេសជាតិមានការអភិវឌ្ឍ ប៉ុន្តែប្រសិន បើការបង្កើតរោងចក្រឧស្សាហកម្មនោះ ពុំបានគិតគូរវែងឆ្ងាយដល់បញ្ហាបរិស្ថាន នោះការអភិវឌ្ឍនោះនឹងទទួលបានមកវិញនូវគ្រោះមហន្តរាយនាថ្ងៃអនាគត។ ហេតុនេះ ទើបប្រទេសកម្ពុជាធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើគម្រោងឧស្សាហកម្ម ក្នុងគោលបំណងថែរក្សាធនធានធម្មជាតិឱ្យបានគង់វង្ស និងកាត់បន្ថយការបំពុលដែលចេញពីដំណើរការផលិតរបស់រោងចក្រ ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព។

# ជំពូកទី៦
# បញ្ហាប្រឈម និងដំណោះស្រាយ

## ៦.១. បញ្ហាប្រឈម

ទោះបីជាច្បាប់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានអនុម័តតាំងពីឆ្នាំ១៩៩៦មកម្ល៉េះ ក៏ប៉ុន្តែក្រសួងបរិស្ថានបានអះអាងថាការអនុវត្តនៅមានកម្រិតនៅឡើយ។ ជាមួយគ្នានេះដែរក្រសួងបរិស្ថានបានរកឃើញនូវបញ្ហាប្រឈមមួយចំនួន ដែលនាំអោយការអនុវត្តមិនទាន់មានប្រសិទ្ធភាពខ្ពស់។ បញ្ហាប្រឈមទាំងនោះមានដូចជា៖

- កង្វះឧបករណ៍វាយតម្លៃបរិស្ថានយុទ្ធសាស្ត្រសម្រាប់កំណត់តំបន់អភិវឌ្ឍន៍ និងតំបន់អភិរក្ស ហើយតំបន់អភិវឌ្ឍន៍នេះទៀតសោតពុំមានផែនការច្បាស់ សម្រាប់អភិវឌ្ឍន៍លើវិស័យឧស្សាហកម្ម ថាមពល រ៉ែ កសិ-ឧស្សាហកម្ម ទេសចរណ៍ និងហេដ្ឋារចនាសម្ព័ន្ធ
- កង្វះឧបករណ៍ច្បាប់សម្រាប់ពង្រឹងដល់ការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- កង្វះកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធលើវិស័យអភិវឌ្ឍន៍នានា
- ក្រសួងពុំមានការផាកពិន័យ ឬចំណាត់ការផ្លូវច្បាប់ទៅលើម្ចាស់គម្រោងពុំអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថាន និងកិច្ចសន្យាការពារបរិស្ថាន ជាពិសេសគម្រោងដែលគ្មានច្បាប់អនុញ្ញាតពីក្រសួងបរិស្ថាន
- នីតិវិធីរដ្ឋបាលមានភាពស្មុគស្មាញ
- ជំរុញ និងប្រមូលមូលនិធិទាយជ្ជទានបរិស្ថាននៅមានកម្រិត
- សមត្ថភាពអ្នកពាក់ព័ន្ធដូចជាវិស័យឯកជន និងសង្គមស៊ីវិលនៅមានកម្រិត
- ដៃគូអភិវឌ្ឍន៍តែងតែអនុវត្តគោលការណ៍ណែនាំស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់ខ្លួន ដែលតែងតែខុសគ្នានឹងគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន

សមត្ថភាពរបស់មន្ត្រីរាជការមួយចំនួននៅមានកម្រិត ជាពិសេសមន្ត្រីថ្នាក់រាជធានី ខេត្ត។

## ៦.២. ដំណោះស្រាយ

ទន្ទឹមនឹងបញ្ហាប្រឈមខាងលើ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន បានដាក់ចេញនូវទិសដៅ និងយុទ្ធសាស្ត្រដូចខាងក្រោម៖

- ការវាយតម្លៃបរិស្ថានយុទ្ធសាស្ត្រ
- ជំរុញការកសាងលិខិតបទដ្ឋានគតិយុត្តិ និងការអនុវត្តន៍ច្បាប់

- ពង្រៀងច្បាប់ដែលមានតម្រូវការសម្រាប់បង្កភាពងាយស្រួលដល់ការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថានអោយមានប្រសិទ្ធភាព(ក្រមបរិស្ថាន)
- បង្កើនគោលការណ៍ណែនាំតាមវិស័យ
- ការសហាការជាមួយក្រសួងពាក់ព័ន្ធក្នុងការកំនត់នូវអត្តសញ្ញាណរោងចក្រ ឬគម្រោងដែលត្រូវពិនិត្យនិងវាយតម្លៃ
- បង្កើនប្រសិទ្ធភាពការពិនិត្យ និងវាយតម្លៃគម្រោងអភិវឌ្ឍន៍
- ជំរុញការចូលរួមជាសាធារណៈ ផ្សព្វផ្សាយពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដល់សាធារណៈជនតាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ
- ការបណ្តុះបណ្តាលបច្ចេកវិទ្យា និងការអភិវឌ្ឍធនធានមនុស្សទាំងថ្នាក់ជាតិនិងក្រោមជាតិតាមរយៈកម្មវិធីសិក្ខាសាលាក្នុងនិងក្រៅប្រទេស បណ្តុះបណ្តាលមន្ត្រីមន្ទីររាជធានី-ខេត្តចំនួនពីរដងក្នុងមួយឆ្នាំ។

# សេចក្តីសន្និដ្ឋាន និង អនុសាសន៍

## ១. សន្និដ្ឋាន

នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានតួនាទី ពិនិត្យ និងវាយតម្លៃលើរបាយការណ៍អង្កេតតាមដានបរិស្ថាននៃគម្រោងសាធារណៈ និងគម្រោងវិនិយោគឯកជន ក្នុងគោលបំណងថែរក្សា និងការពារគុណភាពបរិស្ថានឱ្យមានភាពគង់វង្ស ដើម្បីជួយគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព។ បរិស្ថានគឺជាឧបករណ៍សំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ពីព្រោះថាធនធានធម្មជាតិភាគច្រើនជាវត្ថុធាតុដើមសម្រាប់ផលិតជាផលិតផលប្រើប្រាស់ ដើម្បីបំពេញនូវតម្រូវការរបស់អ្នកប្រើប្រាស់។ មិនតែប៉ុណ្ណោះ បរិស្ថានក៏មានតួនាទីយ៉ាងសំខាន់ផងដែរក្នុងការរស់នៅប្រចាំថ្ងៃ ព្រោះថាមនុស្សគ្រប់រូបសុទ្ធតែត្រូវការ ទឹក ដី ខ្យល់ អាហារ និងសម្ភារៈទ្រទ្រង់ផ្សេងៗ។ ផ្ទុយមកវិញ ប្រសិនបើបរិស្ថានមានបញ្ហា នោះវានឹងជះឥទ្ធិពលអវិជ្ជមានត្រលប់មកវិញយ៉ាងធ្ងន់ធ្ងរដល់ប្រជាជន និងការអភិវឌ្ឍប្រទេសជាតិទាំងមូល។ម្យ៉ាងវិញទៀត បញ្ហាបរិស្ថានងាយនឹងកើតឡើង តែបើកើតឡើងហើយ គឺមិនអាចជួលជុលឱ្យដូចដើមវិញឡើយ ដូចជា ការបាត់បង់វត្ថុធាតុដើម និងការបំពុលខ្យល់ជាដើម ដែលការបំពុលខ្យល់ភាគច្រើនកើតចេញពីរោងចក្រឧស្សាហកម្ម។ ហេតុនេះហើយ ទើបក្រសួងបរិស្ថានបានបង្កើតនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះឡើង ដើម្បីធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើរាល់គម្រោងមុននឹងធ្វើការសាងសង់ និងពិនិត្យតាមដានជារៀងរាល់៦ខែម្តង។

ជាក់ស្តែង ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើគម្រោងឧស្សាហកម្ម បានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនសម្រាប់ម្ចាស់គម្រោង និងប្រទេសជាតិទាំងមូល។ ម្ចាស់គម្រោងនឹងទទួលបាននូវដំណោះស្រាយ និងមតិយោបល់លើដំណើរការគម្រោងរបស់ពួកគេ ដើម្បីកុំឱ្យមានបញ្ហារាំងស្ទះណាមួយនៅថ្ងៃខាងមុខ។ ក្រៅពីនេះ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើគម្រោងឧស្សាហកម្មបានចូលរួមអភិវឌ្ឍសេដ្ឋកិច្ចជាតិទាំងមូលតាមរយៈ ការបង្កើតការងារដល់ប្រជាពលរដ្ឋ ការកាត់បន្ថយភាពក្រីក្រ ការផ្តល់នូវស្តង់ដារនៃការរស់នៅរបស់ប្រជាជន និងគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព។ ព្រោះថា បន្ទាប់ពីបានធ្វើការពិនិត្យវាយតម្លៃរួច នោះរាល់ការបំពុលបរិស្ថានដែលនឹងចេញពីរោងចក្រនោះ នឹងត្រូវបានទប់ស្កាត់ និងកាត់បន្ថយជាអប្បបរមាដោយអនុវត្តន៍វិធានការណ៍កាត់បន្ថយ។ ពេលនោះ រោងចក្រឧស្សាហកម្មនឹងមានការដំណើរការទៅមុខយ៉ាងរលូន ដោយមិនភ័យខ្លាចមានការបំពុលបរិស្ថានលើសកម្រិតចេញពីរោងចក្រនៅថ្ងៃខាងមុខឡើយ។

ដូចនេះ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពិតជាមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា និងគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព។

## ២. អនុសាសន៍

ការវាយម្លៃហេតុប៉ះពាល់បរិស្ថានពិតជាមានសារៈសំខាន់ក្នុងការអភិវឌ្ឍប្រទេសកម្ពុជាដោយមិនអាចខ្វះបានទេ ពីព្រោះថារាល់ការអភិវឌ្ឍតែងតែមានផលប៉ះពាល់ទៅលើបរិស្ថាន។ ដូច្នេះ ការបង្កើនការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះអោយមានប្រសិទ្ធភាពនិងគ្រប់ជ្រុងជ្រោយគឺជាតួនាទីរបស់រាជរដ្ឋាភិបាលដែលគួរតែយកចិត្តទុកដាក់ខ្លាំងមែនទែន។ យើងដឹងថាការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់ក្រសួងពុំទាន់មានប្រសិទ្ធភាពខ្ពស់ និងបញ្ហាប្រឈមជាច្រើន ហើយក្រសួងក៏បានមាននូវដំណោះស្រាយជាច្រើនដូចជាយុទ្ធសាស្ត្ររបស់នាយកដ្ឋានផងដែរ ប៉ុន្តែការអនុវត្តនូវដំណោះស្រាយនោះពុំទាន់ឆ្លើយតបនឹងតម្រូវការនៅឡើយទេ។ ក្នុងនោះផងដែរ ក្រៅពីសំណូមពរអោយមន្ត្រីពាក់ព័ន្ធទាំងអស់អនុវត្តនូវទិសដៅយុទ្ធសាស្ត្ររបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន យើងខ្ញុំមានអនុសាសន៍សម្រាប់ចូលរួមមួយចំនួនទៀត ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះឱ្យកាន់តែមានប្រសិទ្ធភាព។ អនុសាសន៍ទាំងនោះមានដូចជា៖

- ដើម្បីអោយការអនុវត្តលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើគម្រោងនានាក្នុងប្រទេសកម្ពុជាអោយបានគ្រប់គម្រោង ក្រសួងគួរតែសិក្សាស្រាវជ្រាវថាតើគម្រោងនៅកម្ពុជាមានគម្រោងប៉ុន្មានទៀតដែលក្រសួងមិនទាន់បានត្រួវពិនិត្យ និងវាយតម្លៃ។ ក្នុងនេះមានន័យថា ក្រសួងគួរតែដឹងពីភាគរយនៃចំនួនគម្រោង ដែលក្រសួងបានធ្វើការវាយតម្លៃហាតុប៉ះពាល់

  បរិស្ថានរួច ធៀបនឹងគម្រោងទាំងអស់ដែលត្រូវវាយតម្លៃ។ ការធ្វើបែបនេះ ក្រសួងនឹងដឹងពីសមត្ថភាពក្នុងការអនុវត្តរបស់ខ្លួន ហើយដឹងថាគួរជម្រុញយ៉ាងណាដើម្បីអោយការអនុវត្តបានគ្រប់ជ្រុងជ្រោយ
- ក្រសួងគួរតែបង្កើនការសហាការជាមួយក្រសួងពាក់ព័ទ្ធដទៃទៀតដូចជាក្រសួងពាណិជ្ជកម្ម និងក្រុមប្រឹក្សាអភិវឌ្ឍន៍ជាតិជាដើម ដើម្បីកុំអោយមានការរំលងនូវគម្រោងថ្មីៗ ដែលគ្រោងនឹងបង្កើតនៅក្នុងប្រទេស

- ជំរុញ និងធ្វើការយ៉ាងជិតស្និទ្ធជាមួយមន្ត្រីថ្នាក់ក្រោមជាតិក្នុងការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីអោយពួកគាត់យកចិត្តទុកដាក់ធ្វើការស្វែងរកគម្រោងដែលត្រូវវាយតម្លៃ និងត្រួតពិនិត្យគម្រោងជាប្រចាំតាមគោលការណ៍ដែលកំណត់
- ផ្សព្វផ្សាយអោយទូលំទូលាយជាងនេះអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទៅដល់សាធារណជនទាំងឡាយ
- អនុវត្តច្បាប់អោយតឹងរឹងចំពោះគម្រោងដែលមិនគោរពតាមគោលការណ៍ណែនាំរបស់ក្រសួង។

# គន្ថនិទ្ទេស


## **ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត**

អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន, លេខ៥៧អនក្រ.បក, ២៥ កញ្ញា ១៩៩៧។

អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន, លេខ៧២អនក្រ.បក, ១១ សីហា ១៩៩៩។

ប្រកាសស្តីពីប្រតិភូកម្មអំណាចក្នុងការធ្វើសេចក្តីសម្រេចក្នុងនាមក្រសួងចំពោះគំរោងវិនិយោគជូនមន្ទីរបរិស្ថានខេត្ត-ក្រុង, លេខ២៣០ ប្រក ប.ស្ក, ២៩ កក្កដា ២០០៥។

ប្រកាសស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់ដំបូង និងពេញលេញ, លេខ៣៧៦ ប្រក ប.ស្ក, ២ កញ្ញា ២០០៩។

ប្រកាសស្តីពីការចុះបញ្ជីក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម, លេខ២១៥ ប្រក ប.ស្ក, ១៩ ឧសភា ២០១៤។

## **សៀវភៅជាភាសាខ្មែរ**

ក្រសួងបរិស្ថាន. *អំពីក្រសួងបរិស្ថាន*, (គ្មានកាលបរិច្ឆេទ), http://www.moe.gov.kh/about-moe (ចូលទស្សនា ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩)។

ក្រសួងបរិស្ថាន. *កម្រងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន*, (២០១៨)។

អង្គការទិន្នន័យអំពីការអភិវឌ្ឍ. *ភាគសំណល់រឹង*, ២០១៦, https://opendevelopmentcambodia.net/km/topics/solid-waste/#ref-90788-2 (ចូលទស្សនាថ្ងៃទី៧ ឧសភា ២០១៩)។

អង្គការទិន្នន័យអំពីការអភិវឌ្ឍ. ការប្រែប្រួលអាកាសធាតុ, ២០១៦, https://opendevelopmentcambodia.net/km/topics/climate-change/ (ចូលទស្សនាថ្ងៃទី៥ ឧសភា ២០១៩)។

អង្គការទិន្នន័យអំពីការអភិវឌ្ឍ. *ការបំពុលខ្យល់*, ២០១៦, https://opendevelopmentcambodia.net/km/topics/air-pollution/#ref-90916-3 (ចូលទស្សនាថ្ងៃទី៧ ឧសភា ២០១៩)។

អង្គការទិន្នន័យអំពីការអភិវឌ្ឍ. *បរិស្ថាន និងធនធានធម្មជាតិ*, ២០១៥, https://opendevelopmentcambodia.net/km/topics/environment-and-natural-resources/#return-note-64105-14 (ចូលទស្សនាថ្ងៃទី៣០ ខែមេសា ២០១៩)។

## សៀវភៅជាភាសាអង់គ្លេស

Army Institute Professor Ministry. *មេរៀនបរិស្ថាន*. ២០១៦. http://www.armyinstitute.epizy. com (ចូលទស្សនាថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៩)។

Economicshelp. *Difference between economic growth and development*, (២០១៥), https://www.economicshelp.org/blog/1187 /development/economic-growth-and-development/ (ចូលទស្សនាថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៩)។

Everett. T & others. *Economics Growth and the Environment*, (២០១០), អាចរកបាននៅ https://assets.publishing.service.gov.uk/government/ uploads/system/uploads/ attachmentdata/file/69195/pb13390-economic-growth-100305.pdf, (ចូលទស្សនាថ្ងៃទី៣០ ខែមេសា ២០១៩)។

Jim Chappelow. *Economics: overview, types, and economic indicators*, (2019), https://www.investopedia.com/ terms/e/economics.asp, (ចូលទស្សនាថ្ងៃទី៤ ឧសភា ២០១៩)។

Soas. *Economics Principles*, (គ្មានកាលបរិច្ឆេទ), https://www.soas.ac.uk/cedep-demos/000_P542_EP_K3736-Demo/module/ topindex.htm (ចូលទស្សនាថ្ងៃទី៤ ឧសភា ២០១៩)។

University of Wollongong. *What is eia?*, (គ្មានកាលបរិច្ឆេទ), https://www.uow.edu.au/~sharonb/STS218/eis/what.html (ចូលទស្សនាថ្ងៃទី០៩ ឧសភា ឆ្នាំ២០១៩)។

Acciona. *What is sustainable development and what are the global goals*, (គ្មានកាលបរិច្ឆេទ), https://www.acciona.com/sustainable-development/ (ចូលទស្សនាថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩)។

# ឧបសម្ព័ន្ធ